# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣៦

## សឡាយតនវគ្គ អដ្ឋមភាគ

ពុទ្ធសករាជ ២៥៥៦

**អធិប្បាយ**

**៩ សំយុត្ត**

ព្រះអដ្ឋកថាកែសេចក្ដី ៦៤ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

ភាគ ៣៦

## សឡាយតនវគ្គ អដ្ឋមភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

៩ សំយុត្ត

ព្រះអដ្ឋកថាកែសេចក្តី ៦៤ សូត្រ

# សឡាយតនវគ្គ

## អដ្ឋមភាគ មាន ៩ សំយុត្ត

| | | | |
|---|---|---|---|
| ១-វេទនាសំយុត្ត | មាន | ១៩ | អដ្ឋកថា |
| ២-មាតុគ្រាមសំយុត្ត | មាន | ០៧ | អដ្ឋកថា |
| ៣-ជម្ពុខាទកសំយុត្ត | មាន | ០៦ | អដ្ឋកថា |
| ៤-សាមណ្ឌកសំយុត្ត | មាន | ០១ | អដ្ឋកថា |
| ៥-មោគ្គល្លានសំយុត្ត | មាន | ០៤ | អដ្ឋកថា |
| ៦-ចិត្តគហបតិបុច្ឆាសំយុត្ត | មាន | ១០ | អដ្ឋកថា |
| ៧-គាមណិសំយុត្ត | មាន | ១១ | អដ្ឋកថា |
| ៨-អសង្ខតសំយុត្ត | មាន | ០១ | អដ្ឋកថា |
| ៩-អព្យាកតសំយុត្ត | មាន | ០៥ | អដ្ឋកថា |

រួមក្នុងអដ្ឋមភាគនេះ មាន

៩ សំយុត្ត ព្រះអដ្ឋកថាចានកែសេចក្ដីដែល

លំចាកសរុបមានចំនួន ៦៤ សូត្រ

# ស្រៈនិងស្រ័យ

# *Signes et accents:*



# ស្រះពេញតួ
# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | a | ā | i | i | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | [illegible] | [illegible] |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សឹង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្តើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមឡើងដោយពាក្យថា សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្តែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្តី*

រីករាយ និងស្តួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាមឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែលបណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់របូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា**ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធ: ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋ: ) ខ្វះ ( សិរិកូដ្ឋ: ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រូតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទូន

ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត

ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី

ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉េយ៉ា

ឧបាសក សុក្រ ហ៊ត

ឧបាសក សោម រតនៈ

ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ផុន

ឧបាសក ជា ស៊ីបាន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ន    ឧបាសក ហាយ ចំរើន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **វេទនាសំយុត្តទី ១** | | |
| អដ្ឋកថា សមាធិសូត្រ | ទី ១ | ១ |
| អដ្ឋកថា សុខសូត្រ | ទី ២ | ៣ |
| អដ្ឋកថា បហានសូត្រ | ទី ៣ | ៥ |
| អដ្ឋកថា ចាតាលសូត្រ | ទី ៤ | ៧ |
| អដ្ឋកថា ទដ្ឋព្វសូត្រ | ទី ៥ | ៩ |
| អដ្ឋកថា សល្លត្ថសូត្រ | ទី ៦ | ១០ |
| អដ្ឋកថា បឋមគេលញ្ញសូត្រ | ទី ៧ | ១២ |
| អដ្ឋកថា ទុតិយគេលញ្ញសូត្រ | ទី ៨ | ១៤ |
| អដ្ឋកថា អនិច្ចសូត្រ | ទី ៩ | ១៥ |
| អដ្ឋកថា ផស្សមូលកៈសូត្រ | ទី ១០ | ១៦ |
| **រហោគតវគ្គទី ២** | | |
| អដ្ឋកថា រហោគតសូត្រ | ទី ១ | ១៧ |
| អដ្ឋកថា បឋមវាតសូត្រ | ទី ២ | ១៩ |
| អដ្ឋកថា ទុតិយវាតសូត្រ | ទី ៣ | ២០ |
| អដ្ឋកថា អគារសូត្រ | ទី ៤ | ២១ |
| អដ្ឋកថា បញ្ចកង្គៈសូត្រ | ទី ៩ | ២៣ |
| អដ្ឋកថា ភិក្ខុសូត្រ | ទី ១០ | ២៦ |

## អដ្ឋសតបរិយាយវគ្គទី ៣


| | | |
|---|---|---|
| អដ្ឋកថា សិវកសូត្រ | ទី ១ | ២៧ |
| អដ្ឋកថា អដ្ឋសតបរិ...សូត្រ | ទី ២ | ៣១ |
| អដ្ឋកថា និរាមិសសូត្រ | ទី ១១ | ៣៧ |


## មាតុគ្រាមសំយុត្តទី ២


| | | |
|---|---|---|
| អដ្ឋកថា អមនាបសូត្រ | ទី ១ | ៣៩ |
| អដ្ឋកថា អវេណិកសូត្រ | ទី ៣ | ៤១ |
| អដ្ឋកថា មាតុគ្រាមសូត្រ | ទី ៤ | ៤២ |


## មាតុគាមពលវគ្គ


| | | |
|---|---|---|
| អដ្ឋកថា វិសារទសូត្រ | ទី ១ | ៤៥ |
| អដ្ឋកថា បសយ្ហសូត្រ | ទី ២ | ៤៦ |
| អដ្ឋកថា អភិភុយ្យសូត្រ | ទី ៣ | ៤៧ |
| អដ្ឋកថា នាសយិត្តសូត្រ | ទី ៥ | ៤៨ |


## ជម្ពុខាទកសំយុត្តទី ៣


| | | |
|---|---|---|
| អដ្ឋកថា និព្វានបញ្ហាសូត្រ | ទី ១ | ៤៩ |
| អដ្ឋកថា អរហត្តបញ្ហាសូត្រ | ទី ២ | ៥២ |
| អដ្ឋកថា ធម្មវាទីបញ្ហាសូត្រ | ទី ៣ | ៥៣ |
| អដ្ឋកថា កិមត្ថិយសូត្រ | ទី ៤ | ៥៤ |
| អដ្ឋកថា ទុក្ខបញ្ហាសូត្រ | ទី ១៤ | ៥៥ |
| អដ្ឋកថា ទុក្ករបញ្ហាសូត្រ | ទី ១៦ | ៥៦ |

## សាមណ្ឌកសំយុត្តទី ៤

អដ្ឋកថា សាមណ្ឌកសំយុត្តសូត្រ ៥៧

## មោគ្គល្លានសំយុត្តទី ៥

អដ្ឋកថា សវិតក្កបញ្ហាសូត្រ ទី ១ ៥៨
អដ្ឋកថា អវិតក្កបញ្ហាសូត្រ ទី ២ ៥៩
អដ្ឋកថា អនិមិត្តបញ្ហាសូត្រ ទី ៩ ៦០
អដ្ឋកថា សក្កសូត្រ ទី ១០ ៦២

## ចិត្តគហបតិបុច្ឆាសំយុត្តទី ៦

អដ្ឋកថា សំយោជនសូត្រ ទី ១ ៦៣
អដ្ឋកថា បឋមឥសិទត្តសូត្រ ទី ២ ៦៥
អដ្ឋកថា ទុតិយឥសិទត្តសូត្រ ទី ៣ ៦៧
អដ្ឋកថា មហកសូត្រ ទី ៤ ៦៨
អដ្ឋកថា បឋមកាមភូសូត្រ ទី ៥ ៧០
អដ្ឋកថា ទុតិយកាមភូសូត្រ ទី ៦ ៧១
អដ្ឋកថា គោទត្តសូត្រ ទី ៧ ៨២
អដ្ឋកថា និគណ្ឋសូត្រ ទី ៨ ៨៧
អដ្ឋកថា អចេលសូត្រ ទី ៩ ៩០
អដ្ឋកថា គិលានសូត្រ ទី ១០ ៩១

## គាមណិសំយុត្តទី ៧

អដ្ឋកថា ចណ្ឌសូត្រ ទី ១ ៩៣
អដ្ឋកថា តាលបុត្តសូត្រ ទី ២ ៩៤
អដ្ឋកថា យោធាជីវសូត្រ ទី ៣ ៩៧

អដ្ឋកថា អសិពន្ធកបុត្តសូត្រ ទី ៦ ៩៩
អដ្ឋកថា ទេសនាសូត្រ ទី ៧ ១០១
អដ្ឋកថា សង្ខធម្មសូត្រ ទី ៨ ១០៤
អដ្ឋកថា កុលសូត្រ ទី ៩ ១០៧
អដ្ឋកថា មណិចូឡកសូត្រ ទី ១០ ១១០
អដ្ឋកថា គន្ធភកសូត្រ ទី ១១ ១១៣
អដ្ឋកថា រាសិយសូត្រ ទី ១២ ១១៤
អដ្ឋកថា ទាដលិយសូត្រ ទី ១៣ ១១៨

## អសង្ខតសំយុត្តទី ៨

អដ្ឋកថា វគ្គទី ១ និងវគ្គទី ២ ១២២

## អព្យាកតសំយុត្តទី ៩

អដ្ឋកថា ខេមាថេរីសូត្រ ទី ១ ១២៨
អដ្ឋកថា បឋមសារីបុត្ត..សូត្រទី ៣ ១៣១
អដ្ឋកថា កុតុហលសាលាសូត្រទី ៩ ១៣២
អដ្ឋកថា អានន្ទសូត្រ ទី ១០ ១៣៣
អដ្ឋកថា សភិយសូត្រ ទី ១១ ១៣៤

# អដ្ឋកថា វេទនាសំយុត្ត

## បឋមកសគាថវគ្គទី ១

## អ ដ្ឋ ក ថា

### សមាធិសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមាធិសូត្រទី ១ នៃ សហគាថាវគ្គ១ ក្នុង វេទនាសំយុត្ត ដូចតទៅនេះ ។*

[២] *បទថា **មានចិត្តតាំងមាំល្អហើយ (សមាហិតោ)** សេចក្តីថា មានចិត្តតាំងមាំដោយឧបចារៈ ឬដោយអប្បនា ។ បទថា **រមែងដឹងច្បាស់នូវវេទនា (វេទនា ច បជានាតិ)** សេចក្តីថា សាវករបស់ព្រះមានព្រះភាគ រមែងដឹងច្បាស់នូវវេទនាដោយអំណាចជាទុក្ខសច្ចៈ ។ បទថា **និងហេតុកើតនៃវេទនា (វេទនានញ្ច សម្ភវំ)** សេចក្តីថា រមែងដឹងច្បាស់ហេតុកើតនៃវេទនាទាំងនោះឯង ដោយអំណាចជាសមុទយសច្ចៈ ។ បទថា **វេទនាទាំងនេះ...ក្នុងទីណា (យត្ថ ចេតា)** សេចក្តីថា វេទនាទាំងនេះ នឹងរលត់ក្នុងនិព្វានណា រមែងដឹងច្បាស់នូវនិព្វាននោះ ដោយជានិរោធសច្ចៈ ។ បទថា **ឲ្យដល់ការអស់ទៅ***

*(ខយគាមិនំ) សេចក្តីថា រមែងដឹងច្បាស់នូវផ្លូវឲ្យដល់ការអស់ទៅនៃវេទនាទាំងនោះឯង ដោយអំណាចនៃមគ្គសច្ចៈ ។ បទថា* ***ជាអ្នកអស់សេចក្តីស្រេកឃ្លាន (និច្ឆាតោ បរិនិព្វុតោ)*** *សេចក្តីថា ភិក្ខុដែលអស់តណ្ហា បរិនិព្វានហើយដោយការរលត់កិលេស ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វេទនាដែលប្រព្រឹត្តទៅក្នុងការពិចារណាដោយប្រការដូច្នេះ ។ ទ្រង់ត្រាស់សមថៈនិងវិបស្សនា ដោយបទទាំងពីរក្នុងគាថាទាំងឡាយ ។ ត្រាស់សច្ចៈ ៤ ដោយបទដ៏សេស ការកំណត់ធម៌ប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលរួបរួមធម៌ទុកទាំងអស់ ក៏បានត្រាស់ទុកក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សមាធិសូត្រទី ១

# អ ដ្ឋ ក ថា

## សុខសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង សុខសូត្រទី ២ ដូចតទៅនេះ ៖

[៤] បទថា **មិនមែនទុក្ខមិនមែនសុខក៏ដោយ** (អទុក្ខមសុខំ សហ) បានដល់ មិនមែនទុក្ខមិនមែនសុខ ព្រមដោយសុខ និងទុក្ខ បទថា **ទាំងជាខាងក្នុង និងខាងក្រៅ** (អជ្ឈត្តញ្ច ពហិទ្ធា ច) សេចក្តីថា របស់ខ្លួន និងរបស់អ្នកដទៃ ។

បទថា **មានសេចក្តីវិនាសជាធម្មតា** (មោសធម្មំ) គឺ មានសេចក្តីវិនាសជាសភាព ។

បទថា **មានសេចក្តីបែកធ្លាយជាធម្មតា** (បលោកិនំ) គឺ មានសេចក្តីបែកជាសភាព ។ បទថា **ពាល់ត្រូវសេចក្តីវិនាស** (ដោយញាណ) **ហើយ** (ផុស្ស ផុស្ស វយំ ផុស្សំ) សេចក្តីថា ពាល់ត្រូវសេចក្តីវិនាស ព្រោះពាល់ត្រូវដោយញាណ ។ បទថា **រមែងប្រាសចាកតម្រេកក្នុងវេទនាទាំងនោះដោយប្រការដូច្នេះ** (ឯវំ តត្ថ វិរជ្ជតិ) សេចក្តីថា រមែងប្រាសចាកសេចក្តីត្រេកអរ

ក្នុងវេទនាទាំងនោះ ដោយប្រការយ៉ាងនេះ ។ ក្នុងព្រះសូត្រសូម្បីនេះ ត្រាស់វេទនាដែលប្រព្រឹត្តទៅក្នុងការពិចារណា ត្រាស់ការពាល់ត្រូវដោយញាណក្នុងគាថាទាំងឡាយ ។

ចប់អដ្ឋកថា សុខសូត្រទី ២

# អ ដ្ឋ ក ថា

## បហានសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បហានសូត្រទី ៣** ដូចតទៅនេះ ៖*

[៤] *បទថា **ផ្តាច់បង់តណ្ហាបានហើយ (អច្ឆេជ្ជិ តណ្ហំ)** សេចក្តីថា កាត់តណ្ហាសូម្បីទាំងពួងបានដាច់ហើយ ។ បទថា **គាស់រំលើងសំយោជនៈបានហើយ (វិវត្តយិ សញ្ញោជនំ)** សេចក្តីថា គាស់រំលើងសញ្ញោជនៈទាំង ១០ យ៉ាង បានហើយ គឺ បានធ្វើឲ្យអស់ឫសគល់ ។ បទថា **ដោយល្អ (សម្មា)** គឺ ដោយហេតុ គឺ ដោយការណ៍ ។ បទថា **ព្រោះលះបង់មានះបាន (មានាភិសមយា)** សេចក្តីថា ព្រោះឃើញ និងដឹងច្បាស់ ដល់ការលះមានះចេញបាន ព្រោះថា អរហត្តមគ្គ រមែងឃើញមានះ ដោយអំណាចនៃកិច្ច ។ នេះចាត់ជាការលះបង់មានះនោះដោយទស្សនៈ ។ ចំណែកមានះដែលអរហត្តមគ្គនោះឃើញហើយ រមែងលះបានទាន់ពេល ដូចជីវិតរបស់សត្វដែលបុគ្គលឃើញហើយ លះបានដោយអំណាចទិដ្ឋិដូច្នោះ ។ នេះចាត់ជាការលះបង់មានះនោះ ដោយបហានៈ ។ បទថា **បានធ្វើទីបំផុតនៃទុក្ខហើយ (អន្តមកាសិ ទុក្ខស្ស)** លោកអធិប្បាយថា ទីបំផុតទាំង ៤ នេះណា*

គឺ ទីបំផុតមានដែនខេត្តជាទីបំផុត តាមដែលលោកពោលយ៉ាងនេះថា គ្រឿងបង់កាយ រមែងគ្រាំគ្រាជាទីបំផុត ឬមានសេចក្តីស្អាតជាទីបំផុតដូច្នេះ ១ ទីបំផុតនៃលាមក ព្រះអង្គត្រាស់យ៉ាងនេះថា នេះជាទីបំផុតនៃជីវិត ណាំភិក្ខុទាំងឡាយ ដូច្នេះ ១ ចំណែកបំផុតតាមដែលលោកពោលយ៉ាងនេះថា កាយរបស់ខ្លួនមានទីបំផុតម្យ៉ាង ដូច្នេះ ១ ចំណែកបំផុតតាមដែលលោកពោលយ៉ាងនេះថា នុ៎ះឯង ជាទីបំផុតនៃទុក្ខ ព្រោះអស់បច្ច័យ ដូច្នេះ ១ ក្នុងទីបំផុតទាំង ៤ នោះ ភិក្ខុបានធ្វើទីបំផុត ពោលគឺ ចំណែកទី ៤ នៃវដ្ត-ទុក្ខទាំងអស់នុ៎ះឯង គឺ បានធ្វើការកំណត់ ការដែលកំណត់ទុក គឺ បានធ្វើទុក្ខនៅសល់ត្រឹមតែរាងកាយជាទីបំផុត ព្រោះអរហត្តមគ្គឃើញ និងលះមានះបាន ។

[៦] បទថា **មិនលះបង់សម្បជញ្ញៈ (សម្បជញ្ញេន រិញ្ចតិ)** បានដល់ រមែងលះបង់សម្បជញ្ញៈ ។ បទថា **រមែងមិនចូលដល់ការរាប់ (សំខ្យំ នូបេតិ)** សេចក្តីថា រមែងមិនចូលដល់ការបញ្ញត្តថា ជាអ្នកពេញចិត្ត ទាស់ចិត្ត ជាអ្នកវង្វេង ដូច្នេះ លោកលះបង់បញ្ញត្តនោះបានហើយ បានឈ្មោះថា មហា-ខីណាស្រព ។ អារម្មណានុស័យត្រាស់ទុកហើយ ក្នុងព្រះសូត្រនេះឯង ។

ចប់អដ្ឋកថា បហានសូត្រទី ៣

# អ ដ្ឋ ក ថា

## ឆាតាលសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***បាតាលសូត្រទី ៤*** *ដូចតទៅនេះ ៖*

[៧] *បទថា* ***បាតាលោ*** *ឈ្មោះថា បាតាល ព្រោះអត្ថថា គួរ គឺ កាលបើធ្លាក់ទៅក្នុងបាតាល រមែងមិនមានទីអាស្រ័យ ។ បទថា* ***ដែលមិនមាន ដែលមិនប្រាកដ (អសន្តំ អសំវិជ្ជមានំ)*** *បានដល់ វាចាមិនមាន មិនប្រាកដ ។ បទថា* ***រមែងនិយាយវាចាយ៉ាងនេះ (ឯវំ វាចំ ភាសតិ)*** *សេចក្តីថា បុថុជ្ជន រមែងនិយាយយ៉ាងនេះថា ក្នុងមហាសមុទ្រមានបាតាល ។ ក៏បាតាលនោះ ស្រដៀងរណ្តៅក្នុងមហានរក រមែងមានក្នុងទីធ្លាក់នៃទឹក ដែលមានមាត់ទឹកខ្លាំងរបស់មហាសមុទ្រ ហូរទៅលឿនរហ័សទល់ចក្រវាឡ ឬភ្នំសិនេរុ ហើយក៏បាញ់ឡើង សូម្បីប្រមាណមួយយោជន៍ ពីរយោជន៍ ឬ ១០ យោជន៍ ហើយក៏ធ្លាក់ចុះក្នុងមហាសមុទ្រទៀត ។ ទឹកណាគេសន្មតគ្នាក្នុងលោកថា មាត់ទឹកខ្លាំង បុថុជ្ជន រមែងនិយាយយ៉ាងនេះ សំដៅដល់ទឹកនោះ ។ ក៏ព្រោះក្នុងទឹកនៃមហាសមុទ្រនោះ ជាទីអាស្រ័យយ៉ាងសប្បាយរបស់ត្រី អណ្តើក ទេវតា និងយក្ខ ។ ឈ្មោះថា រមែងនិយាយវាចានោះៗ*

ដែលមិនមាន ដែលមិនប្រាកដ ។ ក៏ព្រោះពួកបុថុជ្ជនទាំងពួង រមែងមិនអាចនឹងតាំងនៅដោយទុក្ខវេទនាដែលប្រព្រឹត្តទៅក្នុងសរីរៈបាន ។ ដូច្នោះព្រះអង្គទ្រង់សម្តែងថា នេះឯង បាតាល ដូច្នេះ ដោយន័យថា គួរដើម្បីធ្លាក់ទៅ ទើបត្រាស់ពាក្យជាដើមថា **សារីរិកានំ ខោ ឯតំ ភិក្ខវេ** ។ បទថា **មិនប្រាកដក្នុងបាតាល (បាតាលេ ន បច្ចុដ្ឋាតិ)** គឺ មិនតាំងនៅក្នុងបាតាល ។ បទថា **រមែងដល់ (គាធំ)** គឺ ទីនៅអាស្រ័យ ។ បទថា **រមែងទ្រហោយំ (កន្ទតិ)** សេចក្តីថា រមែងទួញយំរៀបរាប់ កន្ទក់កន្ទេញរហូតកាល ។

[៨] បទថា **ជាអ្នកទុព្វល (ទុព្វលោ)** គឺ មានប្រាជ្ញាថយ ។ បទថា **កម្លាំងតិច (អប្បថាមកោ)** សេចក្តីថា ឈ្មោះថា មានកម្លាំងតិច ព្រោះកម្លាំងនៃប្រាជ្ញាតិច ។ ព្រះអរិយសាវកក្នុងសូត្រនេះជាសោតាបន្ន ការពិតអរិយសាវកជាសោតាបន្ន មាននាទីក្នុងសេចក្តីនេះ ។ ចំណែកយោគាវចរអ្នកមានវិបស្សនាចាស់ក្លា គឺ ប្រាជ្ញាវាងវៃ ជាអ្នកអាចតាំងនៅបាន មិនក្តៅក្រហាយទៅតាមវេទនាដែលកើតឡើងហើយ បានដូចគ្នា ។

ចប់អដ្ឋកថា បាតាលសូត្រទី ៤

# អ ដ្ឋ ក ថា

## ទដ្ឋព្វសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទដ្ឋព្វសូត្រទី ៥ ដូចតទៅនេះ ៖*

[៩] *បទថា* ***គប្បីឃើញសុខវេទនា ដោយសេចក្តីជាទុក្ខ (ទុក្ខតោ ទដ្ឋព្វា)*** *សេចក្តីថា គប្បីឃើញទុក្ខ ដោយអំណាចសេចក្តីប្រែប្រួល ។ បទថា* ***ដូចជាកូនសរ (សល្លតោ)*** *សេចក្តីថា ចំណែកទុក្ខ គប្បីឃើញដូចជាកូនសរ ដោយអត្ថថា ជាគ្រឿងចាក់ ។ បទថា* ***ដោយជារបស់មិនទៀង (អនិច្ចតោ)*** *សេចក្តីថា គប្បីឃើញអទុក្ខមសុខ ដោយជារបស់មិនទៀង ដោយអាការមានហើយក៏មិនមាន ។ បទថា* ***ឃើញ (អទ្ទ)*** *គឺ បានឃើញហើយ ។ បទថា* ***ដែលមានហើយ (សន្តំ)*** *គឺ មានជាសភាវៈ ។*

ចប់អដ្ឋកថា ទដ្ឋព្វសូត្រទី ៥

# អ ដ្ឋ ក ថា

## សល្លត្ថសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សល្លត្ថសូត្រទី ៦** ដូចតទៅនេះ ៖*

*[១១] បទថា **តត្រ** គឺ ក្នុងជនទាំងពីរពួកនោះ ។*

*[១២] បទថា **ចាក់ម្តងទៀត (អនុវេធំ វិជ្ឈេយ្យុំ)** សេចក្តីថា ចាក់ឆ្ងាយពីមាត់ដំបៅនោះប្រមាណ ១ ឬ ២ ម្រាមដៃ ប៉ុណ្ណោះ ។ ទុក្ខវេទនាក៏ប្រាកដដល់បុរសដែលត្រូវចាក់នោះ រមែងមានកម្លាំងខ្លាំងក្លាជាងវេទនាលើកដំបូង ។ សូម្បីទោមនស្សវេទនា កាលកើតឡើងពេលក្រោយ រមែងមានកម្លាំងខ្លាំងជាងវេទនាគ្រាដំបូង ដោយប្រការដូច្នេះឯង ។ បទថា **ឧបាយជាគ្រឿងរលាស់ចេញពីទុក្ខវេទនា (ទុក្ខាយ វេទនាយ និស្សរណំ)** សេចក្តីថា សមាធិ មគ្គ និងផល ជាគ្រឿងរលាស់ចេញសូម្បីទុក្ខវេទនា គេរមែងមិនដឹងគ្រឿងរលាស់ចេញនោះ រមែងដឹងថា កាមសុខប៉ុណ្ណោះ ជាគ្រឿងរលាស់ចេញ ។ បទថា **នៃវេទនាទាំងនោះ (តាសំ វេទនានំ)** បានដល់ សុខទុក្ខវេទនាទាំងនោះ ។ បទថា **បុគ្គលប្រកបដោយកិលេស សោយសុខវេទនា (សញ្ញុត្តោ នំ វេទយតិ)** សេចក្តីថា គេជាអ្នកប្រកបដោយកិលេស រមែង*

សោយវេទនានោះ ។ មិនសោយវេទនានោះក៏ទេ ។ បទថា **សញ្ញុត្តោ ទុក្ខស្មា** ជាបញ្ចមីវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា ប្រកបដោយទុក្ខ ។

[១៥] បទថា **អ្នកមានធម៌ដែលដឹងច្បាស់ហើយ (សង្ខាតធម្មស្ស)** សេចក្ដីថា អ្នកមានធម៌ដែលដឹងច្បាស់ហើយ គឺ អ្នកមានធម៌ដែលថ្លឹងបានហើយ ។ បទថា **ជាពហុស្សូត (ពហុស្សុតស្ស)** សេចក្ដីថា ជាពហុស្សូតក្នុងផ្លូវបរិយត្តិ ជាពហុស្សូតក្នុងផ្លូវបដិវេធ ។ បទថា **រមែងជាអ្នកដល់ត្រើយនៃភព ព្រោះដឹងដោយប្រពៃ (សម្មា បជានាតិ ភវស្ស បារគូ)** សេចក្ដីថា ដល់ហើយនូវត្រើយនៃភព គឺ ព្រះនិព្វាន រមែងដឹងច្បាស់នូវព្រះនិព្វាននោះឯងដោយប្រពៃ ។ អារម្មណានុស័យ ព្រះអង្គត្រាស់ហើយសូម្បីក្នុងព្រះសូត្រនេះ ។ កេចិអាចារ្យពោលថា ក៏បណ្ដាព្រះអរិយសាវកព្រះខីណាស្រព មាននាទីក្នុងអារម្មណានុស័យនេះ ។ សូម្បីព្រះអនាគាមីក៏គួរ ដូច្នេះ ។

ចប់អដ្ឋកថា សល្លត្ថសូត្រទី ៦

# អ ដ្ឋ ក ថា

## បឋមគេលញ្ញសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***បឋមគេលញ្ញសូត្រទី ៧*** *ដូចតទៅនេះ ៖*

*[១៦] បទថា* ***ស្ដេចយាងចូលទៅកាន់គិលានសាលា (យេន គិលានសាលា តេនុបសង្កមិ)*** *សេចក្ដីថា ព្រះមានព្រះភាគទ្រង់ត្រិះរិះថា ភិក្ខុទាំងឡាយគិតថា សូម្បីតថាគត ដែលជាបុគ្គលកំពូលក្នុងលោកព្រមទាំងទេវលោក ស្ដេចនៅទៅកាន់ទីឧបដ្ឋាកអ្នកជម្ងឺ ពួកភិក្ខុឈឺ ឈ្មោះថា គួរដល់ភិក្ខុដែលគប្បីរក្សា គួរកាន់យកហើយ នឹងសម្គាល់ពួកភិក្ខុឈឺ ដែលភិក្ខុគួរទំនុកបម្រុង ដូច្នេះ ។ មួយទៀត ភិក្ខុពួកណា ជាអ្នកមានកម្មដ្ឋានជាទីសប្បាយ ក្នុងទីនោះ តថាគតនឹងប្រាប់កម្មដ្ឋានដល់ភិក្ខុពួកនោះ ដូច្នេះ ទើបស្ដេចយាងចូលទៅរក ។*

*[១៧] ខ្ញុំនឹងពោលបទ ដែលលោកពោលទុកក្នុងបទជាដើមថា* ***រមែងជាអ្នកមានប្រក្រតីឃើញកាយក្នុងកាយ (កាយេ កាយានុបស្សី)*** *នោះខាងមុខ ។*

*[១៨] បទថា* ***អនិច្ចានុបស្សី*** *គឺ ពិចារណាឃើញការមិនទៀង ។ បទថា* ***វយានុបស្សី*** *គឺ ពិចារណាឃើញសេចក្ដីវិនាស ។ បទថា* ***វិរាគា-***

នុបស្សី គឺ ពិចារណាឃើញការប្រាសចាកតម្រេក ។ បទថា និរោធានុបស្សី គឺ ពិចារណាឃើញសេចក្តីរលត់ ។ បទថា បដិនិស្សគ្គានុបស្សី គឺ ពិចារណាឃើញនូវការលះបង់ ។

សួរថា ហេតុអ្វី ព្រះមានព្រះភាគ ទ្រង់សម្តែងដោយពាក្យមានប្រមាណប៉ុណ្ណេះ? ។

ឆ្លើយថា វត្តបដិបត្តិជាគ្រឿងសម្រេចរបស់ភិក្ខុនេះ សូម្បីសតិប្បដ្ឋានរមែងជាចំណែកខាងដើមតែម្យ៉ាង ។ អនុបស្សនា ៣ ទាំងនេះ គឺ អនិច្ចានុបស្សនា វយានុបស្សនា វិរាគានុបស្សនា សូម្បីក្នុងសម្បជញ្ញៈ រមែងជាចំណែកខាងដើមតែម្យ៉ាង ។ និរោធានុបស្សនា សូម្បីបដិនិស្សគ្គានុបស្សនាទាំង ២ នេះ រមែងជាមិស្សកៈ (លាយគ្នា) ។ ព្រះមានព្រះភាគទ្រង់សម្តែងដល់វេលាភាវនាចំពោះភិក្ខុនេះ ដោយហេតុប្រមាណប៉ុណ្ណេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយទាំងនោះឯង ។

ចប់អដ្ឋកថា បឋមគេលញ្ញសូត្រទី ៧

# អ ដ្ឋ ក ថា

## ទុតិយគេលញ្ញសុត្រទី ៨

[២៦] គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយគេលញ្ញសូត្រទី ៨ ដូចតទៅនេះ ៖

[២៧] កាលព្រះអង្គត្រាស់ថា ឥមមេវ ផស្សំ បដិច្ច ដូច្នេះ ព្រះអង្គត្រាស់ដោយអធ្យាស្រ័យសម្រាប់បណ្ឌិតទាំងឡាយ ។ តែពោលដោយអត្ថនោះ មិនមានហេតុដែលផ្សេងៗ គ្នាទេ ។ ការពិត កាយប៉ុណ្ណោះ ត្រាស់ថាផស្សៈ ក្នុងទីនេះ ។

ចប់អដ្ឋកថា ទុតិយគេលញ្ញសូត្រទី ៨

# អ ដ្ឋ ក ថា

## អនិច្ចសូត្រទី ៩

[៣០] *សូត្រទី ៩ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា អនិច្ចសូត្រទី៩

# អ ដ្ឋ ក ថា

## ផស្សមូលកសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង ផស្សមូលកសូត្រទី ១០ ដូចតទៅនេះ ៖

[៣១] បទថា *សុខវេទនីយំ* បានដល់ ផស្សៈជាបច្ច័យនៃសុខ-វេទនា ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះនុ៎ះឯង ចំណែកក្នុងសេចក្តីនេះ ការពណ៌នាតាមលំដាប់បទ លោកពោលពិស្តារទុកហើយក្នុងខាងក្រោយ ។ ក្នុងពីរសូត្រនេះ ត្រាស់ដល់វេទនាដែលប្រព្រឹត្តទៅក្នុងការពិចារណា ។

ចប់អដ្ឋកថា ផស្សមូលកសូត្រទី ១០

## ចប់បឋមកសតាថវគ្គទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

| | |
|---|---|
| ១-អដ្ឋកថា សមាធិសូត្រ | ២-អដ្ឋកថា សុខសូត្រ |
| ៣-អដ្ឋកថា បហានសូត្រ | ៤-អដ្ឋកថា បាតាលសូត្រ |
| ៥-អដ្ឋកថា ទដ្ឋព្វសូត្រ | ៦-អដ្ឋកថា សល្លត្តសូត្រ |
| ៧-អដ្ឋកថា បឋមគេលញ្ញសូត្រ | ៨-អដ្ឋកថា ទុតិយគេលញ្ញសូត្រ |
| ៩-មិនមានអដ្ឋកថា អនិច្ចសូត្រ | ១០-អដ្ឋកថា ផស្សមូលកសូត្រ |

# រហោគតវគ្គទី ២

## អ ដ្ឋ ក ថា

### រហោគតសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង រហោគតសូត្រទី ១ នៃ រហោគតវគ្គ ដូចតទៅនេះ ៖

[៣៣] បទថា **ការសោយអារម្មណ៍ណានីមួយជាទុក្ខ (យង្កិញ្ចិ វេទយិតំ តំ ទុក្ខស្មិំ)** សេចក្តីថា ការសោយអារម្មណ៍យ៉ាងណាមួយនោះ ទាំងអស់ជាទុក្ខ ។ ក្នុងបទថា **សង្ខារទាំងឡាយនេះឯង មិនទៀង (សង្ខារានំយេវ អនិច្ចតំ)** ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងថា សភាពនៃសង្ខារទាំងឡាយមិនទៀង មានការអស់ទៅ សាបសូន្យទៅ ប្រែប្រួលទៅជាធម្មតា យ៉ាងនេះតថាគតសំដៅដល់ប្រការនេះ ទើបពោលថា ការសោយអារម្មណ៍ណានីមួយនោះជាទុក្ខ អធិប្បាយថា វេទនាទាំងពួងជាទុក្ខ ដោយបំណងនេះថា ព្រោះថាសង្ខារទាំងឡាយមិនទៀង សូម្បីវេទនាទាំងឡាយ ក៏មិនទៀងដូចគ្នា ។ ក៏ឈ្មោះថា សេចក្តីមិនទៀងនេះ ជាមរណៈ ឈ្មោះថា សេចក្តីទុក្ខក្រៃលែង

ជាឯមរណៈរមែងមិនមាន ដូច្នេះ ។

[៣៤] បទថា ម្នាលភិក្ខុ លំដាប់នោះឯង តថាគត (អថខោ បន ភិក្ខុ មយា) នេះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធដើម្បីសម្តែងថា តថាគតបញ្ញត្តិសេចក្តីរលត់នៃវេទនាតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន តថាគតបញ្ញត្តិសេចក្តីរលត់នៃធម៌សូម្បីទាំងនេះផង ។ ត្រាស់សេចក្តីស្ងប់ និងសេចក្តីរម្ងាប់ តាមអធ្យាស្រ័យរបស់បុគ្គលជាបណ្ឌិត ដោយទេសនាបែបនេះ ។ គប្បីជ្រាបថា អរូបឈាន ៤ លោកកាន់យកហើយក្នុងទីនេះ ដោយសញ្ញាវេទយិតនិរោធ ស័ព្ទ ។

ចប់អដ្ឋកថា រហោគតសូត្រទី ១

# អ ដ្ឋ ក ថា

## បឋមវាតសូត្រទី ២

[៣៧] គប្បីជ្រាបវិនិច្ឆ័យក្នុង *បឋមវាតសូត្រទី ២* ដូចតទៅនេះ ៖

[៣៨] បទថា *ខ្យល់ច្រើនយ៉ាងបក់ទៅ (បុថូ វាយន្តិ មាលុតា)* បានដល់ ខ្យល់ច្រើនយ៉ាងរមែងបក់ទៅ ។ ពាក្យដ៏សេស មានសេចក្តីងាយទាំងអស់ ។

ចប់អដ្ឋកថា បឋមវាតសូត្រទី ២

# អ ដ្ឋ ក ថា

## ទុតិយវាតសូត្រទី ៣

[៣៩] គប្បីជ្រាបវិនិច្ឆ័យក្នុង *ទុតិយវាតសូត្រទី ៣* ដូចតទៅនេះ ៖

*វៀរគាថាទាំងឡាយចេញ ព្រះមានព្រះភាគត្រាស់តាមអជ្ឈាស្រ័យរបស់បុគ្គលដែលជាបណ្ឌិតហើយ ។*

ចប់អដ្ឋកថា ទុតិយវាតសូត្រទី ៣

# អ ដ្ឋ ក ថា

## អគារសុត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុងនិវាសសូត្រទី ៤ ដូចតទៅនេះ ៖*

*[៤០] បទថា **បុរត្ថិមា** គឺ ក្នុងទិសខាងកើត ។ ក្នុងបទទាំងពួងក៏ដូច្នេះ ។*

*ក្នុងបទជាដើមថា **សុខវេទនាប្រកបដោយអាមិសខ្លះ (សាមិសាបិ សុខា វេទនា)** សុខវេទនា ដែលប្រកបដោយអាមិស គឺ កាម ឈ្មោះថា **សុខមានអាមិស** វេទនា ដែលកើតឡើងដោយអំណាចនៃឈានទាំងឡាយមានបឋមជ្ឈានជាដើម ដោយអំណាចនៃវិបស្សនា និងដោយអំណាចនៃអនុស្សតិ ឈ្មោះថា **សុខមិនមានអាមិស** ។ ទុក្ខវេទនាប្រកបដោយអាមិស ដោយអាមិស គឺ កាម ឈ្មោះថា **ទុក្ខមានអាមិស** ។ ទោមនស្សវេទនា ដែលកើតឡើងដល់ភិក្ខុ ដែលញ៉ាំងសេចក្តីប្រាថ្នាឲ្យចូលទៅតាំងទុក ក្នុងវិមោក្ខដ៏កំពូល (អនុត្តរវិមោក្ខ) ព្រោះសេចក្តីប្រាថ្នាជាបច្ច័យ ឈ្មោះថា **ទុក្ខមិនមានអាមិស** ។ វេទនាមានអាមិស ដោយអំណាចអាមិស គឺ កាម ឈ្មោះថា **អទុក្ខមសុខដែលមានអាមិស** ។ អទុក្ខមសុខវេទនា ដែលកើត*

ឡើងដោយអំណាចចតុត្ថជ្ឈាន ឈ្មោះថា **អទុក្ខមសុខដែលមិនមានអាមិស** ។

៤ សូត្រ មានសូត្រទី ៥ ជាដើមទៅ មានន័យដូចពោលទុកហើយក្នុងខាងក្រោយ ។ ចំណែកក្នុងសេចក្តីនេះ ពីរសូត្រដំបូង ប្រកបដោយបសទ្ធិបរិបូណ៌ ។ ពីរសូត្រក្រោយ ប្រកបដោយបសទ្ធិពាក់កណ្តាល ។ ព្រះមានព្រះភាគត្រាស់ហើយ តាមអធ្យាស្រ័យរបស់បុគ្គលជាបណ្ឌិតដោយទេសនា ។

ចប់អដ្ឋកថា អគារសូត្រទី ៤

# អ ដ្ឋ ក ថា

## បញ្ចកង្គសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង **បញ្ចកង្គសូត្រទី ៩** ដូចតទៅនេះ ៖

[៥១] បទថា **បញ្ចកង្គោ** ក្នុងបទថា **ជាងឈើឈ្មោះបញ្ចកង្គៈ (បញ្ចកង្គោ ថបតិ)** ជាឈ្មោះរបស់ជាងឈើនោះ មួយទៀត ជាងឈើនោះប្រាកដឈ្មោះថា បញ្ចកង្គៈ ព្រោះប្រកបដោយអង្គ ៥ ពោលគឺ កាំបិត ពូថៅ ពន្លាក ញញួរ ប្រអប់ជ្រលក់ខ្សែបន្ទាត់ ។ បទថា **ថបតិ** គឺ ជាងឈើដែលជាមេជាង ។ បទថា **ឧទាយិ** គឺ ព្រះឧទាយីត្ថេរដែលបណ្ឌិត ។

[៥៣] បទថា **បរិយាយំ** គឺ ហេតុ ។

[៥៤] បទថា **ទ្វេបានន្ទ**[១] គឺ ម្នាលអានន្ទ វេទនា ២ ក៏មាន ។ បទថា **ដោយបរិយាយ (បរិយាយេន)** គឺ ដោយហេតុ ។ ចំណែកក្នុងទីនេះគប្បីជ្រាប **វេទនា ២** ដោយអំណាចផ្លូវកាយ និងផ្លូវចិត្ត ។ សូម្បី **វេទនា ៣** ដោយអំណាចសុខជាដើម ។ **វេទនា ៥** មានសុខិន្ទ្រិយជាដើម ដោយអំណាចឥន្ទ្រិយ ។ **វេទនា ៦** មានចក្ខុសម្ផស្សជា ជាដើមដោយអំណាចទ្វារ ។

---

១-បាលីបិដកថា “ ទ្វេបិ មយា អានន្ទ ” ។

**វេទនា ១៨** មានជាដើមថា ឃើញរូបដោយចក្ខុហើយ រមែងគិតនូវរូប ដែលជាទីតាំងនៃសោមនស្សដោយអំណាចការគិត ។ គប្បីជ្រាប **វេទនា ៣៦** គឺ សោមនស្សអាស្រ័យផ្ទះ ៦ , អាស្រ័យនេក្ខម្ម: (ការចេញចាកកាម) ៦ , ទោមនស្សអាស្រ័យផ្ទះ ៦ , អាស្រ័យនេក្ខម្ម: (ការចេញចាកកាម) ៦ , ឧបេក្ខាអាស្រ័យផ្ទះ ៦ , អាស្រ័យនេក្ខម្ម: (ការចេញចាកកាម) ៦ ។ គប្បីជ្រាប **វេទនា ១០៨** យ៉ាងនេះ គឺ វេទនាទាំងនោះ ក្នុងអតីតមាន ៣៦ ។ ក្នុងអនាគតមាន ៣៦ ។ ក្នុងបច្ចុប្បន្នមាន ៣៦ ។

[៥៥] បទថា **អានន្ទ កាមគុណ ៥ ទាំងនេះ (បញ្ចិមេ អានន្ទ កាមគុណា)** នេះ ជាអនុសន្ធិ (ការសរុប) ចំពោះមួយយ៉ាង ។ ដែលពិតព្រះមានព្រះភាគទ្រង់ធ្វើវេទនា ២ ឲ្យជាខាងដើម ទ្រង់បញ្ញត្តិវេទនាតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ។ ដោយបរិយាយ ត្រាស់វេទនាតែម្យ៉ាងក៏មាន កាលនឹងទ្រង់សម្តែងវេទនានោះ ទើបទ្រង់ផ្តើមទេសនានេះ ដើម្បីសរសើរវាទ: របស់ជាងឈើ ឈ្មោះបញ្ចកង្គ: ។

[៥៦] បទថា **ដែលគួរប្រាថ្នាដ៏ក្រៃលែង (អភិក្កន្តតរំ)** គឺ ល្អជាង ។ បទថា **ប្រណីតជាង (បណីតតរំ)** គឺ ថ្លៃថ្លាជាង ។ ក្នុងសេចក្តីនេះ **អទុក្ខមសុខវេទនា** លោកពោលថា សុខ ដោយអត្ថថា ស្ងប់ និងប្រណីត ផ្តើម

តាំងពីចតុត្ថជ្ឈាន ។ **និរោធ** ឈ្មោះថា ជាសុខ ដោយអំណាចសុខមិនបាន សោយអារម្មណ៍ ។ ព្រោះថា ឈ្មោះថា សុខដែលសោយអារម្មណ៍កើតឡើង ហើយ ដោយអំណាចកាមគុណ ៥ និងដោយអំណាចសមាបត្តិ ៨ ។ និរោធ ឈ្មោះថា សុខ ដែលមិនបានសោយអារម្មណ៍ ។ **សុខ ដែលសោយអារម្មណ៍ ក៏ដោយ មិនបានសោយអារម្មណ៍ក៏ដោយ ក៏ឈ្មោះថា សុខ ដោយចំណែក តែមួយ ដោយអត្ថថា ជាសុខ ពោលគឺ ការមិនមានទុក្ខ ។**

[៦៦] បទថា **យត្ថ យត្ថ** គឺ ក្នុងឋានៈណា ។ បទថា **រមែងបាន សុខ (សុខំ ឧបលព្ភតិ)** សេចក្តីថា បុគ្គលរមែងបានសុខដោយការសោយ អារម្មណ៍ ឬសុខដែលមិនបានសោយអារម្មណ៍ ព្រះតថាគតរមែងបញ្ញត្តិសុខ នោះៗ ចុះក្នុងសុខ ។ ព្រះតថាគតរមែងបញ្ញត្តិសុខទាំងអស់នោះ ដោយការ មិនមានសេចក្តីទុក្ខក្នុងសុខប៉ុណ្ណោះ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើនិរោធ- សមាបត្តិឲ្យជាប្រធានក្នុងទីនេះ ហើយទើបទ្រង់ញ៉ាំងទេសនាឲ្យចប់ស្រេច ដោយធម៌ដ៏កំពូល គឺ ព្រះអរហត្តតែម្តង ដោយអំណាចនៃបុគ្គលដែលល្មម ណែនាំបាន ។

ចប់អដ្ឋកថា បញ្ចកង្គសូត្រទី ៩

# អ ដ្ឋ ក ថា

## ភិក្ខុសូត្រទី ១០

[៦៧] *សូត្រទី ១០ មានសេចក្ដីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ភិក្ខុសូត្រទី ១០

## ចប់រោគតវគ្គទី ២

### រួមក្នុងវគ្គនេះមាន ៥ អដ្ឋកថា

១-អដ្ឋកថា រោគតសូត្រ
២-អដ្ឋកថា បឋមវាតសូត្រ
៣-អដ្ឋកថា ទុតិយវាតសូត្រ
៤-អដ្ឋកថា អគារសូត្រ
៥-អដ្ឋកថា បញ្ញាកន្ថសូត្រ

# អដ្ឋសតបរិយាយវគ្គទី ៣

## អ ដ្ឋ ក ថា

### សិវកសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សិវកសូត្រទី ១** នៃ **វគ្គទី ៣** ដូចតទៅនេះ ៖*

*[៦៩] បទថា **សិវកោ** ក្នុងបទថា **មោឡិយសិវកោ** ជាឈ្មោះរបស់បរិព្វាជកនោះ ។ បរិព្វាជកនោះមានជុកនៅត្រង់សីសៈ ព្រោះដូច្នោះ គេទើបហៅថា សិវកៈ បរិព្វាជកមានជុក ។*

*បទថា **បរិព្វាជកោ** បានដល់ បរិព្វាជកអ្នកស្លៀកសំពត់ ។ បទថា **មានប្រមាត់ជាសមុដ្ឋាន (បិត្តសមុដ្ឋានានិ)** បានដល់ មានប្រមាត់ជាបច្ច័យ ។ បទថា **វេទយិតានិ** គឺ វេទនា ។ វេទនា ៣ រមែងកើតឡើងក្នុងបុគ្គលនោះព្រោះប្រមាត់ជាបច្ច័យ ។*

*សួរថា ដូចម្តេច? ។*

*ឆ្លើយថា ពិតហើយ បុគ្គលខ្លះគិតថា ប្រមាត់របស់យើងកម្រើកហើយ ឯជីវិតយើងដឹងបានលំបាក រមែងឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ។*

កុសលវេទនា រមែងកើតឡើងដល់បុគ្គលខ្លះនោះ ដោយអាការយ៉ាងនេះ ។ ចំណែកបុគ្គលខ្លះ គិតថា យើងនឹងធ្វើភេសជ្ជៈព្យាបាលប្រមាត់ រមែងសម្លាប់សត្វ លួចទ្រព្យ និយាយកុហក រមែងទ្រុស្តសីលកម្ម ១០ ក៏មាន ។ អកុ-សលវេទនា រមែងកើតឡើងដល់បុគ្គលខ្លះនោះ ដោយអាការយ៉ាងនេះ ។ តែបុគ្គលខ្លះ មានខ្លួនជាកណ្តាលថា ប្រមាត់របស់យើង រមែងមិនស្ងប់ដោយការធ្វើថ្នាំសូម្បីប្រមាណប៉ុណ្ណេះ រឿងថ្នាំនោះល្មមហើយ រមែងដេកអត់ទ្រាំនូវវេទនាផ្លូវកាយ ។ អព្យាកតវេទនា រមែងកើតឡើងដល់បុគ្គលខ្លះនោះ ដោយអាការយ៉ាងនេះ ។

បទថា **ប្រការដែល...គប្បីជ្រាបបានដោយខ្លួនឯងយ៉ាងនេះ (សាមំបិ ខោ ឯតំ)** សេចក្តីថា បុគ្គលឃើញវិការនៃប្រមាត់នោះៗ ហើយ ក៏គប្បីជ្រាបវេទនានោះបានដោយខ្លួនឯង ។ បទថា **លោកសន្មតថាជារបស់ពិត (សច្ច-សម្មតំ)** គឺ សម្មតិថាពិត ចំណែកមនុស្សលោក ឃើញវិការនៃប្រមាត់មានវណ្ណៈសៅហ្មងជាដើមត្រង់សរីរៈរបស់គេហើយ រមែងដឹងថា ប្រមាត់របស់គេកម្រើក ។ បទថា **ព្រោះដូច្នោះ (តស្មា)** សេចក្តីថា ព្រោះស្មុះទៅកាន់វត្ថុដែលដឹងដោយខ្លួនឯង និងស្មុះទៅកាន់វត្ថុដែលសន្មតិគ្នាថា ជារបស់ពិតក្នុងលោក ។ សូម្បីក្នុងបទ មានសេម្ហៈ (សេ្ហស្មា) ជាសមុដ្ឋានជាដើម ក៏ន័យ

នេះដូចគ្នា ។ ចំណែកបទថា **រួមគ្នា (សន្និបាតិកានិ)** ក្នុងបទថា **រួមគ្នាជាសមុដ្ឋាន (សន្និបាតសមុដ្ឋានានិបិ)** នេះ កើតឡើងហើយ ព្រោះការកម្រើកនៃប្រមាត់ជាដើមសូម្បីទាំងបី ។ បទថា **កើតពីការប្រែប្រួលនៃរដូវ (ឧតុបរិណាមជានិ)** គឺ កើតពីការប្រែប្រួលនៃរដូវ រមែងកើតឡើងដល់អ្នកស្រុកជង្គលទេស កាលនៅក្នុងអនុប្រទេស ។ សេចក្តីប្រែប្រួលរដូវ រមែងកើតឡើងដោយអំណាច មានត្រើយមណីសមុទ្រជាដើមយ៉ាងនេះថា កាលអ្នកស្រុកអនុប្រទេសរស់នៅក្នុងជង្គលទេស ។ បទថា **តតោ ជាតា** បានដល់ កើតពីការប្រែប្រួលនៃរដូវ ។

បទថា **កើតពីការរក្សាឥរិយាបថមិនស្មើ (វិសមបរិហារជានិ)** សេចក្តីថា កើតពីការរក្សាខ្លួនមិនស្មើក្នុងការទទួលភារៈធ្ងន់ ដោយមានការវាយដំជាដើម ។ ឬកាលត្រាច់ទៅខុសវេលា ដោយមានការត្រូវពស់ខាំ និងធ្លាក់អន្លង់ជាដើម ។ បទថា **កើតពីការប្រទូស្ត (ឱបក្កមិកានិ)** សេចក្តីថា កើតឡើងព្រោះគិតថា អ្នកនេះជាចោរ ឬជាទារិការបស់អ្នកដទៃ ហើយទើបប្រទូស-រ៉ាយ ដោយការយកជន្ទល់ កែងដៃ និងដំបងជាដើម វាយឲ្យជាបច្ច័យ ។ បុគ្គលខ្លះ ត្រូវប្រទូសរ៉ាយពីខាងក្រៅនោះហើយ រមែងធ្វើកុសល ដោយន័យដែលពោលហើយនោះឯង ។ បុគ្គលខ្លះធ្វើអកុសល ។ បុគ្គលខ្លះរមែងដេក

អត់ទ្រាំ ។ បទថា **កើតពីផលរបស់កម្ម (កម្មវិបាកជាតានិ)** គឺ កើតពីផលរបស់កម្មតែម្យ៉ាង ។ ក៏កាលកម្មវិបាកទាំងនោះ កើតឡើងហើយ បុគ្គលខ្លះរមែងធ្វើកុសល បុគ្គលខ្លះរមែងធ្វើអកុសល បុគ្គលខ្លះរមែងដេកអត់ទ្រាំ ។ ក៏វេទនា ៣ យ៉ាង រមែងមានក្នុងវារៈទាំងពួងយ៉ាងនេះ ។ ក្នុងវេទនាទាំងនោះ វេទនាដែលប្រព្រឹត្តទៅក្នុងសរីរៈ ដែលកើតឡើងដោយហេតុ ៧ យ៉ាងខាងដើម នរណាៗ ក៏អាចដើម្បីនឹងហាមបាន អំពីភេសជ្ជទាំងពួងក្តី គ្រឿងការពារក្តី តែមិនអាចដើម្បីកម្ចាត់វេទនា ដែលកើតអំពីផលរបស់កម្មបានឡើយ ។ ឈ្មោះថា លោកវោហារ ព្រះអង្គបានត្រាស់ហើយក្នុងព្រះសូត្រនេះ ។

ចប់អដ្ឋកថា សិវកសូត្រទី ១

# អ ដ្ឋ ក ថា

## អដ្ឋសតបរិយាយសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង អដ្ឋសតបរិយាយសូត្រទី ២ ដូចតទៅនេះ ៖*

*[៧២] បទថា ដែលមានបរិយាយផ្សេងៗ ១០៨ (អដ្ឋសតបរិយាយំ) គឺ ជាហេតុ ១០៨ ។ បទថា ធម្មបរិយាយ (ធម្មបរិយាយំ) គឺ ហេតុនៃធម៌ ។*

*[៧៣] ក្នុងបទថា វេទនាផ្លូវកាយ និងវេទនាផ្លូវចិត្ត (កាយិកា ច ចេតសិកា ច) នេះ វេទនាផ្លូវកាយ រមែងមានក្នុងកាមាវចរប៉ុណ្ណោះ ។ វេទនាផ្លូវចិត្ត ក៏ប្រព្រឹត្តទៅក្នុងភូមិ ៤ ។*

*[៧៤] សុខវេទនា ក្នុងបទជាដើមថា សុខា រមែងមិនមានអរូបាវចរៈ តែរមែងមានក្នុងភូមិ ៣ ដ៏សេស ។ ទុក្ខវេទនា ចាត់ជាកាមាវចរៈ ។ វេទនាក្រៅពីនេះ ក៏ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ក្នុងពួក ៥ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ ចាត់ជាកាមាវចរៈ ។ សោមនស្សិន្ទ្រិយ ប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ឧបេក្ខិន្ទ្រិយ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ក្នុងពួក ៦ វេទនាក្នុងទ្វារ ៥ ចាត់ជាកាមាវចរៈ ។ វេទនាក្នុងមនោទ្វារ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ក្នុង*

ពួក ១៨ ក្នុងអារម្មណ៍ដែលគួរប្រាថ្នា ៦ ឈ្មោះថា សោមនស្សុបវិចារៈ ព្រោះអត្ថថា រមែងចូលទៅត្រិះរិះរួមជាមួយសោមនស្ស ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ទេសនានេះ មកហើយដោយអំណាចនៃវិចារៈ ដោយប្រការដូច្នេះ ។ តែគប្បីជ្រាបវេទនា ១៨ ក្នុងទីនេះ ដោយអំណាចនៃសោមនស្សជាដើម ដែលសម្បយុត្តដោយវិចារៈនោះ ។

[៧៨] គប្បីជ្រាបក្នុងបទជាដើមថា **សោមនស្សអាស្រ័យផ្ទះ ៦ (ឆ គេហសិតានិ សោមនស្សានិ)** សេចក្ដីថា សោមនស្សអាស្រ័យកាមគុណ ដែលលោកពោលហើយក្នុងទ្វារ ៦ យ៉ាងនេះថា “កាលវព្ធកដល់ការបាន ដោយការបាននៃរូបដែលគប្បីដឹងដោយចក្ខុ ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត គួររីករាយនៃចិត្ត ដែលប្រកបដោយលោកាមិស ឬកាលបើរព្ធកដល់វត្ថុដែលកន្លងទៅហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយ ដែលខ្លួនធ្លាប់បានហើយក្នុងអតីត សោមនស្ស ក៏រមែងកើតឡើង ។ សោមនស្សបែបនេះ លោកហៅថា **គេហសិតសោមនស្ស** (សោមនស្សអាស្រ័យផ្ទះ)” ឈ្មោះថា សោមនស្សអាស្រ័យផ្ទះ ៦ ។

កាលញ៉ាំងសេចក្ដីខ្វល់ខ្វាយ ផ្ដើមវិបស្សនា ដោយអំណាចសេចក្ដីមិនទៀងជាដើម កើតសោមនស្សថា វិបស្សនាដែលយើងខ្វល់ខ្វាយហើយ

ដូច្នេះ សោមនស្សកើតឡើងហើយ ក្នុងកាលអារម្មណ៍ដែលគួរប្រាថ្នា ទៅប្រាកដក្នុងទ្វារ ៦ យ៉ាងនេះថា “ក៏កាលដឹងច្បាស់ថា រូបទាំងឡាយមិនទៀង ក៏ពិចារណាឃើញនូវសេចក្ដីប្រែប្រួល ប្រាសចាកតម្រេក និងរលត់ បានដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិតនោះ យ៉ាងនេះថា រូបទាំងឡាយក្នុងអតីតក្ដី ក្នុងបច្ចុប្បន្នក្ដី រូបទាំងពួងនោះ ក៏មិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ដូច្នេះ សោមនស្សក៏រមែងកើតឡើង ។ សោមនស្សបែបនេះ លោកហៅថា **នេក្ខម្មសិតសោមនស្ស** (សោមនស្សអាស្រ័យការចេញចាកកាម)” ឈ្មោះថា សោមនស្សអាស្រ័យការចេញចាកកាម ៦ ។

ទោមនស្សអាស្រ័យកាមគុណ ដែលកើតឡើងហើយដល់អ្នកត្រិះរិះថា យើងនឹងមិនសោយ នឹងមិនសោយអារម្មណ៍ ដែលគួរប្រាថ្នាដូច្នេះ ក្នុងទ្វារ ៦ យ៉ាងនេះថា “កាលពិចារណាឃើញដល់ការមិនបាន ដោយការមិនបាននៃរូបទាំងឡាយ គប្បីដឹងដោយចក្ខុ ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត គួររីករាយនៃចិត្ត ដែលប្រកបដោយលោកាមិស ឬកាលពិចារណាឃើញនូវវត្ថុដែលកន្លងទៅហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយ ដែលខ្លួនមិនទាន់ជាប់បានហើយក្នុងអតីត ទោមនស្សក៏រមែងកើតឡើង ទោមនស្សបែបនេះ លោកហៅថា **គេហសិតទោមនស្ស** (ទោមនស្សអាស្រ័យការនៅគ្រប់

គ្រងផ្ទះ)” ឈ្មោះថា ទោមនស្សអាស្រ័យការនៅគ្រប់គ្រងផ្ទះ ៦ ។

ចំណែកភិក្ខុដែលដឹងច្បាស់ថា រូបទាំងឡាយមិនទៀង ឃើញនូវការប្រែប្រួល ប្រាសចាកតម្រេក និងរលត់ ដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិតនោះ រូបទាំងឡាយក្នុងអតីតក្ដី ក្នុងបច្ចុប្បន្នក្ដី រូបទាំងអស់នោះក៏មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា ដូច្នេះ រមែងញ៉ាំងសេចក្ដីព្យាយាមឲ្យចូលទៅតាំងមាំក្នុងវិមោក្ខដ៏កំពូលថា កាលណាយើងនឹងចូលអាយតនៈ (ហេតុឲ្យចិត្តរួចផុត) ដែលព្រះអរិយៈទាំងឡាយរមែងចូលហើយ ដូច្នេះ ។ ដោយអាការយ៉ាងនេះ កាលលោកញ៉ាំងសេចក្ដីព្យាយាម ឲ្យចូលទៅតាំងនៅក្នុងវិមោក្ខដ៏កំពូល ទោមនស្សក៏រមែងកើតឡើង ព្រោះសេចក្ដីព្យាយាមជាបច្ច័យ ។ ទោមនស្សបែបនេះ លោកហៅថា **នេក្ខម្មសិតទោមនស្ស** (ទោមនស្សអាស្រ័យការចេញចាកកាម) កាលបើអារម្មណ៍ដែលគួរប្រាថ្នាទៅប្រាកដក្នុងទ្វារ ៦ យ៉ាងនេះ ទោមនស្សក៏កើតឡើងហើយដល់លោកអ្នកញ៉ាំងសេចក្ដីព្យាយាមឲ្យចូលទៅតាំងទុកក្នុងធម៌ គឺ អរិយផល ពោលគឺអនុត្តរវិមោក្ខ តែក៏មិនញ៉ាំងសេចក្ដីខ្វល់ខ្វាយ ផ្ដើមវិបស្សនាដោយអំណាចនៃសេចក្ដីមិនទៀងជាដើម ដើម្បីបានសម្រេចអរិយផលធម៌នោះ ទើបចេញដោយសភាពមិនខ្វល់ថា យើងមិនអាចនឹងខ្វល់ខ្វាយដល់វិបស្សនា ហើយ

សម្រេចអរិយភូមិបាន ទាំងក្នុងបក្ខនេះ ទាំងខែនេះ ទាំងឆ្នាំនេះ ឈ្មោះថា **នេក្ខម្មសិតទោមនស្ស** (ទោមនស្សអាស្រ័យការចេញចាកកាម) ៦ ។

កាលអារម្មណ៍ដែលគួរប្រាថ្នាចូលទៅប្រាកដក្នុងទ្វារ ៦ យ៉ាងនេះថា ពាលបុថុជ្ជនអ្នកឈ្លក់វង្វេង គឺ បុគ្គលក្រាស់ **ដែលមិនទាន់កើតវិបាក** មិនឃើញទោស មិនបានស្តាប់ ឃើញរូបដោយចក្ខុហើយ ឧបេក្ខាក៏រមែងកើតឡើង ឧបេក្ខាបែបនេះណា ឧបេក្ខានោះ រមែងដឹងរូបមិនបាន ព្រោះដូច្នោះ ឧបេក្ខានោះ លោកហៅថា **គេហសិតឧបេក្ខា** (ឧបេក្ខាអាស្រ័យផ្ទះ) ដូច្នេះ ។ ឧបេក្ខា អាស្រ័យកាមគុណកើតឡើងហើយ កាលកន្លងរូបជាដើមមិនបាន ដូចជារុយក្បាលខៀវ កន្លងទឹកអំពៅទៅមិនបាន ដូច្នោះ ក៏ត្រូវជាប់នៅក្នុងរូបនោះឯង ។ ឈ្មោះថា គេហសិតឧបេក្ខា (ឧបេក្ខាអាស្រ័យផ្ទះ ៦) ។

ឧបេក្ខាសម្បយុត្តដោយញាណ ដែលជាវិបស្សនាកើតឡើងហើយ ដល់អ្នកមិនរីករាយក្នុងអារម្មណ៍ដែលគួរប្រាថ្នា មិនទាស់ក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា មិនវង្វេងក្នុងការសម្លឹងមើលអារម្មណ៍ដែលមិនស្មើ ។ កាលអារម្មណ៍ដែលគួរប្រាថ្នាជាដើមប្រាកដក្នុងទ្វារ ៦ យ៉ាងនេះ ហើយបានដឹងច្បាស់ថា រូបទាំងឡាយមិនទៀង ពិចារណាឃើញនូវការប្រែប្រួល ក៏ប្រាសចាកម្រេក ក៏រលត់ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតនោះ យ៉ាងនេះថា

រូបទាំងឡាយក្នុងអតីតក្តី ក្នុងបច្ចុប្បន្នក្តី រូបទាំងអស់នោះ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ដូច្នេះ ។ ឧបេក្ខា ក៏រមែងកើតឡើង ។ ឧបេក្ខាបែបនេះណា ឧបេក្ខានោះ រមែងកន្លងរូបទៅបាន ព្រោះដូច្នោះ ឧបេក្ខានោះ លោកហៅថា **នេក្ខម្មសិតឧបេក្ខា** (ឧបេក្ខាអាស្រ័យការចេញចាកកាម) ដូច្នេះ ឈ្មោះថា នេក្ខម្មសិតឧបេក្ខា (ឧបេក្ខាអាស្រ័យការចេញចាកកាម) ៦ ។ ក្នុងព្រះសូត្រនេះ ព្រះអង្គត្រាស់ការកំណត់ធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលរួបរួមធម៌ទុកទាំងអស់ ។ សូត្រទី ៣ ជាដើមទៅ មានសេចក្តីងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា អដ្ឋសតបរិយាយសូត្រទី ២

# អ ដ្ឋ ក ថា

## និរាមិសសូត្រទី ១១

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***និរាមិសសូត្រទី ១១*** *ដូចតទៅនេះ ៖*

*[៨៨] បទថា* ***មានអាមិស (សាមិសា)*** *គឺ បីតិមានអាមិស ដោយអាមិស គឺ កិលេស ។ បទថា* ***ជាងបីតិដែលមិនមានអាមិស (និរាមិសតរា)*** *សេចក្តីថា បីតិមិនប្រកបដោយអាមិស ដ៏លើសជាងបីតិក្នុងឈាន សូម្បីដែលមិនមានអាមិស ។*

*សួរថា ក្នុងឈាន ២ បីតិរមែងជាមហគ្គតៈក៏មាន រមែងជាលោកុត្តរៈក៏មាន ។ បីតិក្នុងបច្ចវេក្ខណញ្ញាណ រមែងជាលោកិយៈតែម្យ៉ាង មិនមែនឬ ព្រោះហេតុអ្វី បីតិនោះ ទើបមិនមានអាមិសដ៏លើសជាង ។*

*ឆ្លើយថា ព្រោះកើតឡើងហើយ ដោយអំណាចនៃការពិចារណានូវធម៌ដ៏ស្ងប់ និងប្រណីត ។ ដូចអ្នកនៅបម្រើ ជាបុគ្គលប្រោសប្រាណរបស់ព្រះរាជា ចូលទៅកាន់រាជត្រកូលបានតាមសប្បាយ មិនមានអ្នកណាឃាត់ឃាំង សូម្បីនឹងយកជើងជាក់សេដ្ឋី និងសេនាបតីជាដើមក៏បាន ព្រោះហេតុអ្វី ព្រោះជាអ្នកនៅបម្រើជិតរបស់ព្រះរាជា ។ ដោយហេតុនេះ អ្នកបម្រើនោះ*

រមែងជាអ្នកក្រៃលែងជាងសេដ្ឋជាដើមទាំងនោះ យ៉ាងណា បីតិសុខប្បីនេះ គប្បីជ្រាបថា ក្រៃលែងជាងសុខប្បីបីតិក្នុងលោកុត្តរៈ ព្រោះកើតឡើងហើយដោយអំណាចនៃការពិចារណាធម៌ដ៏ស្ងប់ និងប្រណីត ដូច្នោះ ។ សុខប្បីក្នុងវារៈដ៏សេស ក៏មានន័យនេះនោះឯង ។ ចំណែកក្នុងវារៈនៃវិមោក្ខ វិមោក្ខដែលប្រកបដោយរូប ឈ្មោះថា មានអាមិស ដោយអំណាចអាមិស គឺ រូបដែលជាអារម្មណ៍របស់ខ្លួន ។ ដែលមិនប្រកបដោយរូប ឈ្មោះថា មិនមានអាមិស ដោយមិនមានអាមិស គឺ រូប ។

ចប់អដ្ឋកថា និរាមិសសូត្រទី ១១

## ចប់អដ្ឋសតបរិយាយវគ្គទី ៣

### រួមក្នុងវគ្គនេះមាន ៣ អដ្ឋកថា

១-អដ្ឋកថា សិវកសូត្រ ២-អដ្ឋកថា អដ្ឋសតបរិយាយសូត្រ
៣-អដ្ឋកថា និរាមិសសូត្រ សូត្រទី ១១

# មាតុគ្រាមសំយុត្ត

## បេយ្យាលវគ្គទី ១

## អ ដ្ឋ ក ថា

### អមនាបសុត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង អមនាបសូត្រទី ១ នៃមាតុគ្រាមសំយុត្ត ដូចតទៅនេះ ៖*

[១០០] *បទថា* ***ដោយអង្គ (អង្គេហិ)*** *គឺ ដោយអង្គនៃទោស ។ បទថា* ***រូបមិនស្អាត (ន ច រូបវា)*** *សេចក្តីថា មានរូបមិនសមប្រកប ពិការរូបរាងគួរស្អប់ ។ បទថា* ***មិនមានភោគសម្បត្តិ (ន ច ភោគវា)*** *សេចក្តីថា មិនដល់ព្រមដោយភោគៈ គឺ ទ្រព្យមិនមាន ។ បទថា* ***មិនមានមារយាទ (ន ច សីលវា)*** *សេចក្តីថា អ្នកមានសីលវិបត្តិ គឺ ទ្រុស្តសីល ។ បទថា* ***ខ្ជិលច្រអូស (អលសោ ច)*** *សេចក្តីថា រមែងមិនអាចធ្វើការងារទាំងឡាយ មានការកាប់ឧស និងការដាំស្លជាដើម បុគ្គលខ្ជិលច្រអូស គាពជាអ្នកខ្ជិលច្រអូស រមែងដេកអង្គុយក្នុងទីអង្គុយខ្លះ រមែងដេកឈរក្នុងទីឈរ*

ខ្ញុំ ។ បទថា **មិនបានបុត្តដើម្បីគេ (បជញ្ចស្ស ន លភតិ)** សេចក្តីថា រមែង មិនបានបុត្រជាទីញ៉ាំងវង្សត្រកូលនៃបុរសនោះឲ្យតាំងនៅបាន រមែងឈ្មោះ ថា ស្ត្រីអារ ។ សុក្កបក្ខ (ផ្នែកល្អ) គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នា ជាមួយពាក្យដែលពោលហើយ ។ សូត្រទី ២ គប្បីឲ្យសេចក្តីផ្ទុយគ្នា ដោយ ន័យដែលពោលហើយក្នុងសូត្រទី ១ នេះ ។

ចប់អដ្ឋកថា អមនាបសូត្រទី ១

# អ ដ្ឋ ក ថា

## អាវេណិកសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាវេណិកសូត្រទី ៣ ដូចតទៅនេះ ៖*

*[១០៤] បទថា ចំពោះ (អាវេណិកានិ) សេចក្ដីថា ទុក្ខចំពោះបុគ្គល គឺ មិនទូទៅដោយពួកបុរស ។*

*[១០៨] បទថា ភាពជាស្ត្រីបម្រើ (បារិចរិយំ) គឺ មាតុគ្រាម រមែងចូលដល់ភាពជាស្ត្រីបម្រើ ។*

ចប់អដ្ឋកថា អាវេណិកសូត្រទី ៣

# អ ដ្ឋ ក ថា

## មាតុគ្រាមសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង* **មាតុគ្រាមសូត្រទី ៤** *ដូចតទៅនេះ ៖*

[១០៩] *បទថា* **ដែលមន្ទិល** *គឺ សេចក្តីកំណាញ់រួបរឹត (មច្ឆេរមលបរិយុដ្ឋិតេន) សេចក្តីថា ក៏ក្នុងវេលាព្រឹក មាតុគ្រាមប្រារព្ធដើម្បីនឹងធ្វើការងារដែលមានកង្វល់នៅក្នុងទឹកដោះ ទឹកដោះជូរ និងការដាំស្លដាដើម ស្លម្បីបុត្រតូចទាំងឡាយស្រែកសូមហើយ រមែងមិនប្រាថ្នាដើម្បីនឹងឲ្យអ្វី ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យនោះថា វេលាព្រឹក មានចិត្តដែលមន្ទិល គឺ សេចក្តីកំណាញ់រួបរឹតហើយ ។ ចំណែកវេលាថ្ងៃត្រង់ មាតុគ្រាម រមែងត្រូវសេចក្តីក្រោធគ្របសង្កត់ ។ កាលមិនបានឈ្លោះគ្នាខាងក្នុងផ្ទះ ក៏រមែងធ្វើការឈ្លោះគ្នាក្នុងផ្ទះរបស់ជនដែលនៅជិតខាងគ្នា និងរមែងដើរទៅរមិលមើលទីឈរ និងទីអង្គុយរបស់ស្វាមី ។ ដោយហេតុនោះ ព្រះអង្គទើបត្រាស់ថា វេលាថ្ងៃត្រង់ មានចិត្តត្រូវសេចក្តីឫស្យារួបរឹតហើយ ។ ចំណែកក្នុងវេលាល្ងាច ចិត្តរបស់ស្រីនោះរមែងបង្អោនទៅដើម្បីសេពអសទ្ធម្ម ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា វេលាល្ងាច មានចិត្តដែលកាមរាគៈ*

រួបរឹតហើយ ។

ចប់អដ្ឋកថា មាតុគ្រាមសូត្រទី ៤

## ចប់បេយ្យាលវគ្គទី ១

### រួមក្នុងវគ្គនេះមាន ៣ អដ្ឋកថា

១-អដ្ឋកថា អមនាបសូត្រ ២-អដ្ឋកថា អាវេណិកសូត្រ សូត្រទី៣
៣-អដ្ឋកថា មាតុគាមសូត្រ សូត្រទី ៤

# បេយ្យាលវគ្គទី ២

*មិនមានអដ្ឋកថាកែសេចក្ដីដែលលំបាកទេ ។*

# មាតុគាមពលវគ្គទី ៣

## អ ដ្ឋ ក ថា

### វិសារទសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិសារទសូត្រទី ១ ដូចតទៅនេះ ៖*

[១២៦] *ក្នុងបទជាដើមថា **កម្លាំង គឺ រូប** (រូបពលំ) សេចក្តីថា សេចក្តីដល់ព្រមនៃរូប ឈ្មោះថា រូបពលៈ ។ សេចក្តីដល់ព្រមនៃភោគៈ ឈ្មោះថា ភោគពលៈ ។ សេចក្តីដល់ព្រមនៃញាតិឈ្មោះថា ញាតិពលៈ ។ សេចក្តីដល់ព្រមនៃបុត្រ ឈ្មោះថា បុត្តពលៈ ។ សេចក្តីដល់ព្រមនៃសីល ឈ្មោះថា សីលពលៈ ។ ក៏កាលរក្សាសីល ៥ ឬសីល ១០ មិនដាច់ ឈ្មោះថា សីលពលៈ គឺ សេចក្តីដល់ព្រមនៃសីល ។ បទថា **ម្នាលភិក្ខុទាំងឡាយ កម្លាំងប្រាំប្រការនេះឯង** (ឥមានិ ខោ ភិក្ខវេ បញ្ចហិ ពលេហិ) សេចក្តីថា ពលៈទាំង ៥ នេះ លោកហៅឈ្មោះថា **ពលៈ** ព្រោះអត្ថថា ជាគ្រឿងគាំទ្រ (ឧបត្ថម្ភ) ។*

ចប់អដ្ឋកថា វិសារទសូត្រទី ១

# អ ដ្ឋ ក ថា

## បសយ្ហសូត្រទី ២

[១២៧] *បទថា បន្ទ្រ្កប (បសយ្ហ) គឺ គ្របសង្កត់ហើយ ។*

ចប់អដ្ឋកថា បសយ្ហសូត្រទី ២

# អ ដ្ឋ ក ថា

## អភិកុយ្យសូត្រទី ៣

[១២៨] *បទថា* ***រមែងប្រព្រឹត្តគ្របសង្កត់ (អភិកុយ វត្តតិ)*** *បានដល់ រមែងគ្របសង្កត់ គឺ សង្កត់សង្កិន ។ បទថា* ***កម្លាំង គឺ រូប រមែងការពារមិនបាន (នេវ រូបពលំ តាយតិ)*** *សេចក្តីថា កម្លាំង គឺ រូប រមែងមិនអាចនឹងការពារ គឺ រក្សាបានឡើយ ។*

ចប់អដ្ឋកថា អភិកុយ្យសូត្រទី ៣

# អ ដ្ឋ ក ថា

## នាសយិត្ថសូត្រទី ៥

[១៣២] បទថា រមែងញ៉ាំងមាតុគ្រាមនោះឲ្យវិនាស គឺ មិនឲ្យនៅក្នុងត្រកូល (នាសេន្តេវ នំ កុលេ ន វាសេន្តិ) សេចក្ដីថា ពួកញាតិគិតថា ស្ត្រីទ្រុស្តសីល វិនាសមារយាទ ប្រព្រឹត្តក្បត់ចិត្ត ដូច្នេះ ទើបចាប់.កនាំចេញទៅ គឺ មិនឲ្យនៅក្នុងត្រកូលនោះ ។ បទថា រមែងញ៉ាំងមាតុគ្រាមនោះឲ្យនៅក្នុងត្រកូល រមែងមិនឲ្យវិនាស (វាសេន្តេវ នំ កុលេ ន នាសេន្តិ) សេចក្ដីថា ពួកញាតិដឹងថា ប្រយោជន៍អ្វីដោយរូប ឬដោយគោត្រជាដើម ស្ត្រីនេះជាអ្នកមានសីលបរិសុទ្ធិ មានមារយាទល្អ ទើបឲ្យនៅក្នុងត្រកូលនោះ មិនឲ្យវិនាស ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានសេចក្ដីងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា នាសយិត្ថសូត្រទី ៥

## ចប់មាតុគាមពលវគ្គទី ៣

### រួមក្នុងវគ្គនេះមាន ៣ អដ្ឋកថា

១-អដ្ឋកថា វិសារទសូត្រ ២-អដ្ឋកថា បសយ្ហសូត្រ
៣-អដ្ឋកថា អភិភុយ្យសូត្រ ៤-អដ្ឋកថា នាសយិត្ថសូត្រ

# ជម្ពុខាទកសំយុត្ត

## អ ដ្ឋ ក ថា

## និព្វានបញ្ហាសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វានបញ្ហាសូត្រទី ១ នៃ ជម្ពុខាទកសំយុត្ត ដូចតទៅនេះ ៖*

[១៣៩] *បទថា* ***បរិព្វាជក ឈ្មោះថា ជម្ពុខាទក*** *(ជម្ពុខាទកោ បរិព្វាជកោ) សេចក្ដីថា បរិព្វាជកអ្នកស្លៀកសំពត់ ជាញាតិរបស់ព្រះសារីបុត្តត្ថេរ ដែលមានឈ្មោះយ៉ាងនេះ ។ បទថា* ***អ្នកមានអាយុ ការអស់រាគៈ (យោ ខោ អាវុសោ រាគក្ខយោ)*** *សេចក្ដីថា រាគៈ រមែងអស់ទៅព្រោះអាស្រ័យនិព្វាន ព្រោះដូច្នោះព្រះសារីបុត្រ ទើបហៅនិព្វានថា ការអស់រាគៈ ដូច្នេះ ។ សូម្បីក្នុងការអស់ទោសៈ និងមោហៈ ក៏មានន័យនេះដូចគ្នា ។*

*ចំណែកបុគ្គលណា គប្បីពោលត្រឹមតែការអស់កិលេសថា និព្វាន ដោយសូត្រនេះ ។ បុគ្គលនោះ គប្បីត្រូវសួរថា ការអស់កិលេសរបស់បុគ្គលនោះ របស់ខ្លួន ឬរបស់អ្នកដទៃ ។ គេនឹងឆ្លើយថា របស់ខ្លួនឯង ។*

គេត្រូវសួរតទៅទៀតថា អ្វីជាអារម្មណ៍របស់គោត្រភូញាណ កាលដឹងនឹង ឆ្លើយថា និព្វាន ។ សួរថា ក៏កិលេសទាំងឡាយអស់ហើយ កំពុងអស់ នឹង អស់ក្នុងខណៈនៃគោត្រញាណឬ ឆ្លើយថា គេមិនគប្បីឆ្លើយថា អស់ហើយ ឬកំពុងអស់ ។ តែគប្បីឆ្លើយថា នឹងអស់ដូច្នេះ ។ ក៏កាលកិលេសទាំង ឡាយនោះ នៅមិនទាន់អស់ហើយ ។ គោត្រភូញាណ នឹងធ្វើការអស់នៃ កិលេស ឲ្យជាអារម្មណ៍បានឬ កាលលោកត្រូវសួរយ៉ាងនេះហើយ គេនឹង មិនមានពាក្យឆ្លើយ ។

តែក្នុងសេចក្តីនេះ គប្បីប្រកបការអស់កិលេសសូម្បីដោយមគ្គញាណ ។ ព្រោះថា កិលេសទាំងឡាយ សូម្បីក្នុងខណៈនៃមគ្គ មិនគួរពោលថា អស់ ហើយ ឬនឹងអស់ មួយទៀត កិលេសទាំងឡាយមិនទាន់អស់ទៅ ការអស់ កិលេស រមែងជាអារម្មណ៍ក៏មិនបាន ។ ព្រោះដូច្នោះ ប្រការនោះគួរទទួល បាន ។ ធម៌ មានរាគៈជាដើម រមែងអស់ទៅ ព្រោះអាស្រ័យធម្មជាតិណា ព្រោះហេតុនោះ ធម្មជាតិ ឈ្មោះថា **និព្វាន** ។ ចំណែកនិព្វាននេះ មិនត្រឹម តែជាការអស់កិលេសប៉ុណ្ណោះ ព្រោះលោកសង្គ្រោះទុកថា ជាអរូបធម៌ ។ ធម៌ទាំងឡាយដែលឈ្មោះថា រូប ក្នុងទុកៈមាតិកា មានជាដើមថា **រូបិនោ ធម្មា អរូបនោ ធម្មា** ធម៌ទាំងឡាយដែលឈ្មោះថា រូប ធម៌ទាំងឡាយដែល

មិនឈ្មោះថា រូប ដូច្នេះ ។

ចប់អដ្ឋកថា និព្វានបញ្ហាសូត្រទី ១

# អដ្ឋកថា

## អរហត្តបញ្ហាសូត្រទី ២

[១៨០] ក្នុងការព្យាករណ៍បញ្ហាក្នុងអរហត្ត ព្រោះអរហត្តរមែងកើតឡើងក្នុងទីបំផុតនៃការអស់រាគៈ ទោសៈ និងមោហៈ ដូច្នោះ ព្រះសារីបុត្រទើបពោលថា ការអស់រាគៈ ទោសៈ មោហៈ ដូច្នេះ ។

ចប់អដ្ឋកថា អរហត្តបញ្ហាសូត្រទី២

# អ ដ្ឋ ក ថា

## ធម្មវាទីបញ្ហាសូត្រទី ៣

[១៤១] *បទថា បុគ្គលទាំងនោះ ឈ្មោះថា ជាអ្នកមានដំណើរល្អក្នុងលោក (តេ លោកេ សុគតា) សេចក្តីថា លោកទាំងនោះ ឈ្មោះថា ទៅល្អហើយ ព្រោះលះរាគៈជាដើម ទៅហើយ ។*

ចប់អដ្ឋកថា ធម្មវាទីបញ្ហាសូត្រទី ៣

# អ ដ្ឋ ក ថា

## កិមត្ថិយសូត្រទី ៤

[១៤២] *បទថា អ្នកមានអាយុ... ដើម្បីកំណត់ដឹងទុក្ខ (ទុក្ខស្ស ខោ អាវុសោ បរិញ្ញត្ថំ) សេចក្តីថា ដើម្បីកំណត់ដឹងវដ្តទុក្ខ ។*

ចប់អដ្ឋកថា កិមត្ថិយសូត្រទី ៤

# អ ដ្ឋ ក ថា

## ទុក្ខបញ្ហាសូត្រទី ១៤

[១៥២] *បទថា សភាវទុក្ខ (ទុក្ខតា) គឺ សភាពនៃទុក្ខ ។ ក្នុងបទជាដើមថា ទុក្ខទុក្ខតា បានដល់ សភាពនៃទុក្ខ ពោលគឺ ទុក្ខ ឈ្មោះថា ទុក្ខតា ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ទុក្ខបញ្ហាសូត្រទី ១៤

# អ ដ្ឋ ក ថា

## ទុក្ករបញ្ហាសូត្រទី ១៦

[១៥៤] បទថា សេចក្ដីត្រេកអរក្រៃលែង (អភិរតិ) គឺ សេចក្ដីមិនអផ្សុកក្នុងការបព្វជ្ជា ។ បទថា មិនយូរណាស់ (ន ចិរំ អាវុសោ) លោកសម្ដែងថា បពិត្រលោកដ៏មានអាយុ ភិក្ខុដែលបដិបត្តិធម៌សមគួរដល់ធម៌កាលប្រារព្ធព្យាយាម ព្យាយាមនៅ នឹងគប្បីជាព្រះអរហន្ត គឺ គប្បីតាំងនៅក្នុងព្រះអរហត្ត បានមិនយូរ គឺ រហ័សទាន់ឯង ។ ព្រោះលោកពោលថា ភិក្ខុដែលលោកដាស់តឿនហើយក្នុងវេលាព្រឹក ក៏នឹងសម្រេចគុណវិសេសក្នុងវេលាល្ងាច ភិក្ខុដែលលោកដាស់តឿនហើយក្នុងវេលាល្ងាច នឹងសម្រេចគុណវិសេសក្នុងវេលាព្រឹក ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្ដីងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ទុក្ករបញ្ហាសូត្រទី ១៦

## ចប់ជម្ពុខាទកវគ្គទី ៤

### រួមក្នុងវគ្គនេះមាន ៣ អដ្ឋកថា

១-អដ្ឋកថា និព្វានបញ្ហាសូត្រ
២-អដ្ឋកថា អរហត្តបញ្ហាសូត្រ
៣-អដ្ឋកថា ធម្មវាទីសូត្រ
៤-អដ្ឋកថា កិមត្ថិយសូត្រ
៥-អដ្ឋកថា ទុក្ខបញ្ហាសូត្រ
៦-អដ្ឋកថា ទុក្ករបញ្ហាសូត្រ

# សាមណ្ឌកសំយុត្ត

## អ ដ្ឋ ក ថា

## សាមណ្ឌកសំយុត្ត

[១៥៥] *សូម្បីក្នុង សាមណ្ឌកសំយុត្ត គប្បីជ្រាបសេចក្តីដោយន័យនេះឯង[១] ។*

*រួមព្រះសូត្រក្នុងសំយុត្តនេះ ដូចគ្នានឹងក្នុងសំយុត្តមុន (គឺ ជម្ពុខាទកសំយុត្ត)*

ចប់អដ្ឋកថា សាមណ្ឌកសំយុត្ត

## ចប់សាមណ្ឌកសំយុត្ត

# មោគ្គល្លានសំយុត្ត

## អ ដ្ឋ ក ថា

## សវិតក្កបញ្ហាសុត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោគ្គល្លានសំយុត្ត ដូចតទៅនេះ ៖*

[១៥៧] *បទថា ដែលប្រកបដោយកាម (កាមសហគតា) គឺ ប្រកបដោយនីវរណៈ ៥ ក៏កាលភិក្ខុនោះចេញចាកបឋមឈានហើយ នីវរណៈ ៥ ប្រាកដហើយដោយសេចក្តីស្ងប់ ដោយហេតុនោះ បឋមជ្ឈាននោះ របស់ភិក្ខុនោះ រមែងឈ្មោះថា មានចំណែកនៃសេចក្តីសាបសូន្យ ព្រះសាស្តាទ្រង់ជ្រាបសេចក្តីប្រមាទនោះហើយ ទើបបានប្រទានព្រះឱវាទថា "កុំប្រមាទ" ។*

ចប់អដ្ឋកថា សវិតក្កបញ្ហាសូត្រទី ១

# អ ដ្ឋ ក ថា

## អវិតក្កបញ្ហាសូត្រទី ២

[១៥៨] *សូមជ្រាបក្នុងទុតិយជ្ឈានជាដើម ក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ។ ក៏ក្នុងសេចក្តីនេះ ឈានដែលប្រកបជាមួយអារម្មណ៍ប៉ុណ្ណោះ លោកពោលថា* ***សហគតំ*** *ដូច្នេះ ។*

ចប់អដ្ឋកថា អវិតក្កបញ្ហាសូត្រទី ២

# អ ដ្ឋ ក ថា

## អនិមិត្តបញ្ហាសូត្រទី ៩

[១៦៥] បទថា **អនិមិត្តោ ចេតោសមាធិ** នោះ ព្រះថេរៈពោលសំដៅដល់វិបស្សនាសមាធិដែលលះបង់និមិត្តថា ទៀងជាដើមបាន ហើយប្រព្រឹត្តទៅ ។ បទថា **វិញ្ញាណដែលផ្សាយទៅតាមអនិមិត្តរមែងមាន (អនិមិត្តានុសារិវិញ្ញាណំ ហោតិ)** សេចក្តីថា កាលខ្ញុំនៅដោយវិបស្សនាសមាធិវិហារធម៌នេះ វិបស្សនាញាណក៏ចាស់ក្លា បរិសុទ្ធ នាំទៅហើយ ។ ដូចកាលបុរសយកពូថៅដ៏មុតល្អ កាប់ដើមឈើ ហើយសម្លឹងមើលត្រង់មុខកាប់ក្នុងគ្រប់ខណៈ ដោយគិតថា ពូថៅរបស់យើងមុតពិតហ្ន៎ ដូច្នេះ កិច្ចក្នុងការកាត់ ក៏រមែងមិនសម្រេចយ៉ាងណា សូម្បីព្រះថេរៈប្រារព្ធវិបស្សនា ដោយគិតថា ញាណរបស់យើងចាស់ក្លាពិតហ្ន៎ ដូច្នេះ សេចក្តីប្រាថ្នាក៏រមែងកើតឡើង ក្នុងកាលនោះ ព្រះថេរៈនោះ ក៏មិនអាចឲ្យវិបស្សនាកិច្ចសម្រេចបានដូច្នោះ ។ ព្រះថេរៈសំដៅដល់ប្រការនោះ ទើបពោលថា **អនិមិត្តានុសារិវិញ្ញាណំ ហោតិ** ។ បទថា **ខ្ញុំចូលអនិមិត្តចេតោសមាធិហើយ ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង (សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោ-**

*សមាធិ ឧបសម្បជ្ជ វិហាសឹ) សេចក្តីថា ខ្ញុំចូលបេតោសមាធិដែលសម្បយុត្ត ដោយវុដ្ឋានគាមិនីវិបស្សនា និងសមាធិក្នុងមគ្គ និងផលជាន់ខ្ពស់ ដែលមាននិព្វានជាអារម្មណ៍ ដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តថាទៀង ថាសុខ ថាជាខ្លួន ។*

ចប់អដ្ឋកថា អនិមិត្តបញ្ហាសូត្រទី ៩

# អ ដ្ឋ ក ថា

## សក្កសូត្រទី ១០

[១៦៩] *បទថា ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក (អវេច្ចប្ប-សាទេន) បានដល់ ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក ។*

[១៧២] *បទថា ដោយឋានៈ ១០ (ទសហិ ឋានេហិ) គឺ ដោយហេតុ ១០ ។ បទថា រមែងគ្របសង្កត់ (អធិគណ្ហន្តិ) គឺ រមែងគ្របសង្កត់ គឺ ប្រសើរលើស ។ ពាក្យដ៏សេសមានសេចក្ដីងាយទាំងអស់នោះឯង ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សក្កសូត្រទី ១០

## ចប់មោគ្គល្លានសំយុត្ត

### រួមក្នុងវគ្គនេះមាន ៤ អដ្ឋកថា

*១-អដ្ឋកថា សវិតក្កបញ្ហាសូត្រ ២-អដ្ឋកថា អវិតក្កបញ្ហាសូត្រ*

*៣-អដ្ឋកថា អនិមិត្តបញ្ហាសូត្រ ៤-អដ្ឋកថា សក្កសូត្រ*

# ចិត្តគហបតិបុច្ឆាសំយុត្ត

## អ ដ្ឋ ក ថា

### សញ្ញោជនសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញោជនសូត្រទី ១ នៃ ចិត្តគហបតិបុច្ឆា-សំយុត្ត ដូចតទៅ ៖*

[១៧៩] *បទថា* **មច្ឆិកាសណ្ឌេ** *គឺ ក្នុងដងព្រៃដែលមានឈ្មោះយ៉ាងនេះ ។ បទថា* **បានសន្ទនាគ្នា (អយមន្តរាកថា ឧទបាទិ)** *សេចក្តីថា ព្រះថេរៈចាស់ រមែងមិនសន្ទនាគ្នាដល់តិរច្ឆានកថា កាលតាំងបញ្ហាឡើងក្នុងទីអន្លុយហើយ ពួកអ្នកមិនដឹង ក៏រមែងសួរ ពួកអ្នកដែលដឹង ក៏រមែងឆ្លើយ ដោយហេតុនោះ ការសន្ទនានេះ ទើបកើតឡើងហើយដល់ព្រះថេរៈទាំងនោះ ។*

[១៨០] *បទថា* **មិគបថកំ** *គឺ ស្រុកសួយរបស់ខ្លួនដែលមានឈ្មោះយ៉ាងនេះ ។ បានឮថាស្រុកសួយនោះ នៅក្រោយអម្ពាដការាម ។*

[១៨១] *បទថា* **បានចូលទៅរកព្រះថេរៈទាំងឡាយដល់ទីនៅ (តេនុបសង្កមិ)** *សេចក្តីថា ចិត្តគហបតីគិតថា យើងដោះស្រាយបញ្ហារបស់ព្រះថេរៈ*

ទាំងឡាយហើយ នឹងធ្វើសេចក្ដីនៅជាសុខឲ្យ ដូច្នេះ ទើបចូលទៅរក ។

[១៨២] បទថា ក្នុងព្រះពុទ្ធវចនៈដ៏ជ្រាលជ្រៅ (គម្ភីរេ ពុទ្ធវចនេ) សេចក្ដីថា ក្នុងព្រះពុទ្ធវចនដ៏ជ្រាលជ្រៅដោយអត្ថ និងជ្រាលជ្រៅដោយធម៌ ។ បទថា បញ្ញាចក្ខុរបស់លោកនឹងជ្រាប (បញ្ញាចក្ខុ កមតិ) សេចក្ដីថា ចក្ខុ គឺ ញាណ រមែងនឹងជ្រាប គឺ រមែងប្រព្រឹត្តទៅ។

ចប់អដ្ឋកថា សញ្ញោជនសូត្រទី ១

# អ ដ្ឋ ក ថា

## បឋមឥសិទត្តសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***បឋមឥសិទត្តសូត្រទី ២*** *ដូចតទៅនេះ ៖*

[១៨៤] *បទថា* ***ព្រះថេរៈដែលជាប្រធាន (អាយស្មន្តំ ថេរំ)*** *គឺ មហាថេរៈដែលជាធំ ក្នុងបណ្តាព្រះថេរៈទាំងនោះ ។*

[១៨៥] *បទថា* ***បាននៅស្ងៀម (តុណ្ហី អហោសិ)*** *សេចក្តីថា ព្រះថេរៈសូម្បីដឹងហើយ ក៏មិនព្យាករណ៍អ្វីៗ ព្រោះមិនក្លៀវក្លា ។*

[១៨៦] *បទថា* ***បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំសូមព្យាករណ៍ (ព្យាករោមហំ ភន្តេ)*** *សេចក្តីថា ព្រះឥសិទត្តៈគិតថា ព្រះថេរៈនេះ រមែងមិនព្យាករណ៍ដោយខ្លួនឯង ។ ព្រះថេរៈនេះ រមែងមិនអរាធនា ចំណែកឧបាសករមែងបៀតបៀនភិក្ខុសង្ឃ , យើងព្យាករណ៍បញ្ហានោះហើយ នឹងធ្វើការនៅជាសុខឲ្យ ដូច្នេះ ក្រោកចាកអាសនៈទៅកាន់សំណាក់របស់ព្រះថេរៈ បានធ្វើឱកាសយ៉ាងនេះហើយ បានឱកាសយ៉ាងនេះហើយ ឯព្រះឥសិទត្តៈ បានឱកាសដែលខ្លួនធ្វើហើយ អង្គុយលើអាសនៈរបស់ខ្លួន ព្យាករណ៍ ។*

[១៨៧] *បទថា* ***សហត្ថា*** *គឺ ដោយដៃរបស់ខ្លួន ។ បទថា* ***ឲ្យឆ្អែត***

ស្កប់ស្កល់ (សន្តប្បេសិ) សេចក្តីថា ឲ្យឆ្អែតគ្រប់គ្រាន់ដោយល្អតាមប្រាថ្នា ។

បទថា គ្រប់គ្រាន់ (សម្បវារេសិ) សេចក្តីថា ឲ្យព្រះថេរៈទាំងឡាយហាមដោយហត្ថសញ្ញា ឬដោយវាចាថា គ្រប់គ្រាន់ហើយ ដូច្នេះ ។ បទថា ដកដៃចេញពីបាត្រហើយ (ឱនីតបត្តបាណិនោ) សេចក្តីថា នាំដៃចេញពីបាត្រលាងបាត្រហើយ ទើបយកទុកក្នុងស្បោកត្រង់ស្មា ដូច្នេះ ។

ចប់អដ្ឋកថា បឋមឥសិទត្តសូត្រទី ២

# អ ដ្ឋ ក ថា

## ទុតិយឥសិទត្តសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឥសិទត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[១៩៣] *បទថា អវន្តី (អវន្តិយា) គឺ ក្នុងអវន្តីជនបទ ។*

[១៩៤] *បទថា លោកពោលល្អហើយ (កល្យាណំ វុច្ចតិ) សេចក្តីថា ព្រះឥសិទត្តៈ រមែងពោលដោយបំណងថា ឧបាសក ឧបាសិកាទាំងឡាយ ពាក្យដែលអស់ទោស មិនមានទោស ដែលលោកពោលថា ខ្ញុំនឹងទំនុកបម្រុង ដោយបច្ច័យទាំងឡាយ ៤ ។*

ចប់អដ្ឋកថា ទុតិយឥសិទត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## មហកសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង មហកសូត្រទី ៤ ដូចតទៅនេះ ៖*

*[១៩៧] បទថា ចូរចែកអាហារចំណែកដែលសេសសល់ចុះ (សេសកំ វិស្សជ្ជេថ) សេចក្ដីថា បានឮថា ពួកឧបាសក និងឧបាសិកា ជូតថាសសំរិទ្ធិ ហើយដួសបាយបាយាសជូនដល់ចិត្តគហបតី ព្រមទាំងព្រះថេរៈទាំងឡាយនោះ ចិត្តគហបតីបរិភោគបាយបាយាសរួចស្រេចហើយ ប្រាថ្នានឹងទៅជាមួយព្រះថេរៈទាំងឡាយនុ៎ះឯង ទើបគិតថា ឧបាសិកាចាត់ចែងអាហារដែលសល់នៅក្នុងផ្ទះមុន ចំណែកទាសៈ និងកម្មករក្នុងផ្ទះនេះ បើយើងមិនប្រាប់ នឹងមិនជួយចាត់ចែងបាយបាយាសដែលប្រណីតនេះ ទើបចេញទៅដោយអាការយ៉ាងនេះ ដូច្នេះ កាលបើអនុញ្ញាត ទើបពោលយ៉ាងនេះ ដល់ទាសៈ និងកម្មករទាំងនោះ ។ បទថា កុដ្ឋិតំ គឺ ក្ដៅខ្លាំង អធិប្បាយថា ខាងក្រោមក្ដៅដោយខ្សាច់ និងខាងលើក្ដៅដោយកំដៅព្រះអាទិត្យ ក៏ពាក្យនេះជាពាក្យមិនលាយឡំក្នុងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ។ បទថា រួញចូល (បវេលិយមានេន) គឺ មានកាយលំបាក ។*

[១៩៨] បទថា *លោកម្ចាស់ដ៏ចម្រើន ជាការប្រពៃណាស់ដែលគប្បីមាន (សាធុ ខ្វស្ស ភន្តេ)* សេចក្តីថា ព្រះមហកៈគិតថា យើងនឹងធ្វើការនៅជាសុខដល់ព្រះថេរៈទាំងនោះ ទើបពោលយ៉ាងនេះ ។

បទថា *បានបណ្តាលឥទ្ធាភិសង្ខារ (ឥទ្ធាភិសង្ខារំ អភិសង្ខរិ)* បានដល់បានបណ្តាលឫទ្ធិដោយការអធិដ្ឋាន ។ ក្នុងការបណ្តាលឫទ្ធិនេះ ការធ្វើមានបរិកម្មផ្សេងៗ យ៉ាងនេះថា សូមខ្យល់ត្រជាក់ៗ ចូរបក់មក សូមភ្លៀងធ្លាក់ចុះមកម្តងមួយគ្រាប់ៗ ដូច្នេះ ហើយអធិដ្ឋានរួមគ្នាយ៉ាងនេះថា សូមភ្លៀងលាយដោយខ្យល់ចូរធ្លាក់ចុះ ដូច្នេះក៏មាន ការធ្វើបរិកម្មរួមគ្នាថា សូមភ្លៀងលាយដោយខ្យល់ធ្លាក់ចុះ ហើយអធិដ្ឋានផ្សេងៗ ថា សូមខ្យល់ត្រជាក់ៗ ចូរបក់មក សូមភ្លៀងធ្លាក់ចុះមកម្តងមួយគ្រាប់ៗ ដូច្នេះក៏មាន ការបរិកម្មផ្សេងៗ (និង) ការអធិដ្ឋានផ្សេងៗ ការបរិកម្មរួមគ្នា (និង) ការអធិដ្ឋានរួមគ្នាក៏មាន ដោយន័យដែលពោលហើយនោះឯង ។ ក៏កាលបុគ្គលធ្វើយ៉ាងណាមួយ ចេញចាកឈានដែលជាបាទ ធ្វើបរិកម្មហើយ ការអធិដ្ឋាននោះរមែងសម្រេចដោយចិត្តអធិដ្ឋានដែលជាមហគ្គតៈប៉ុណ្ណោះ ក្នុងវាងនៃបរិកម្ម ។

[១៩៩] បទថា *គ្របលើ (ឱកាសេសិ)* គឺ រលាស់ចេញហើយ ។

ចប់អដ្ឋកថា មហាកសូត្រទី ៤

# អ ដ្ឋ ក ថា

## បឋមកាមភូសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមកាមភូសូត្រទី ៥** ដូចតទៅនេះ ៖

[២០០] បទថា **នេលង្គោ** គឺ មិនមានទោស ។ បទថា **សេតបច្ឆាទោ** គឺ មានគ្រឿងពាសពណ៌ស ។ បទថា **អនីឃំ** គឺ មិនមានទុក្ខ ។

[២០១] បទថា **ស្ងៀមតែមួយរំពេច (មុហុត្តំ តុណ្ហី ហុត្វា)** សេចក្តីថា ចិត្តគហបតីកាលញុំាងព្រះត្រៃបិដកឲ្យញាប់ញ័រ ដើម្បីសម្លឹងសេចក្តីនៃបទថា **នេលង្គោ** នោះ ដូចជាការញីត្រចៀក ទើបនៅស្ងៀមមួយភ្លែតដើម្បីពិចារណាថា នេះជាសេចក្តីនៃបទនេះ ។ បទថា **វិមុត្តិ (វិមុត្តិយា)** គឺ អរហត្តផលវិមុត្តិ ។ ក៏ឧបាសក កាលពោលបញ្ហានេះ បានធ្វើវត្ថុដែលធ្វើបានលំបាក ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធត្រាស់ដោយវត្ថុដែលព្រះអង្គទ្រង់ឃើញហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនឃើញភិក្ខុនោះ ស្ងួកស្គាំង ស្គាំងស្គម ប្រមុះស្រួច មកទេឬ តែចិត្តគហបតីនេះ ពោលហើយថា នោះជាឈ្មោះរបស់ព្រះអរហន្ត ដោយឲ្យកាន់យកន័យ ។

ចប់អដ្ឋកថា បឋមកាមភូសូត្រទី ៥

# អ ដ្ឋ ក ថា

## ទុតិយកាមភូសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ទុតិយកាមភូសូត្រទី ៦** ដូចតទៅនេះ ៖*

[២០២] *បទថា **បពិត្រព្រះករុណាដ៏ចម្រើន សង្ខារមានប៉ុន្មានហ្ន៎ (កតិ នុ ខោ ភន្តេ សង្ខារា)** សេចក្តីថា បានឮថា គហបតីរមែងស្វែងរកនិរោធ ព្រោះដូច្នោះ ទើបគិតថា យើងនឹងសួរសង្ខារទាំងឡាយដែលជាបាទនៃនិរោធ ទើបបានពោលយ៉ាងនេះ ។ សូម្បីព្រះថេរៈក៏ដឹងសេចក្តីបំណងរបស់គហបតីនោះ កាលបើសង្ខារច្រើនយ៉ាង មានបុញ្ញាភិសង្ខារជាដើម សូម្បីមានហើយ កាលនឹងប្រាប់កាយសង្ខារជាដើម ទើបពោលពាក្យមានជាដើមថា **តយោ ខោ គហបតិ** ។*

*បណ្តាបទទាំងនោះ ឈ្មោះថា **កាយសង្ខារ** ព្រោះអត្ថថា ដែលកាយតាក់តែងឲ្យកើត ព្រោះជាប់ដោយកាយ ។ ឈ្មោះថា **វចីសង្ខារ** ព្រោះអត្ថថា តាក់តែងវាចា ធ្វើឲ្យកើតដោយវាចា ។ ឈ្មោះថា **ចិត្តសង្ខារ** ព្រោះអត្ថថា ដែលចិត្តតាក់តែងឲ្យកើត ព្រោះជាប់ដោយចិត្ត ។*

[២០៣] *ក្នុងបទថា **កតមោ បន ភន្តេ** នេះ គហបតីបានសួរដូចម្តេច*

បានសួរថា សង្ខារទាំងឡាយនេះ លាយច្រឡំគ្នា ច្របូកច្របល់គ្នា មិនប្រាកដច្បាស់ សម្តែងលំបាក ។ ពិតយ៉ាងនោះ ចេតនា ២០ ដែលជាកុសល និងអកុសល យ៉ាងនេះ គឺ កាមាវចរកុសលចេតនា ៨ ដួង ដែលកើតឡើងហើយ ឲ្យសម្រេចសូម្បីការតោង ការកាន់ ការព្រលែង ការកម្រើកក្នុងកាយទ្វារ , អកុសលចេតនា ១២ ដួងក្តី ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញក្តី លោកហៅថា កាយសង្ខារ ។ ចេតនា ២០ ដួងក្តី វិតក្កៈវិចារក្តី ដែលមានប្រការដូចពោលមក ដែលកើតឡើងឲ្យសម្រេចសូម្បីការកម្រើនមាត់បន្ទឹះវាចាក្នុងវចីទ្វារ លោកហៅថា វចីសង្ខារ ។ ចេតនា ២៩ ដួង ដែលជាកុសល និងអកុសល កើតឡើងហើយដល់អ្នកអង្គុយគិតនៅក្នុងទីកំបាំង មិនសម្រេចដល់ការកម្រើកកាយទ្វារ និងវចីទ្វារក្តី និងធម៌ ២ យ៉ាងទាំងនេះ គឺ សញ្ញា និងវេទនាក្តី លោកហៅថា ចិត្តសង្ខារ ។ សង្ខារទាំងនេះ លាយឡំគ្នា ច្របូកច្របល់គ្នា មិនប្រាកដច្បាស់ សម្តែងលំបាក ។ ខ្ញុំធ្វើសង្ខារទាំងនោះឲ្យប្រាកដជាក់ច្បាស់មិនបាន ទើបសូមឲ្យលោកម្ចាស់សម្តែង ដោយប្រការដូច្នេះ ។

[២០៤] ក្នុងបទថា **កស្មា បន ភន្តេ** នេះ គហបតី រមែងសួរសេចក្តីនៃបទរបស់សង្ខារ មានកាយសង្ខារជាដើម ។ ក្នុងការឆ្លើយសេចក្តីបទនោះ

បទថា **ធម៌ទាំងនេះជាប់ដោយកាយ (កាយបដិពទ្ធា)** គឺ ធម៌ទាំងនេះអាស្រ័យកាយ កាលបើកាយមាន ធម៌ទាំងនេះក៏មាន កាលបើកាយមិនមាន ធម៌ទាំងនេះ ក៏មិនមាន ។ បទថា **ធម៌ទាំងនេះជាប់ដោយចិត្ត (ចិត្តបដិពទ្ធា)** គឺ ធម៌ទាំងនេះអាស្រ័យចិត្ត កាលបើចិត្តមាន ធម៌ទាំងនេះក៏មាន កាលចិត្តមិនមាន ធម៌ទាំងនេះក៏មិនមាន ។

[២០៥] ឥឡូវនេះ កាលសួរដើម្បីឲ្យដឹងថា ព្រះកាមភូនោះ រមែងស្វែងរកនូវសញ្ញាវេទយិតនិរោធ ឬមិនស្វែងរក ជាអ្នកជំនាញ ឬមិនជំនាញក្នុងសញ្ញាវេទយិតនិរោធនោះ ទើបសួរថា **ព្រះករុណាដ៏ចម្រើន ក៏សញ្ញាវេទយិតនិរោធ កើតឡើងដូចម្តេច? (កថម្បន ភន្តេ សញ្ញាវេទយិតនិរោធសមាបត្តិ ហោតិ)** ។

ក្នុងការឆ្លើយ សញ្ញាវេទយិតនិរោធនោះ ដោយពីរបទថា **នឹងចូល ឬកំពុងចូល (សមាបជ្ជិស្សន្តិ វា សមាបជ្ជាមានេតិ វា)** ជាការដែលលោកពោលដល់វេលាចូលនៅសញ្ញានាសញ្ញាយតនៈ ។ ដោយបទថា **ចូលហើយ (សមាបន្នោ)** គឺ លោកពោលដល់ចំណែកក្នុងនិរោធ ។ ដោយពីរបទមុននោះ លោកពោលដល់វេលាមានវិតក្កៈ ។ ដោយបទក្រោយ លោកពោលដល់វេលាមិនមានវិតក្កៈ ។

បទថា **មុននឹងចូល លោកបានអប់រំចិត្ត (បុព្វេ តថា ចិត្តំ ភាវិតំ ហោតិ)** សេចក្តីថា ការកំណត់វេលាថា យើងមិនមានចិត្ត នឹងទៅបានរហូតដល់អស់វេលាប្រមាណប៉ុណ្ណេះ តពីនោះ នឹងជាអ្នកមានចិត្ត ក្នុងវេលាមុននឹងចូលនិរោធសមាបត្តិ ក៏កំណត់វេលាបានដូចគ្នា ។ លោកបានអប់រំចិត្តយ៉ាងនោះ ។ បទថា **តែងបង្អោនទៅដើម្បីមានសភាពដូច្នោះ (យន្តំ តថត្តាយ ឧបនេតិ)** សេចក្តីថា ចំណែកចិត្តដែលលោកអប់រំយ៉ាងនេះហើយ រមែងនាំបុគ្គលនោះចូលទៅដើម្បីមានសភាពដូច្នោះ គឺ បង្អោនទៅដើម្បីមិនឲ្យមានចិត្ត ។ (បិដក គឺ មិនឲ្យមានសញ្ញា និងវេទនានោះឯង) ។

[២០៦] បទថា **វចីសង្ខាររលត់មុន (វចីសង្ខារោ បឋមំ និរុជ្ឈតិ)** សេចក្តីថា វចីសង្ខារ រមែងរលត់ក្នុងទុតិយជ្ឈាន មុនសង្ខារដ៏សេស ។ បទថា **តពីនោះកាយសង្ខារ (តតោ កាយសង្ខារោ)** គឺ តពីនោះ កាយសង្ខារទើបរលត់ក្នុងចតុត្ថជ្ឈាន ។ បទថា **តពីនោះចិត្តសង្ខារ (តតោ ចិត្តសង្ខារោ)** គឺ តពីនោះ ចិត្តសង្ខារទើបរលត់ក្នុងខាងក្នុងនិរោធសមាបត្តិ ។

[២០៧] បទថា **អាយុ (អាយុ)** គឺ រូបជីវិតិន្ទ្រិយ ។ បទថា **បែកធ្លាយរាត់រាយ (វិបរិភិន្នានិ)** គឺ ត្រូវកម្ចាត់ វិនាសទៅហើយ ។

បណ្តាបទទាំងនោះ អាចារ្យពួកខ្លះ រមែងពោលថា កាលចូលនិរោធ

ហើយ ចិត្តរមែងមិនរលត់ ព្រោះបាលីថា ចិត្តសង្ខាររលត់ ព្រោះដូច្នោះ សមាបត្តិនេះ ក៏នៅមានចិត្ត ។ អាចារ្យពួកខ្លះនោះ គប្បីត្រូវជំទាស់ថា វាចាក៏មិនរលត់ ព្រោះបាលីថា វចីសង្ខាររបស់គេក៏រលត់ ព្រោះដូច្នោះ បុគ្គលចូលនិរោធហើយ គប្បីអង្គុយសម្តែងធម៌ក៏មាន គប្បីអង្គុយស្វាធ្យាយក៏មាន ។ ចិត្តក៏មិនរលត់ ព្រោះបាលីថា បុគ្គលនេះស្លាប់ហើយ ធ្វើកាលៈហើយ ព្រះអរហន្តក្តី ដែលស្លាប់ហើយ ទើបជាអនន្តរិយកម្ម ។ មិនគប្បីប្រកាន់យកព្យញ្ជនៈហួសពេកទេ គប្បីតាំងនៅក្នុងការណែនាំរបស់អាចារ្យទាំងឡាយ ហើយពិចារណាដល់អត្ថ ដោយប្រការដូច្នេះ ។ ព្រោះថា អត្ថជាទីពឹងបាន ព្យញ្ជនៈមិនបាន ។

បទថា **ឥន្ទ្រិយផូរផង់ (ឥន្ទ្រិយានិ វិប្បសន្នានិ)** សេចក្តីថា ក៏កាលការប្រព្រឹត្តសម្រេចដោយកិរិយាប្រព្រឹត្តទៅហើយ អារម្មណ៍ទាំងឡាយក្នុងខាងក្រៅ ប៉ះខ្ទប់ត្រង់បសាទទាំងឡាយ ឥន្ទ្រិយទាំងឡាយរមែងលំបាក ។ ឥន្ទ្រិយទាំងឡាយ ដែលត្រូវប៉ះខ្ទប់ហើយ រមែងដូចជាប្រឡាក់ , ដូចកញ្ចក់ដែលគេតាំងទុកក្នុងផ្លូវធំបែកជា ៤ រមែងប្រឡាក់ដោយធូលីកើតពីខ្យល់ជាដើម ដូច្នោះ ។ ប្រៀបដូចកញ្ចក់ ដែលគេដាក់ទុកក្នុងស្បោង រក្សាទុកក្នុងហិបជាដើម រមែងថ្លាល្អនៅខាងក្នុងប៉ុណ្ណោះ យ៉ាងណា កាលភិក្ខុចូល

និរោធហើយ បសាទ ៥ រមែងផូរផង់ក្រៃលែងក្នុងខាងក្នុងនិរោធ ក៏ដូច្នោះ ។ ដោយហេតុនោះ លោកទើបពោលថា **ឥន្ទ្រិយថ្លាផូរផង់** ។

[២០៨] លោកពោលដល់វេលានៅក្នុងនិរោធ ដោយពីរបទថា **នឹងចេញ ឬកំពុងចេញ (វុដ្ឋហិស្សន្តិ វា វុដ្ឋហាមិ វា)** លោកពោលដល់វេលាផលសមាបត្តិកើត ដោយបទថា **ចេញហើយ (វុដ្ឋិតោ)** ។ លោកពោលដល់វេលាមិនមានចិត្ត ដោយពីរបទមុននោះ ។ ដោយបទក្រោយ លោកពោលដល់វេលាមានចិត្ត ។ បទថា **មុននឹងចេញ លោកបានអប់រំចិត្ត (បុព្វេ តថា ចិត្តំ ភាវិតំ ហោតិ)**[១] សេចក្តីថា ក្នុងវេលាមុននឹងចេញចាកនិរោធ-សមាបត្តិ ក៏កំណត់វេលាបានដូចគ្នា គឺ លោកបានអប់រំចិត្តដែលកំណត់វេលាបានថា យើងជាអ្នកមិនមានចិត្ត នឹងនៅបានរហូតអស់វេលាប្រមាណប៉ុណ្ណោះ តអំពីនោះ នឹងជាអ្នកមានចិត្ត ។ បទថា **បង្អោនទៅដើម្បីមានសភាពដូច្នោះ (យន្តំ តថត្តាយ ឧបនេតិ)** សេចក្តីថា ចិត្តដែលលោកអប់រំយ៉ាងនេះហើយ រមែងនាំបុគ្គលនោះចូលទៅដើម្បីសភាពដូច្នោះ គឺ សភាពជាអ្នកមានចិត្ត ។ លោកពោលវេលាចូលនិរោធទុកក្នុងខាងក្រោយហើយ ដោយប្រការដូច្នេះ ។ ក្នុងទីនេះ លោកពោលដល់វេលាចេញចាកនិរោធ ។

---

១ អដ្ឋកថា បុព្វេ ច តថា ចិត្តំ ភាវិតំ ហោតិ (យកតាមបិដក) ។

ឥឡូវនេះ លោកគប្បីពោលនិរោធកថាថា កាលៈ ដើម្បីនឹងពោលនិរោធកថា ។ ក៏និរោធកថានេះ លោកតាំងជាមាតិកាថា បញ្ញាដែលអប់រំដរាបជំនាញ ដោយការស្ងប់ម្ងាប់សង្ខារ ៣ ព្រោះប្រកបដោយពលៈ ២ ដោយការប្រព្រឹត្តក្នុងញាណ (ញាណចរិយា) ១៦ ដោយការប្រព្រឹត្តក្នុងសមាធិ (សមាធិចរិយា) ៩ ជាញាណក្នុងនិរោធសមាបត្តិ ដែលពោលទុកក្នុងវិសុទ្ធិមគ្គ ដោយអាការទាំងពួងហើយ ព្រោះដូច្នោះ អ្នកសិក្សាគប្បីកាន់យកដោយន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះចុះ ។

សួរថា ឈ្មោះថា និរោធនេះ ដូចម្តេច? ។

ឆ្លើយថា ការពិចារណាខន្ធ ៤ ហើយ មិនប្រព្រឹត្តទៅ ។

សួរថា បើដូច្នោះ ពួកភិក្ខុរមែងចូលនិរោធនោះ ដើម្បីប្រយោជន៍អ្វី? ។

ឆ្លើយថា រមែងចូល ដើម្បីប្រយោជន៍នេះថា ពួកយើង (ធ្លាប់) ជាអ្នកអផ្សុក (ធុញទ្រាន់) ក្នុងការប្រព្រឹត្តទៅនៃសង្ខារទាំងឡាយ (ឥឡូវនេះ) នឹងជាអ្នកមិនមានចិត្ត នៅជាសុខរហូតអស់ ៧ ថ្ងៃ និរោធនេះ ឈ្មោះថា **ទិដ្ឋធម្មនិព្វាន** (និព្វានក្នុងបច្ចុប្បន្ន) ។

[២០៩] បទថា **ចិត្តសង្ខារកើតមុន** (**ចិត្តសង្ខារោ បឋមំ ឧប្បជ្ជតិ**)

សេចក្ដីថា ក៏កាលភិក្ខុចេញចាកនិរោធ ចិត្ត គឺ ផលសមាបត្តិរមែងកើតឡើង មុន ។ ព្រះកាមភូសំដៅដល់សញ្ញា និងវេទនា ដែលសម្បយុត្តដោយចិត្ត គឺ ផលសមាបត្តិនោះឯង ទើបពោលថា **ចិត្តសង្ខារោ បឋមំ ឧប្បជ្ជតិ** ។ បទថា **តអំពីនោះ កាយសង្ខារ (តតោ កាយសង្ខារោ)** សេចក្ដីថា តពីនោះ កាយសង្ខារ រមែងកើតឡើងក្នុងភវង្គសម័យ ។

សួរថា ក៏ផលសមាបត្តិ រមែងមិនញ៉ាំងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញឲ្យកើតឡើងឬ ឆ្លើយថា ឲ្យកើតឡើង ។ ប៉ុន្តែថា ផលសមាបត្តិរបស់ភិក្ខុប្រកបដោយចតុត្ថជ្ឈាន ផលសមាបត្តិនោះ ទើបមិនញ៉ាំងខ្យល់អស្សាសបស្សាសៈឲ្យតាំងឡើង ប្រយោជន៍អ្វីដោយខ្យល់អស្សាសបស្សាសៈនោះ ផលសមាបត្តិសូម្បីនឹងមានក្នុងបឋមជ្ឈានក៏ដោយ ក្នុងទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានក៏ដោយ ចូរលើកទុក ។ កាលភិក្ខុចេញចាកសមាបត្តិហើយ ខ្យល់អស្សាសបស្សាសៈ រមែងជាអព្យោហារិកៈ (មានដូចមិនមាន) ។ ការដែលខ្យល់អស្សាសបស្សាសៈទាំងនោះ ជាអព្យោហារិកៈ គប្បីជ្រាបបានដោយរឿងរបស់ព្រះសញ្ជីវត្ថេរ ។

ក៏កាលព្រះសញ្ជីវត្ថេរ ចេញចាកសមាបត្តិហើយ ទន្ទ្រាន ដើរលើរងើកភ្លើងប្រាសចាកអណ្ដាតភ្លើងដូចផ្កាចារ សូម្បីអណ្ដាតភ្លើង ក៏មិនឆេះ

ចីវរ ឬថា អាការនៃចំហាយក្តៅក៏មិនមាន ។ គេចិអាចារ្យ រមែងពោលថា នោះឈ្មោះថា ផលរបស់សមាបត្តិ ។ លោកសំដៅយ៉ាងនេះឯង ទើបពោលថា កាលភិក្ខុចេញចាកផលសមាបត្តិ ខ្យល់អស្សាសបស្សាសៈ ក៏ជាអព្វោ-ហារិកៈ ព្រោះហេតុដូច្នោះ គប្បីជ្រាបថា លោកពោលដោយកវត្តសម័យប៉ុណ្ណោះ ។

បទថា **តពីនោះ វចីសង្ខារ (តតោ វចីសង្ខារោ)** សេចក្តីថា តពីនោះ វចីសង្ខាររមែងកើតឡើង ក្នុងវេលាស្វែងរកការប្រព្រឹត្ត ដែលសម្រេចដោយកិរិយា ។ សួរថា កវត្ត រមែងមិនញុំាងវិតក្កវិចារៈឲ្យកើតឡើងឬ ឆ្លើយថា ឲ្យកើតឡើង ។ តែវិតក្កវិចារៈ ដែលមានកវត្តនោះជាសមុដ្ឋាន រមែងមិនអាចដើម្បីទឹងតាក់តែងវាចាបាន ព្រោះដូច្នោះ ពាក្យនោះ លោកក្នុងវេលាស្វែងរកការប្រព្រឹត្តដែលសម្រេចដោយកិរិយា ។

[២១០] ផស្សៈ ៣ មានជាដើមថា **សុញ្ញផស្សៈ (សុញ្ញតោ ផស្សោ)** គប្បីពោលដោយគុណខ្លះ ដោយអារម្មណ៍ខ្លះ ។ ពោលដោយគុណមុនផលសមាបត្តិ ឈ្មោះថា **សុញ្ញតា** លោកពោលថា សុញ្ញតផស្សៈ សំដៅដល់ ផស្សៈដែលកើតព្រមជាមួយផលសមាបត្តិនោះ សូម្បីក្នុងអនិមិត្តផស្សៈ និងអប្បណិហិតផស្សៈ ក៏ន័យនេះដូចគ្នា ។

ចំណែកពោលដោយអារម្មណ៍ និព្វាន ឈ្មោះថា សុញ្ញតៈ ព្រោះសូន្យចាកកិលេស មានរាគៈជាដើម ។ ឈ្មោះថា អនិមិត្តៈ ព្រោះមិនមានរាគៈជានិមិត្តជាដើម ។ ឈ្មោះថា អប្បណិហិតៈ ព្រោះមិនមានទីតាំងនៃរាគៈ ទោសៈ និងមោហៈ ។ ការពាល់ត្រូវក្នុងផលសមាបត្តិដែលកើតឡើង ឈ្មោះថា សុញ្ញតៈ ព្រោះធ្វើសុញ្ញតនិព្វានឲ្យជាអារម្មណ៍ ។ ក្នុងអនិមិត្តៈ និងអប្បណិហិតៈ ក៏មានន័យនេះដូចគ្នា ។

ឈ្មោះថា កថាជាទីមក ក៏មានដទៃទៀត ។ ពិតណាស់ សូម្បីវិបស្សនា លោកក៏ហៅថា សុញ្ញតៈ អនិមិត្តៈ និងអប្បណិហិតៈ ។

បណ្ដាបទទាំងនោះ ភិក្ខុណា កំណត់សង្ខារទាំងឡាយដោយជារបស់មិនទៀង ឃើញថាមិនទៀង រមែងចេញចាកការមិនទៀង វិបស្សនាដែលជាវុដ្ឋានគាមិនីរបស់ភិក្ខុនោះ រមែងឈ្មោះថា អនិមិត្តៈ ។ ភិក្ខុណា កំណត់ដោយភាពជាទុក្ខ ឃើញថាជាទុក្ខ រមែងចេញចាកសេចក្ដីទុក្ខ វិបស្សនារបស់ភិក្ខុនោះ រមែងឈ្មោះថា អប្បណិហិតៈ ។ ភិក្ខុណា កំណត់ដោយភាពជាអនត្តា ឃើញថាជាអនត្តា រមែងចេញចាកភាពអនត្តា វិបស្សនារបស់ភិក្ខុនោះ រមែងឈ្មោះថា សុញ្ញតៈ ។ បណ្ដាបទទាំងនោះ មគ្គរបស់អនិមិត្តវិបស្សនា ឈ្មោះថា អនិមិត្ត , ផលរបស់អនិមិត្តមគ្គ ឈ្មោះថា អនិមិត្ត ។

*កាលផស្សៈ ដែលកើតព្រមជាមួយអនិមិត្តផលសមាបត្តិ ពាល់ត្រូវហើយ លោកហៅថា អនិមិត្តផស្សៈរមែងពាល់ត្រូវ ។ សូម្បីក្នុងអប្បណិហិតៈ និង សុញ្ញតៈ ក៏មានន័យនេះដូចគ្នា ។ កាលលោកពោល ដោយការមក គប្បី ពោលដល់ការកំណត់ថា សុញ្ញតផស្សៈ អនិមិត្តផស្សៈ ឬអប្បណិហិតផស្សៈ ព្រោះដូច្នោះ អ្នកតាំងនៅដោយកថាជាទីមក គប្បីពោលដោយគុណ និង ដោយអារម្មណ៍ ។ ក៏ផស្សៈទាំងឡាយ ៣ រមែងពាល់ត្រូវយ៉ាងនេះ ដូច្នោះ ទើបសមគួរ ។*

[២១១] *និព្វាន ឈ្មោះថា វិវេក ក្នុងបទជាដើមថា* ***បង្អោនទៅ កាន់វិវេក (វិវេកនិន្នំ)*** *។ ឈ្មោះថា* ***វិវេកនិន្នំ*** *ព្រោះអត្ថថា បង្អោនទៅ គឺ បង្អោនទៅក្នុងវិវេកនោះ ។ បទថា* ***វិវេកបោណំ*** *ព្រោះអត្ថថា តាំងនៅដូច ការទេរទៅ ដោយហេតុនៃវិវេកដែលមកពីដទៃ ។ ឈ្មោះថា* ***វិវេកបព្ភារំ*** *ព្រោះអត្ថថា តាំងនៅដូចជាជ្រេទៅ ដោយហេតុនៃវិវេក ។*

ចប់អដ្ឋកថា ទុតិយកាមភូសូត្រទី ៦

# អ ដ្ឋ ក ថា

## គោទត្តសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង គោទត្តសូត្រទី ៧ ដូចតទៅនេះ ៖

[២១៣] បទថា មានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា (នានត្ថា ចេវ នានាព្យញ្ជនា ច) គឺ សូម្បីព្យញ្ជនៈនៃធម៌ទាំងនោះ ផ្សេងគ្នា សូម្បីអត្ថក៏ផ្សេងគ្នា ។ ក្នុងសេចក្តីផ្សេងគ្នានោះ សេចក្តីផ្សេងគ្នានៃព្យញ្ជនៈ ប្រាកដច្បាស់ហើយ ។ ចំណែកសេចក្តីផ្សេងគ្នាដោយអត្ថ ដូច្នេះ អប្បមាណា-ចេតោវិមុត្តិ ពោលដោយភូមិ ជាមហគ្គតៈ ជារូបាវចរៈ ដោយអារម្មណ៍ មានសត្វបញ្ញត្តិជាអារម្មណ៍ ។ អាកិញ្ចញ្ញាចេតោវិមុត្តិ ដោយភូមិ ជាមហ-គ្គតៈ ជាអរូបាវចរៈ ដោយអារម្មណ៍ មានអារម្មណ៍មិនគប្បីពោល (គឺបញ្ញត្តិ) ។ សុញ្ញតាចេតោវិមុត្តិ ដោយជាភូមិ ជាកាមាវចរៈ ដោយអារម្មណ៍ មានសង្ខារជាអារម្មណ៍ ។ ចំណែកវិបស្សនា លោកបំណងថា សុញ្ញតា ក្នុងទីនេះ ។ អនិមិត្តាចេតោវិមុត្តិ ដោយភូមិ ជាលោកុត្តរៈ ដោយអារម្មណ៍ មាននិព្វានជាអារម្មណ៍ ។

[២១៤] ក្នុងបទមានជាដើមថា រាគៈ ឈ្មោះថា កិលេសជាគ្រឿង

ធ្វើប្រមាណ (រាគោ ខោ ភន្តេ បមាណករណោ) លោកពោលកិលេសជាគ្រឿងធ្វើប្រមាណទុកថា ឈ្មោះថា ទឹកជ្រៅ ព្រោះស្លឹកឈើរលួយ មានពណ៌ខ្មៅនៅត្រង់ជើងភ្នំ កាលសម្លឹងមើលរមែងប្រាកដ ដូចទឹកជ្រៅរយព្យាម កាលកាន់យកឈើ ឬម៉ែត្រវាស់ ទឹកត្រឹមតែលិចខ្នងជើងក៏មិនបានយ៉ាងណា ។ រហូតអស់វេលាដែលរាគៈជាដើម មិនទាន់កើតឡើង នរណាៗរមែងមិនអាចនឹងស្គាល់បុគ្គលនោះបាន គេរមែងប្រាកដស្រដៀងព្រះសោតាបន្ន ស្រដៀងព្រះសកទាគាមិ ស្រដៀងព្រះអនាគាមី តែកាលណារាគៈជាដើម កើតឡើងដល់គេ កាលនោះ គេប្រាកដថា ពេញចិត្ត ទាស់ចិត្តវង្វេង ដូច្នោះ ។ ដូច្នោះ រាគៈជាដើមទាំងនោះ កាលសម្តែងប្រមាណដល់ថា បុគ្គលនេះប្រមាណប៉ុណ្ណេះ រមែងកើតឡើង ។ បទថា **អប្បមាណាចេតោវិមុត្តិ មានប្រមាណប៉ុនណា (យាវតា ខោ ភន្តេ អប្បមាណា ចេតោវិមុត្តិយោ)** សេចក្តីថា អប្បមាណាចេតោវិមុត្តិមានប្រមាណប៉ុនណា ។

សួរថា ក៏អប្បមាណាចេតោវិមុត្តិទាំងនោះ មានប៉ុន្មាន ។

ឆ្លើយថា មាន ១២ គឺ ព្រហ្មវិហារ ៤ មគ្គ ៤ ផល ៤ ។ ក្នុង ១២ យ៉ាងនោះ ព្រហ្មវិហារ ឈ្មោះថា អប្បមាណា ព្រោះផ្សាយទៅរកប្រមាណមិនបាន ។ ធម៌ដ៏សេស (មគ្គ និងផល) គប្បីជ្រាបដូច្នេះ សូម្បីនិព្វាន ក៏

ឈ្មោះថា អប្បមាណា ដូចគ្នា ព្រោះកិលេសទាំងឡាយជាគ្រឿងធ្វើប្រមាណ មិនមាន ។ តែមិនឈ្មោះថា ចេតោវិមុត្តិ ព្រោះដូច្នោះ ទើបមិនកាន់យក ។ បទថា **មិនកម្រើក (អកុប្បា)** គឺ អរហត្តផលចេតោវិមុត្តិ ។ អរហត្តផល-ចេតោវិមុត្តិនោះ ជាប្រធានធម៌ទាំងអស់នៃអប្បមាណាចេតោវិមុត្តិទាំងនោះ ព្រោះដូច្នោះ លោកទើបពោលថា **អគ្គមក្ខាយតិ** ។ បទថា **រាគៈ ឈ្មោះថា កិលេស ជាគ្រឿងកង្វល់ (រាគោ ខោ ភន្តេ កិញ្ចនំ)** សេចក្តីថា រាគៈកើតឡើងហើយ រមែងកង្វល់ ញាំញី រមែងចងបុគ្គលទុក ព្រោះដូច្នោះ លោកទើបហៅថា **កិញ្ចនំ** (កិលេសជាគ្រឿងកង្វល់) ។ បានឮថា ពួកមនុស្សឲ្យគោទាំងឡាយបញ្ជាន់លាន ហើយនិយាយថា ក្រហមវិលទៅ ខ្មៅវិលទៅ គប្បីជ្រាបថា រាគៈ មានអត្ថថា ញាំញី មានអត្ថថា កង្វល់ ។ សូម្បីក្នុងទោសៈ និងមោហៈ ក៏មានន័យនេះដូចគ្នា ។ ធម៌ ៩ គឺ អាកិញ្ចញ្ញាយតនៈ ១ មគ្គ ៤ ផល ៤ ឈ្មោះថា អាកិញ្ចញ្ញាចេតោវិមុត្តិ ។ ក្នុងធម៌ទាំងនោះ អាកិញ្ចញ្ញាយតនៈ ឈ្មោះថា អាកិញ្ចញ្ញៈ ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ជាអារម្មណ៍ ។ មគ្គ និងផល ឈ្មោះថា អាកិញ្ចញ្ញៈ ព្រោះកិលេសជាគ្រឿងកង្វល់ គឺ កិលេសជាគ្រឿងញាំញី និងជាគ្រឿងចងមិនមាន ។ និព្វាន ក៏ជាអាកិញ្ចញ្ញៈ តែមិនមែនចេតោវិមុត្តិ ព្រោះដូច្នោះ លោកទើប

មិនកាន់យក ។ បទមានជាដើមថា *រាគៈ* ឈ្មោះថា កិលេសជាគ្រឿងធ្វើនិមិត្ត *(រាគោ ខោ ភន្តេ និមិត្តករណោ)* សេចក្តីថា ត្រកូលពីរ មានកូនគោពីរគូដូចៗ គ្នា បុគ្គលរមែងមិនអាចនឹងស្គាល់បានថា នេះកូនគោរបស់ត្រកូលឯណោះ នេះកូនគោរបស់ត្រកូលឯណោះ រហូតវេលាដែលគេមិនទាន់បានធ្វើគ្រឿងសម្គាល់ទុកត្រង់កូនគោទាំងនោះ តែកាលណាគេធ្វើគ្រឿងសម្គាល់ណាមួយ ដោយលំពែងមុខ ៣ ជាដើម ត្រង់កូនគោទាំងនោះ កាលនោះ បុគ្គលរមែងអាចស្គាល់បាន យ៉ាងណា រហូតវេលាដែលរាគៈមិនទាន់កើតឡើងដល់បុគ្គល បុគ្គលរមែងមិនអាចនឹងដឹងបានថា គេជាព្រះអរិយៈឬបុថុជ្ជន តែកាលរាគៈកើតឡើងដល់គេ រមែងកើតឡើងដូចជាធ្វើនូវគ្រឿងសម្គាល់ឲ្យដឹងបានថា បុគ្គលនេះ ឈ្មោះថា នៅមានរាគៈ ព្រោះដូច្នោះលោកទើបពោលរាគៈថា ជាគ្រឿងធ្វើនូវនិមិត្ត ។ សូម្បីក្នុងទោសៈ និងមោហៈ ក៏មានន័យនេះដូចគ្នា ។

ធម៌ ១៣ គឺ វិបស្សនា ១ អរូប ៤ មគ្គ ៤ ផល ៤ ឈ្មោះថា អនិមិត្តាចេតោវិមុត្តិ ។ ក្នុងធម៌ ១៣ នោះ វិបស្សនា ឈ្មោះថា អនិមិត្តៈ ព្រោះអត្ថថា ដកនិមិត្តថាទៀង ថាសុខ ថាខ្លួនចេញបាន ។ អរូប ៤ ឈ្មោះថា អនិមិត្ត ព្រោះមិនមានរូបនិមិត្ត ។ មគ្គ និងផល ឈ្មោះថា អនិមិត្ត

ព្រោះមិនមានកិលេសជាគ្រឿងធ្វើនូវនិមិត្ត ។ សូម្បីនិព្វាន ក៏ជាអនិមិត្ត ប៉ុណ្ណោះ ។ តែលោកមិនកាន់យកនិព្វាននោះ ព្រោះមិនមែនចេតោវិមុត្តិ ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វី លោកទើបមិនកាន់យកសុញ្ញតាចេតោ-វិមុត្តិ ។ ឆ្លើយថា សុញ្ញតាចេតោវិមុត្តិនោះ មិនបាត់ចូលក្នុងធម៌ទាំងពួង ព្រោះបាលីថា **សុញ្ញា រាគេន** ជាដើម ព្រោះដូច្នោះ លោកចែកទុកមិនកាន់យក ។ បទថា **មានអត្ថតែមួយដូចគ្នា** (ឯកត្ថា) សេចក្តីថា មានអត្ថតែម្យ៉ាងដូចគ្នា ដោយអំណាចនៃអារម្មណ៍ ។ ក៏បទទាំងនោះ គឺ អប្បមាណៈ អាកិញ្ចញ្ញៈ សុញ្ញតៈ អនិមិត្តៈ ទាំងអស់ ជាឈ្មោះរបស់និព្វានទុំះឯង ។ ដោយបរិយាយយ៉ាងនេះ ទើបមានអត្ថតែមួយដូចគ្នា ។ តែព្យញ្ជនៈផ្សេងគ្នា ដោយបរិយាយនេះថា ក៏ក្នុងកន្លែងមួយ ជាអប្បមាណា ក្នុងកន្លែងមួយ ជាអាកិញ្ចញ្ញា ក្នុងកន្លែងមួយជាសុញ្ញតា ក្នុងកន្លែងមួយជាអនិមិត្តា ។

ចប់អដ្ឋកថា គោទត្តសូត្រទី ៧

# អ ដ្ឋ ក ថា

## និគណ្ឋសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង និគណ្ឋសូត្រទី ៨ ដូចតទៅនេះ ៖

[២១៩] បទថា ចូលទៅរក (តេនុបសង្កមិ) សេចក្តីថា សួរថា ចិត្តគហបតីជាអរិយសាវក ថ្នាក់អនាគាមីបុគ្គល ដែលមានអាគមដល់ហើយ ដឹងពាក្យទូន្មានជាក់ច្បាស់ហើយ ហេតុអ្វី ទើបចូលទៅរកនិគ្រន្ថអាក្រាតកាយ មិនមានសិរីមង្គលហ្ន៎ ។ ឆ្លើយថា ដើម្បីដោះវាទៈអាក្រក់ និងដើម្បីលើកវាទៈ ។ បានឮថា ពួកនិគ្រន្ថ រមែងចូលទៅលើកវាទៈអាក្រក់ថា ពួកសាវករបស់សមណគោតម ដូចជាជន្លត់ឈើគគីដ៏រឹង រមែងមិនធ្វើបដិសណ្ឋារជាមួយនរណាឡើយ ចិត្តគហបតីចូលទៅរកហើយ ដើម្បីដោះវាទៈអាក្រក់នោះ និងគិតថា យើងនឹងលើកវាទៈជាមួយនិគ្រន្ថនោះ ដូច្នេះ ។ បទថា លោកដ៏ចម្រើន ខ្ញុំមិនបានជឿចំពោះព្រះមានព្រះភាគ ក្នុងសេចក្តីនេះ (ន ខ្វាហំ ឯត្ថ ភន្តេ ភគវតោ សទ្ធាយ គច្ឆាមិ) លោកសម្តែងថា បុគ្គលណា រមែងមិនធ្វើឲ្យច្បាស់ដោយញាណ បុគ្គលនោះគប្បីជឿចំពោះបុគ្គលដទៃថា បានឮថា វត្ថុនោះជាយ៉ាងនោះ តែវត្ថុនោះ ដែលយើងធ្វើឲ្យ

ច្បាស់ហើយដោយញាណ ។ ព្រោះដូច្នោះ ខ្ញុំទើបមិនជឿចំពោះព្រះមាន-ព្រះភាគ ក្នុងសេចក្តីនេះ ដូច្នេះ ទើបពោលយ៉ាងនេះ ។

[២២០] បទថា ក្រឡេកមើល (អបលោកេត្វា) សេចក្តីថា បង្អោនកាយចូលទៅ ដែទប់ពោះ ដក.កសម្លឹងមើលទៅក្នុងទិសទាំងពួង ។ បទថា យល់ថា គប្បីបៀតបៀន (ពាធេតព្វំ មញ្ញេយ្យ) សេចក្តីថា ចិត្តគហបតីនោះ គប្បីយល់ថា គប្បីហាមខ្យល់ ឬគប្បីចងទុកដោយសំណាញ់ ដោយប្រការដែលខ្យល់នឹងចេញទៅមិនបាន ដូច្នោះ ។

[២២១] បទថា មានហេតុផល (សហធម្មិកា) គឺ ព្រមដោយហេតុ ។ បទថា ក៏សូមប្រាប់ខ្ញុំ ព្រមទាំងបរិស័ទ (អថ មំ បដិហរេយ្យាសិ សទ្ធឹ និគ្គណ្ឋបរិសាយ) សេចក្តីថា កាលលោកដឹងអត្ថនៃបញ្ហាទាំងនោះហើយ គប្បីប្រាប់ដល់និគ្រន្ថបរិស័ទមុន លោកមកកាន់សម្នាក់របស់យើងដែលបានឆ្លើយឆ្លងហើយ គប្បីប្រកាសឲ្យបរិស័ទដឹងថា ខ្ញុនមកហើយ ដូច្នេះ ។ បទថា ប្រស្នាមួយ (ឯកោ បញ្ហោ) គឺ មគ្គបញ្ហាមួយ ។ អធិប្បាយថា ការស្វែងរកប្រស្នាមួយ ។ បទថា ឧទ្ទេសមួយ (ឯកោ ឧទ្ទេសោ) គឺ អ្វីឈ្មោះថាមួយ ។ មួយនេះ គឺ ឧទ្ទេស ។ បទថា វេយ្យាករណ៍មួយ (ឯកំ ព្យា-ករណំ) សេចក្តីថា ពាក្យនេះថា សត្វទាំងឡាយទាំងពួង តាំងនៅបានដោយ

*អាហារ ឈ្មោះថា វេយ្យាករណ៍មួយ ៗ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួង យ៉ាងនេះ ៗ*

ចប់អដ្ឋកថា និគណ្ឋសូត្រទី ៨

# អ ដ្ឋ ក ថា

## អចេលសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង អចេលសូត្រទី ៩ ដូចតទៅនេះ ៖

[២២២] បទថា **បួសមកយូរប៉ុន្មាន (កីវចិរ បព្វជិតោ)** សេចក្តីថា វេលាយូរប៉ុនណា ។ បទថា **ឧត្តរិមនុស្សធម៌ (ឧត្តរិមនុស្សធម្មា)** គឺ កុសលកម្មបថ ១០ ឈ្មោះថា មនុស្សធម៌ ។ ក្រៃលែងជាងមនុស្សធម៌នោះ ឈ្មោះថា ឧត្តរិមនុស្សធម៌ ។ បទថា **ញាណទស្សនវិសេសដ៏កំពូលយ៉ាងសម្បូរ (អលមរិយញ្ញាណទស្សនវិសេសោ)** សេចក្តីថា ញាណទស្សនវិសេស ពោលគឺ អលមរិយធម៌ ព្រោះអាចធ្វើភាពជាអរិយៈ ។ បទថា **ការប្រព្រឹត្តអាក្រាត (នគ្គេយ្យ)** គឺ ចាកភាពជាបុគ្គលអាក្រាត ។ បទថា **ជាបុគ្គលត្រងោល (មុណ្ឌេយ្យ)** គឺ ចាកភាពជាបុគ្គលត្រងោល ។ បទថា **វាឡនិប្បោតនាយ** គឺ ចាកការបោសធូលី អធិប្បាយថា កាលគេអង្គុយលើផែនដី ក៏ត្រឹមតែកាន់យកកន្ទុយសត្វក្ងោក ដើម្បីបោសធូលី និងខ្សាច់ដែលជាប់ត្រង់ជិតទីអង្គុយ ។

ចប់អដ្ឋកថា អចេលសូត្រទី៩

# អ ដ្ឋ ក ថា

## គិលានសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង គិលានសូត្រទី ១០ ដូចតទៅនេះ ៖*

[២២៥] *បទថា* ***អារាមទេវតា*** *សេចក្តីថា ពួកទេវតាដែលស្ថិតនៅក្នុងសួនឈើមានផ្កា និងសួនឈើផ្លែ ។ បទថា* ***វនទេវតា*** *គឺ ទេវតាដែលស្ថិតនៅក្នុងដងព្រៃ ។ បទថា* ***រុក្ខទេវតា*** *សេចក្តីថា វេស្សវណទេវតាក្នុងកាលនៃព្រះបាទមត្តរាជ ពួកទេវតា ដែលស្ថិតនៅព្រួដ៏ដើមឈើទាំងនោះយ៉ាងនេះ ។ បទថា* ***ដើមឈើដែលជាថ្នាំ និងស្តេចឈើ (ឱសធិតិណ-វនប្បតិ)*** *សេចក្តីថា ពួកទេវតាដែលស្ថិតនៅលើដើមសម៉ និងកន្ទួតព្រៃជាដើម លើស្មៅដំណេកទន្សាយ និងស្មៅយាប្លង់ជាដើម និងលើដើមឈើដែលជាមេព្រៃ ។*

*បទថា* ***ប្រជុំ (សង្គម្ម)*** *គឺ ប្រជុំព្រមគ្នាហើយ ។ បទថា* ***មករួម (សមាគម្ម)*** *គឺ មកព្រមគ្នាហើយអំពីទីនោះៗ ។ បទថា* ***ចូរប្រាថ្នា (បណិ-ធេហិ)*** *សេចក្តីថា លោកចូរតាំងសេចក្តីប្រាថ្នា ។*

[២២៦] *បទថា* ***ការប្រាថ្នាដោយចិត្តរបស់អ្នកមានសីលនេះ នឹងបាន***

សម្រេច (ឥជ្ឈិស្សតិ សីលវតោ ចេតោបណិធិ) សេចក្តីថា សេចក្តីប្រាថ្នានៃចិត្តនឹងសម្រេចដល់លោកអ្នកមានសីល ។ បទថា បុគ្គលប្រកបដោយធម៌ (ធម្មិកោ) អ្នកប្រកបដោយកុសលធម៌ ១០ គឺ មិនដល់អគតិ ។ បទថា ធម្មរាជា ជាវេវចនៈ របស់បទថា ធម្មិកោ នោះឯង ។ មួយទៀត ឈ្មោះថា ធម្មរាជា ព្រោះរាជសម្បត្តិដែលព្រះអង្គទ្រង់បានមកដោយធម៌ ។

[២២៧] បទថា ដូច្នោះ (តស្មា) សេចក្តីថា បពិត្រលោកដ៏ចម្រើន លោកជានាយបុត្រ បើយ៉ាងនោះ សូមលោកទាំងឡាយ ចូរពោលទូន្មានពួកខ្ញុំដោយឱវាទជាដើមចុះ ។ បទថា ជារបស់គួរបែងចែក (អប្បដិវិភត្តំ) សេចក្តីថា ទេយ្យធម៌ដែលបែងចែកគ្នាហើយ យ៉ាងនេះថា ពួកយើងនឹងថ្វាយវត្ថុនេះដល់ពួកភិក្ខុ យើងនឹងបរិភោគវត្ថុនេះដោយខ្លួន ដូច្នេះ នឹងជារបស់ទូទៅជាមួយពួកភិក្ខុ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា គិលានសូត្រទី ១០

## ចប់ចិត្តគហបតិបុច្ឆាសំយុត្ត

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថា សំយោជនសូត្រ
២-អដ្ឋកថា បឋមឥសិទត្តសូត្រ
៣-អដ្ឋកថា ទុតិយឥសិទត្តសូត្រ
៤-អដ្ឋកថា មហកសូត្រ
៥-អដ្ឋកថា បឋមកាមភូសូត្រ
៦-អដ្ឋកថា ទុតិយកាមភូសូត្រ
៧-អដ្ឋកថា គោទត្តសូត្រ
៨-អដ្ឋកថា និគណ្ឋសូត្រ
៩-អដ្ឋកថា អចេលសូត្រ
១០-អដ្ឋកថា គិលានសូត្រ

# គាមណិសំយុត្ត

## អ ដ្ឋ ក ថា

### ចណ្ឌសូត្រទី ១

*ចណ្ឌសូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[២២៨] បទថា **ចណ្ឌោ គាមណិ** សេចក្តីថា បុរសអ្នកស្រុកម្នាក់ ដែលព្រះធម្មសង្គាហកត្ថេរ ហៅឈ្មោះថា ចណ្ឌៈ ។ ដោយបទថា **សម្តែងឲ្យប្រាកដ (បាតុករោតិ)** លោកសម្តែងថា គេឈ្មោះ ក៏ឈ្មោះតប គេជេរ ក៏ជេរតប គេប្រហារ ក៏ប្រហារតប ឈ្មោះថា ធ្វើឲ្យប្រាកដ ។ ដោយបទថា **មិនធ្វើឲ្យប្រាកដ (ន បាតុករោតិ)** លោកសម្តែងថា សូម្បីត្រូវជេរ ក៏មិនធ្វើខ្លួនជាសត្រូវអ្វីៗ ។*

ចប់អដ្ឋកថា ចណ្ឌសូត្រទី ១

# អ ដ្ឋ ក ថា

## តាលបុត្តសូត្រទី ២

*តាលបុត្តសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[២៣១] *បទថា តាលបុត្ត (តាលបុត្តោ) គឺ គេមានឈ្មោះយ៉ាងនោះ ។ បានឮមកថា បុរសស្រុកម្នាក់ជាអ្នករបាំនោះ មានពណ៌សម្បុរថ្លាផូរផង់ដូចផ្លែត្នោតទុំដែលជ្រុះចាកទង ។ ដោយហេតុនោះ អ្នកទាំងឡាយទើបតាំងឈ្មោះគេថា តាលបុត្រ នាយតាលបុត្រនោះ ដល់ព្រមដោយអភិនិហារ (បុណ្យចាស់) ជាបុគ្គលកើតក្នុងកពចុងក្រោយ (មិនកើតទៀត) ។ តែព្រោះធម្មតាបដិសន្ធិយកពិតប្រាកដមិនបាន ដូចកំណាត់ឈើដែលបោះទៅក្នុងអាកាស ដូច្នោះ នាយតាលបុត្រនេះទើបកើតក្នុងត្រកូលអ្នករបាំ ពេលចម្រើនវ័យក៏ជាកំពូលខាងសិល្បៈរបាំ មានឈ្មោះល្បីសុះសាយទូទៅទាំងជម្ពូទ្វីប ។ គេមានរទេះ ៥០០ ក្បាល មានស្រីមេផ្ទះ ៥០០ នាក់ ជាបរិវារ សូម្បីគេក៏មានកិរិយាចំនួនប៉ុណ្ណោះ ដូច្នោះ គេព្រមជាមួយនឹងស្ត្រី ១.០០០ នាក់ និងរទេះ ១.០០០ អាស្រ័យនៅនគរ ឬនិគមណាៗ ប្រជាជនក្នុងនគរ ឬនិគមនោះៗ នាំគ្នាឲ្យទ្រព្យមួយសែនដល់គេមុនៗ*

កាលគេតែងខ្លួន សម្ដេចមហោស្រព កំពុងលេងកីឡាជាមួយស្ត្រី ១.០០០ នាក់ ប្រជាជនទាំងឡាយ បោះគ្រឿងប្រដាប់ដៃជើងជាដើមជាវង្វាន់ឲ្យមិនដាច់ ។ ថ្ងៃនោះ គេហែហមដោយស្ត្រី ១.០០០ នាក់ លេងកីឡាក្នុងក្រុងរាជគ្រឹះ ព្រោះមានញាណចាស់ក្លា ព្រមដោយបរិវារទាំងអស់ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

[២៣២] បទថា *សច្ចាលិកេន* បានដល់ ដោយពាក្យពិតខ្លះ ដោយពាក្យកុហកខ្លះ ។ បទថា *រឿងនេះចូរលើកទុកចុះ (តិដ្ឋតេតំ))* សេចក្ដីថា ប្រការនោះ ចូរលើកទុកចុះ ។

[២៣៣] បទថា *ដែលជាទីតាំងនៃតម្រេក (រជនីយា)* បានដល់ កលមាយា សម្ដែងខ្យល់លាយភ្លៀង ផ្លុំអំបោះប្រាំពណ៌ចេញចាកមាត់ ដែលជាបច្ច័យនៃរាគៈ និងន័យដ៏ក្រៃលែងៗ យ៉ាងដទៃទៀត ដែលសម្ដែងអាការប្រកបដោយសេចក្ដីត្រេកអរក្នុងកាម ។ បទថា *ក្រៃលែងឡើង (ភិយ្យោសោមត្តាយ)* បានដល់ ដោយប្រមាណក្រៃលែង ។ បទថា *ដែលជាទីតាំងនៃទោសៈ (ទោសនិយា)* បានដល់ អាការដែលសម្ដែងកលមាយា មានការកាត់ដៃ និងជើងជាដើម ដែលជាបច្ច័យនៃទោសៈ ។ បទថា *ជាទីតាំងនៃមោហៈ (មោហនិយា)* បានដល់ កលមាយា ប្រភេទយកទឹកធ្វើប្រេង

យកប្រេងធ្វើទឹក យ៉ាងនេះជាដើម ដែលជាបច្ច័យនៃមោហៈ ។ បទថា នរក ឈ្មោះបហាសៈ (បហាសោ នាម និរយោ) សេចក្តីថា ធម្មតា នរកដែលឈ្មោះថា បហាសៈ មិនមែនជានរកមួយផ្សេងដទៃ តែជាចំណែកមួយរបស់អវិចីនុ៎ះឯង ដែលពួកសត្វតែងខ្លួនជាអ្នករបាំ រាំ និងច្រៀង នាំគ្នាឆេះហើយលោកពោលសំដៅយកនរកនោះ ។

[២៣៤] ក្នុងបទថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានយំដល់ (នាហំ ភន្តេ ឯតំ រោទាមិ) នេះ គប្បីជ្រាបន័យដោយអំណាចសកម្មកិរិយា យ៉ាងនេះថា ខ្ញុំព្រះអង្គមិនបានយំដល់ការព្យាករណ៍របស់ព្រះមានព្រះភាគក្នុងប្រការនោះទេ ព្រះអង្គ ។

មួយទៀត ក្នុងប្រការថា ជនទាំងឡាយប្រោះព្រួដល់អ្នកស្លាប់ មានទឹកភ្នែកហូរ យំស្រែកជាដើមនេះ គប្បីជ្រាបថា ជាវោហារម្យ៉ាងទៀត ។

ចប់អដ្ឋកថា តាលបុត្តសូត្រទី ២

# អ ដ្ឋ ក ថា

## យោធាជីវសូត្រទី ៣

ក្នុងយោធាជីវសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២៣៥] បទថា **អ្នកចិញ្ចឹមជីវិតដោយចម្បាំង** (យោធាជីវោ) សេចក្តីថា អ្នកចិញ្ចឹមជីវិតដោយការច្បាំង ព្រះធម្មសង្គាហកត្ថេរ តាំងឈ្មោះទុកយ៉ាងនេះ ។ បទថា **ឧស្សាហ៍ព្យាយាម** (ឧស្សហតិ វាយមតិ) បានដល់ធ្វើសេចក្តីឧស្សាហ៍ព្យាយាម ។ បទថា **បរិយាបាទេន្តិ** បានដល់ ឲ្យដល់សេចក្តីស្លាប់ ។ បទថា **ធ្វើទុកមិនល្អ** (ទុក្កដំ) បានដល់ ធ្វើចិត្តទុកមិនល្អ ។ បទថា **ទុប្បណិហិតំ** បានដល់ តាំងចិត្តទុកមិនល្អ ។ បទថា **នរកឈ្មោះសរជិ** (សរជិតោ នាម និរយោ) សេចក្តីថា សូម្បីនរកឈ្មោះសរជិតនេះ ក៏មិនមែននរកមួយដទៃផ្សេង តែជាចំណែកមួយរបស់អវិចីនុ៎ះឯង ដែលពួកអ្នកមានអាជីវៈជាអ្នកច្បាំង ស្ពាយអាវុធ ៥ យ៉ាង កាន់ខែលឡើងជិះសេះ រថដូចគ្រោះនៅក្នុងសមរភូមិច្បាំង ឆេះភ្លើងហើយ ប្រការនេះលោកពោលសំដៅយកនរកនោះ ។

ចប់អដ្ឋកថា យោធាជីវសូត្រទី ៣

# អ ដ្ឋ ក ថា

## ហត្ថារោហសូត្រទី ៤ និង អស្សារោហសូត្រទី ៥

*សូម្បីក្នុងសូត្រទី ៤ និងសូត្រទី ៥ ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា សូត្រទី ៤-៥

# អដ្ឋកថា

## អសិពន្ធកបុត្តសូត្រទី ៦

*អសិពន្ធកបុត្តសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[២៤០] *បទថា* ***ស្រុកបច្ឆាភូមិ*** *(បច្ឆាភូមកា) ប្រែថា អ្នកនៅក្នុងស្រុកបច្ឆាភូមិ ។ បទថា* ***មានកំសៀវទឹកជាប់ខ្លួន*** *(កាមណ្ឌលុកា) ប្រែថា មានកំសៀវទឹកប្រចាំខ្លួន ។ បទថា* ***ប្រដាប់កាយដោយសារាយ*** *(សេវាលមាលិកា) សេចក្ដីថា ព្រឹកឡើង ក៏យកសារាយខ្លះ ផ្កាឧប្បលជាដើមខ្លះអំពីទឹកធ្វើជាគ្រឿងប្រដាប់កាយ ដើម្បីឲ្យដឹងថា ជាអ្នកបរិសុទ្ធិដោយទឹក ។ បទថា* ***ងូតទឹករាល់ព្រឹក*** *(ឧទកោរោហកា) បានដល់ ជាអ្នកចុះត្រាំទឹក ។ បទថា* ***ឲ្យក្រោកឡើង*** *(ឧយ្យាបេន្តិ) ប្រែថា ឲ្យភ្ញាក់ឡើង ។ បទថា* ***ឲ្យដឹងខ្លួន*** *(សញ្ញាបេន្តិ) ប្រែថា ឲ្យដឹងដោយល្អ ។ បទថា* ***ចូរឲ្យឡើងឋានសួគ៌*** *(សគ្គំ នាម ឱក្កាមេន្តិ)[១] សេចក្ដីថា ឈរហែហមជវនឲ្យទៅកាន់សួគ៌ទៅព្រហ្មលោកចុះ លោកដ៏ចម្រើន ។ បទថា* ***អនុបរិសក្កេយ្យ*** *ប្រែថា ដើរវិលជុំវិញ ។*

---

*១-បិដក (សគ្គំ លោកំ ឧបបជ្ជេយ្យាតិ) , អដ្ឋកថាដូចខាងលើ ។*

[២៤១] បទថា **ឧម្មុជ្ជ** ប្រែថា ចូរងើបឡើងចុះ ។ បទថា **ថលមុប្ឫវ** ប្រែថា ចូរឡើងគោកចុះ ។

[២៤៣] បទថា **តត្រ យស្ស** សេចក្តីថា ដុំគ្រួសឬ ដុំថ្មណា គប្បីមានក្នុងថ្នាំងនោះ ។ បទថា **សក្ខរា វា កឋលា វា** ប្រែថា ដុំគ្រួស ឬដុំថ្ម ។ បទថា **សា អធោគាមី អស្ស** សេចក្តីថា ដុំគ្រួស ឬដុំថ្មនោះ គប្បីលិចចុះ គឺ គប្បីទៅខាងក្រោម ។ បទថា **អធោ គច្ឆ** ប្រែថា ចូរទៅខាងក្រោម ។

ចប់អដ្ឋកថា អសិពន្ធកបុត្តសូត្រទី ៦

# អ ដ្ឋ ក ថា

## ទេសនាសូត្រទី ៧

ក្នុង *ទេសនាសូត្រទី ៧* គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២៨៥] *បទថា* ***មានដីរឹង (ជង្គលំ)*** *បានដល់ ជាដីរឹងមិនទន់ ។ បទថា* ***ប្រៃ (ឱសរំ)*** *ជាដីមានរសប្រៃឯង ។ បទថា* ***ដីអាក្រក់ (បាបភូមិ)*** *ប្រែថា ជាផ្ទៃដីអាក្រក់ ។*

[២៨៦] *ក្នុងបទថា* ***មានតថាគតជាទីពឹង (មំទីបា)*** *ជាដើម មានវិនិច្ឆ័យថា ភិក្ខុ និងភិក្ខុនីទាំងនេះ ឈ្មោះថា* ***មំទីបា*** *ព្រោះពួកគេមានយើងតថាគតជាទីពឹង ជាទីអាស្រ័យ ។ ឈ្មោះថា* ***មានតថាគតជាទីជ្រកកោន (មំលេណា)*** *ព្រោះពួកគេមានតថាគតជាទីពួនសម្ងំ ជាទីជ្រកកោន ។ ឈ្មោះថា* ***មានតថាគតជាទីពំនាក់ (មំតាណា)*** *ព្រោះពួកគេមានតថាគតជាទីពំនាក់ ជាទីរក្សា ។ ឈ្មោះថា* ***មានតថាគតជាសរណៈ (មំសរណា)*** *ព្រោះពួកគេមានតថាគតជាសរណៈ ធ្វើភ័យឲ្យវិនាស ។ បទថា* ***ហើយ (វិហរន្តិ)*** *សេចក្តីថា ធ្វើតថាគតឲ្យជាទីពឹងជាដើម ដូច្នោះ ហើយនៅ ។ បទថា* ***ជាចំណីគោ (គោភត្តំបិ)*** *សេចក្តីថា ព្រោះមិនមានផលាហារ គឺ ស្រូវអង្ករ ទើបទាក់ទងនឹង*

(ពូជដែលព្រោះក្នុងស្រែអាក្រក់) ចងជាកណ្ដាប់ៗ រក្សាទុក គោទាំងឡាយនឹងបានទំពារស៊ីក្នុងរដូវប្រាំង ។

[២៨៧] បទថា ពាងទឹក (ឧទកមណិកោ) បានដល់ ភាជនៈពិសេសដែលមានឈ្មោះយ៉ាងនោះ ព្រោះមានខ្សែចងស្រោក់ត្រង់ពោះ ។ បទថា ទឹកជ្រាបមិនបាន (អហារិអបរិហារី) សេចក្ដីថា ទឹកជ្រាបចេញមិនបាន គឺ ធ្វើឲ្យអស់ទៅមិនបាន ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ការសម្ដែងធម៌ដោយគោរព ដោយប្រការដូច្នេះ ។ សេចក្ដីពិត ការសម្ដែងធម៌ដោយមិនគោរព រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះថា ព្រះពុទ្ធទាំងឡាយទ្រង់មានការប្រព្រឹត្តដូចរាជសីហ៍ រាជសីហ៍កាលចាប់ដំរីឈ្មោលដែលចុះប្រេងក្ដី ចាប់សត្វតូចៗ មានទន្សាយ និងឆ្មាជាដើមក្ដី រមែងប្រើញាំងភាពដ៏រហ័សដូចគ្នា យ៉ាងណា សូម្បីព្រះពុទ្ធទាំងឡាយ ក៏ដូច្នោះ កាលទ្រង់សម្ដែងធម៌ដល់អ្នកស្ដាប់សូម្បីមួយនាក់ក៏ដោយ ទ្រង់សម្ដែងដល់អ្នកស្ដាប់ពីរនាក់ ច្រើននាក់ ដល់ភិក្ខុបរិស័ទ ភិក្ខុនីបរិស័ទ ឧបាសកបរិស័ទ និងឧបាសិកាបរិស័ទក៏ដោយ ដល់ពួកតិរ្ថិយក៏ដោយ ទ្រង់រមែងសម្ដែងដោយគោរពទាំងអស់ ។ បរិស័ទទាំងបួន ក៏មានសទ្ធាពេញចិត្តស្ដាប់ ដូច្នោះ ការ

*សម្តែងដល់បរិស័ទទាំងបួននោះ ទើបឈ្មោះថា សម្តែងដោយគោរព ។*

ចប់អដ្ឋកថា ទេសនាសូត្រទី ៧

# អ ដ្ឋ ក ថា

## សទ្ធធម្មសូត្រទី ៨

ក្នុង សទ្ធធម្មសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២៥០] ដោយបទថា កម្មណាៗ ច្រើន (យំ ពហុលំ យំ ពហុលំ) នេះ និគ្រន្ថ រមែងទម្លាយវាទៈរបស់ខ្លួនដោយខ្លួនឯង ដូច្នោះ ។

[២៥១] ព្រះមានព្រះភាគ ទើបត្រាស់ព្រះពុទ្ធតម្រាស់ថា បើដូច្នោះ នរណាៗ នឹងមិនទៅកាន់អបាយ (ឯវំ សន្តេ ន កោចិ អាបាយិកោ) ដូច្នេះជាដើម ។

[២៥៥] ក៏ ៤ បទមុនៗ រមែងជាបច្ច័យដល់ទិដ្ឋិ ដូច្នោះ ព្រះមានព្រះ-ភាគ កាលនឹងទ្រង់ចង្អុលទោសក្នុងបទទាំងនោះ ទើបត្រាស់ព្រះពុទ្ធតម្រាស់ថា គាមណី សាស្តាខ្លះក្នុងលោកនេះ ជាអ្នកនិយាយយ៉ាងនេះ (ឥធ គាមណិ ឯកច្ចោ សត្ថា ឯវំ វាទី ហោតិ) ដូច្នេះជាដើម ។

[២៥៦] បណ្តាបទទាំងនោះ បទថា អហំបម្ហិ កាត់បទជា អហំបិ អម្ហិ ប្រែថា សូម្បីយើង ។

[២៦១] ពាក្យដែលគួរនឹងពោល ក្នុងបទថា មេត្តាសហគតេន ជាដើម

នោះទាំងអស់ បានពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ព្រមទាំងការនានយ័ ។ តែបទថា **សេយ្យថាបិ គាមណិ ពលវា សង្ខធម្មោ** ជាដើម ក្នុងទីនេះ មិនមានមកពីមុន ។

បណ្តាបទទាំងនោះ បទថា **អ្នកមានកម្លាំង (ពលវា)** សេចក្តីថា ក្នុងបទនោះ សេចក្តីថា អ្នកផ្លុំស័ង្ខសម្បូរណ៍ដោយកម្លាំង ។ បទថា **អប្បកសិរេន** ប្រែថា ដោយមិនលំបាក ។ ពិតណាស់ អ្នកផ្លុំស័ង្ខដែលមានកម្លាំងតិច កាលផ្លុំស័ង្ខ រមែងមិនអាចឲ្យអ្នកដឹងច្បាស់ទាំង ៤ ទិស បានដោយសំឡេង សំឡេងស័ង្ខរបស់គេមិនខ្ចរខ្ចាយទៅទូទាំងទិស តែសំឡេងស័ង្ខរបស់អ្នកមានកម្លាំង រមែងមានប្រការផ្សាយគ្នា (ឮទៅទូទាំងទិស) ដូច្នោះទើបត្រាស់ថា **ពលវា** ។ ក្នុងបទថា **មេត្តាយ ចេតោវិមុត្តិយា** នេះ កាលពោលថា **មេត្តា** ក៏សំដៅដល់ទាំងឧបចារៈ ទាំងអប្បនា តែកាលពោលថា **ចេតោវិមុត្តិ** ក៏សំដៅដល់អប្បនាប៉ុណ្ណោះ ។ បទថា **កម្មដែលធ្វើល្មមប្រមាណណា (យំ បមាណកតំ កម្មំ)** សេចក្តីថា កម្មដែលធ្វើល្មមប្រមាណហៅថា **កាមាវចរៈ** , កម្មដែលធ្វើរកប្រមាណមិនបាន ហៅថា **រូបាវចរៈ** កម្មដែលជារូបាវចរៈនោះ ហៅថា ប្រមាណមិនបាន ព្រោះផ្សាយទៅហួសប្រមាណ ផ្សាយទៅគ្រប់ទិសទាំងចំពោះ និងមិនចំពោះ ។ បទថា **កម្មនោះ**

នឹងមិនមាន មិនតាំងនៅក្នុងរូបាវចរៈនោះ (ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ) សេចក្តីថា កម្មដែលជាកាមាវចរៈ មិនសល់នៅ មិនតាំងនៅក្នុងកម្មដែលជារូបាវចរៈនោះ ។ អធិប្បាយយ៉ាងណា ។ អធិប្បាយថា កម្មដែលជាកាមាវចរៈនោះ មិនអាចជាប់ ឬតាំងនៅក្នុងចន្លោះនៃកម្មដែលជារូបាវចរៈ និងអរូបាវចរៈនោះ មិនអាចផ្សាយទៅដល់កម្មដែលជារូបាវចរៈ និងអរូបាវចរៈ ហើយកាន់យកជាឱកាសរបស់ខ្លួនតាំងនៅ ដែលពិត កម្មដែលជារូបាវចរៈ និងអរូបាវចរៈនុ៎ះឯង រមែងគ្របសង្កត់កម្មដែលជាកាមាវចរៈ ចូលទៅតាំងនៅជំនួស ដូចអន្លង់ទឹកធំផ្សាយទឹកទៅម្តងបន្តិចៗ ចូលទៅតាំងជំនួស ហាមវិបាករបស់កម្មដែលជាកាមាវចរៈនោះ ហើយនាំចូលដល់ភាពជាសម្ចាញ់របស់ព្រហ្មក្នុងសម័យនុ៎ះឯង ព្រះសូត្រដែលប្រព្រឹត្តទៅតាមអនុសន្ធិតែមួយ ព្រោះផ្នែកខាងដើម ផ្តើមដោយអំណាចកិលេស ផ្នែកខាងចុង កាន់យកដោយអំណាចព្រហ្មវិហារ ។

ចប់អដ្ឋកថា សង្ខធម្មសូត្រទី ៨

# អ ដ្ឋ ក ថា

## កុលសូត្រទី ៩

ក្នុង កុលសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២៦២] បទថា ទុព្ភិក្ខា ប្រែថា មានភិក្ខារកបានលំបាក ។ បទថា ចិញ្ចឹមជីវិតបានដោយកាពទាល់ក្រ (ទ្វីហិតិកា) សេចក្តីថា មានសេចក្តីរស់នៅប្រព្រឹត្តទៅយ៉ាងនេះថា ពួកយើងនឹងមានជីវិតរស់នៅបានឬទេហ្ន៎ ។ បាឋៈថា ទុហិតិកា ដូច្នេះក៏មាន ន័យក៏យ៉ាងនេះឯង ឈ្មោះថា ទុហិតិកា ក្នុងប្រការថា រស់នៅលំបាក នេះព្រោះមិនអាចប្រកបការងារអ្វីៗ បានស្រួល ។ ឈ្មោះថា ដេរដាសដោយឆ្អឹង (សេតដ្ឋិកា) ព្រោះមានឆ្អឹងរបស់មនុស្សដែលស្លាប់ក្នុងទីនោះៗ សដេរដាស់ ។

បទថា ត្រូវចំណាយដោយស្លាក (សលាកាវុត្តា) បានដល់ មានជីវិតរស់នៅបានត្រឹមតែប្រើស្លាក គឺ ការរស់នៅក្នុងនាឡូនគ្រាមនោះ ត្រឹមតែប្រើស្លាកប៉ុណ្ណោះ អធិប្បាយថា ឲ្យកើតផល ។ បទថា ខ្ជាក់ (ឧគ្គិលិតុំ) សេចក្តីថា កាលព្រះសមណគោតមមិនអាចពោលដោះស្រាយចំណុចទាំងពីរបាន ឈ្មោះថា មិនអាចខ្ជាក់ គឺ នាំចេញក្រៅ ។ បទថា លេប (ឱគិលិតុំ)

សេចក្តីថា កាលទ្រង់ឃើញទោសនៃពាក្យសួរហើយ មិនអាចនាំចូលទៅ ឈ្មោះថា មិនអាចលេប គឺ ឲ្យចូលទៅខាងក្នុង ។

[២៦៤] ព្រះមានព្រះភាគកាលត្រាស់ថា **រាប់ពីកប្បនេះទៅ ៩១ កប្ប (ឥតោ សោ គាមណិ ឯកនវុតោ កប្បោ)** ប៉ុណ្ណោះ ក៏ទ្រង់រឭកទៅ ៩១ កប្ប ត្រឹមតែរយៈដែលខ្យល់ដកដង្ហើមចេញពីច្រមុះ មិនទាន់ត្រឡប់ចូលវិញ ក៏កំណត់ដឹងថា ក្នុងត្រកូលដែលធ្លាប់ត្រូវបៀតបៀនដោយការឲ្យភិក្ខាដែលឆ្អិនហើយមានខ្វះទេហ្ន៎ ទ្រង់ក៏មិនបានឃើញសូម្បីតែមួយករណី ទើបត្រាស់ព្រះពុទ្ធវចនៈជាដើមថា **ឥតោ សោ គាមណិ** ដូច្នេះ ។ ឥឡូវនេះ កាលត្រាស់អានិសង្សរបស់ទានជាដើម ទើបទ្រង់ផ្តើមព្រះធម៌ទេសនាថា **មយ៉ាងទៀត ត្រកូលពួកណាថ្កុំថ្កើង (អថខោ យានិ តានិ កុលានិ អឌ្ឍានិ)** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ចម្រើនឡើងព្រោះការឲ្យទាន (ទានសម្ភូតានិ)** សេចក្តីថា មានព្រម គឺ កើតព្រោះការឲ្យទាន ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏ន័យនេះដូចគ្នា ។ ក៏ក្នុងបទនេះ ភាពជាអ្នកនិយាយពិត ឈ្មោះសច្ចៈ សីលដ៏សេស ឈ្មោះសញ្ញមៈ ។ បទថា **ខ្ជះខ្ជាយ (វិកិរតិ)** សេចក្តីថា បានតែប្រើដោយមិនប្រកបការងារ រមែងធ្វើទ្រព្យឲ្យខ្ជះខ្ជាយ ។ បទថា **រោយរាយ (វិធមតិ)** សេចក្តីថា រមែងឲ្យវិនាសដូចត្រូវភ្លើងឆេះ ។

បទថា **បំផ្លាញឲ្យវិនាស (វិទ្ធំសេតិ)** សេចក្តីថា ឲ្យវិនាស គឺ ជារបស់ទៀងមិនបាន ឬទ្រព្យដែលប្រើវេលាជាច្រើនប្រមូលរក្សាទុក អន្តរធានទៅក្នុងខណៈមួយក្អែតប៉ុណ្ណោះ ព្រោះមានហើយមិនមាន ។

ចប់អដ្ឋកថា កុលសូត្រទី៩

# អ ដ្ឋ ក ថា

## មណិចូឡកសូត្រទី ១០

*ក្នុង មណិចូឡកសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[២៦៦] *បទថា* ***បានពោលនឹងបរិស័ទ (តំ បរិសំ ឯតទវោច)*** *សេចក្តីថា បានឮថា មេស្រុកនាមថា មណិចូឡកៈនោះ មានការគិតថា កុលបុត្រទាំងឡាយកាលបួស រមែងលះបុត្រ និងភរិយា មាស និងប្រាក់មុនហើយទើបបួស និងគេទាំងនោះលុះលះបង់ហើយបួស ទើបមិនអាចទទួលមាស និងប្រាក់នោះបាន ។ មេស្រុកនោះ មានការប្រកាន់ជាពិសេស ទើបបានពោលពាក្យជាដើមថា* ***មា អយ្យា*** *ដូច្នេះ ។*

[២៦៨] *បទថា* ***ភាពដែលគួរដល់បញ្ចកាមគុណនោះដោយចំណែកតែមួយ (ឯកំសេនេតំ)*** *សេចក្តីថា លោកគប្បីចងចាំសភាពដែលគួរដល់កាម-គុណប្រាំនោះ ដោយចំណែកតែមួយថា មិនមែនធម៌របស់សមណៈ មិនមែនធម៌របស់ពួកសក្យបុត្រ ។ បទថា* ***ស្មៅ (តិណំ)*** *បានដល់ ស្មៅប្រក់សេនាសនៈ ។*

*បទថា* ***គប្បីស្វែងរក (បរិយេសិតព្វំ)*** *សេចក្តីថា កាលផ្ទះដែលប្រក់*

ដោយស្មៅ ឬប្រក់ដោយឥដ្ឋក្បាយ គប្បីទៅកាន់សម្នាក់របស់អ្នកដែលធ្វើផ្ទះនោះ ប្រាប់ថា សេនាសនៈដែលលោកធ្វើ ភ្លៀងលិច ។ យើងមិនអាចនៅក្នុងសេនាសនៈនោះបាន ។ មនុស្សទាំងឡាយកាលធ្វើបាន ក៏នឹងធ្វើឲ្យ កាលធ្វើមិនបាន ក៏នឹងប្រាប់ថា ពួកលោកចូររកជាងឲ្យធ្វើ ពួកយើងនឹងឲ្យសញ្ញាចំពោះមេជាងទាំងនោះ លុះឲ្យមេជាងប្រាប់ទុកយ៉ាងនោះ ធ្វើស្រេចហើយ គប្បីប្រាប់ដល់ពួកមនុស្សទាំងនោះ ពួកមនុស្សនឹងឲ្យតម្លៃឈ្នួលដល់ពួកមេជាង ។ ប្រសិនបើមិនមានម្ចាស់របស់ដែលនៅអាស្រ័យ ភិក្ខុដែលប្រព្រឹត្តកិច្ចាចារវត្ត គួរប្រាប់សូម្បីដល់បុគ្គលដទៃៗ ឲ្យធ្វើ ។ បទថា **បរិយេសិតព្វំ** ទ្រង់ត្រាស់សំដៅសេចក្តីដូច្នេះ ។ បទថា **ឈើ (ទារុំ)** សេចក្តីថា កាលឈើមេដំបូលជាដើមក្នុងសេនាសនៈបាក់ គប្បីស្វែងរកឈើដើម្បីជុសជុល ។ បទថា **រទេះ (សកដំ)** បានដល់ រទេះមួយគ្រាប់ប៉ុណ្ណោះ ធ្វើឲ្យប្លែកពីរបស់គ្រហស្ថ ។ មិនមែនតែរទេះតែម្យ៉ាងប៉ុណ្ណោះ សូម្បីឧបករណ៍ដទៃៗ មានកាំបិត ពូថៅ និងចបជាដើម ក៏គួរស្វែងរកយ៉ាងនេះ ។ បទថា **បុរស (បុរិសោ)** សេចក្តីថា គួរស្វែងរកមនុស្សមកជួយការងារ គឺ និយាយចំពោះបុគ្គលណាមួយថា លោកនឹងជួយការងារបានទេ កាលគេប្រាប់ថា ខ្ញុំនឹងជួយ គួរឲ្យគេធ្វើវត្ថុដែលត្រូវការថា លោកចូរធ្វើវត្ថុនេះៗ ។ បទថា **យើងមិនបាន**

*ពោល...ដោយបរិយាយអ្វីឡើយ (ន គេ្វ វាហំ គាមណិ កេនចិ បរិយា-យេន) សេចក្តីថា យើងមិនបានពោលដល់មាស និងប្រាក់ ថា សមណ-សក្យបុត្រគប្បីស្វែងរក ដោយហេតុអ្វីៗ ឡើយ ។*

ចប់អដ្ឋកថា មណិចូឡកសូត្រទី ១០

# អ ដ្ឋ ក ថា

## គន្ធកសូត្រទី ១១

ក្នុង គន្ធកសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២៦៩] បទថា **ក្នុងមល្លរដ្ឋ (មល្លេសុ)** បានដល់ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។ បទថា **វធេន** ប្រែថា ស្លាប់ ។ បទថា **ជានិយា** ប្រែថា វិនាសទ្រព្យ ។ បទថា **សម្រេចហើយដោយមិនប្រកបដោយកាល (អកាលិកេន បត្តេន)** សេចក្តីថា សម្រេចក្នុងចន្លោះកាល គឺ សម្រេចមិនកន្លងកាល ក៏មិនមែន ។ បទថា **កុមារនាមថា ចិរវាសី (ចិរវាសិ នាម កុមារោ)** បានដល់ បុត្ររបស់មេស្រុកនោះ មានឈ្មោះយ៉ាងនោះ ។ បទថា **អាស្រ័យនៅខាងក្រៅនគរ (ពហិ អាវាសថេ បដិវសតិ)** សេចក្តីថា នៅរៀនសិល្បៈយ៉ាងណាមួយក្រៅក្រុង ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់ទុក្ខក្នុងវដ្តៈ ។

ចប់អដ្ឋកថា គន្ធកសូត្រទី ១១

# អ ដ្ឋ ក ថា

## រាសិយសូត្រទី ១២

*ក្នុង **រាសិយសូត្រទី ១២** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៧១] បទថា **មេស្រុកឈ្មោះរាសិយៈ (រាសិយោ)** សេចក្តីថា ព្រះធម្មសង្គាហកត្ថេរបានកំណត់ឈ្មោះ មេស្រុកថា រាសិយៈ យ៉ាងនេះ ព្រោះគេសួរបញ្ហាជាក្រុម ។ បទថា **អ្នកមានតបៈ (តបស្សី)** បានដល់ អាស្រ័យតបៈ ។ បទថា **មានជីវិតសៅហ្មង (លូខជីវី)** ប្រែថា មានជីវិតសៅហ្មងជានិច្ច ។*

*[២៧២] បទថា **ចំណែកបំផុត (អន្តា)** បានដល់ ចំណែក ។ បទថា **គាមោ** បានដល់ ជារបស់អ្នកស្រុក ។ បាឋៈថា **គម្មោ** ដូច្នេះក៏មាន សេចក្តីថា ជារឿងរបស់អ្នកស្រុក ។ បទថា **អត្តកិលមថានុយោគោ** ប្រែថា ការប្រកបខ្លួនឲ្យលំបាកទទេ អធិប្បាយថា ធ្វើសេចក្តីក្តៅក្រហាយដល់រាងកាយ ។*

*សួរថា ក៏ក្នុងទីនេះ*

*ហេតុអ្វីទើបទ្រង់កាន់យកកាមសុខល្លិកានុយោគ*

*ហេតុអ្វីទើបទ្រង់កាន់យកអត្តកិលមថានុយោគ*

ហេតុអ្វីទើបទ្រង់កាន់យកមជ្ឈិមាបដិបទា ។

ឆ្លើយថា ទ្រង់កាន់យកកាមសុខល្លិកានុយោគ ដើម្បីសម្ដែងដល់ពួកជនអ្នកបរិភោគកាមមុន ។ ទ្រង់កាន់យកអត្តកិលមថានុយោគ ដើម្បីសម្ដែងដល់ពួកជនអ្នកអាស្រ័យតបៈ , ទ្រង់កាន់យកមជ្ឈិមាបដិបទា ដើម្បីសម្ដែងរឿងដែលរកសេចក្ដីទ្រុឌទ្រោមមិនបាន ៣ ប្រការ ។

សួរថា ក្នុងការសម្ដែងវត្ថុបដិបត្តិទាំងនោះ បានប្រយោជន៍អ្វី ។

ឆ្លើយថា បណ្ដាវត្ថុបដិបត្តិទាំងនេះ ព្រះតថាគតទ្រង់លះបង់ចំណែកបំផុត ២ យ៉ាង ហើយទ្រង់សម្រេចព្រះសម្មាសម្ពោធិញ្ញាណដោយមជ្ឈិម-បដិបទា ។ អ្នកបរិភោគកាមទាំងឡាយ ព្រះអង្គក៏ទ្រង់មិនបានតិះដៀល ទ្រង់មិនបានសរសើរ សូម្បីអ្នកអាស្រ័យតបៈទាំងឡាយ ព្រះអង្គក៏ទ្រង់មិនបានតិះដៀល ទ្រង់មិនបានសរសើរទូទៅគ្រប់បុគ្គល ទ្រង់តិះដៀលចំពោះបុគ្គលដែលគួរតិះដៀល ទ្រង់សរសើរចំពោះបុគ្គលដែលគួរសរសើរ គប្បីជ្រាបថាប្រយោជន៍ក្នុងការសម្ដែងវត្ថុបដិបត្តិទាំងនេះ ក៏ដើម្បីប្រកាសនូវសេចក្ដីនេះដោយប្រការដូច្នេះ ។

[២៧៣] ឥឡូវនេះ កាលនឹងទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា គាមណិ បុគ្គលដែលបរិភោគកាម ៣ ជំពូកនេះ (តយោមេ

គាមណិ កាមភោគិនោ) ដូច្នេះ ជាដើម ។

បណ្ដាបទទាំងនោះ បទថា **សាហសេន** ប្រែថា ដោយការធ្វើយ៉ាង ប្រញាប់ប្រញាល់ ។ បទថា **មិនចែកទាន (ន សំវិភជតិ)** សេចក្ដីថា មិន ចែកចាយដល់មិត្តសម្លាញ់ដែលធ្លាប់ឃើញ ធ្លាប់រាប់អានគ្នា ។ បទថា **មិន ធ្វើបុណ្យ (ន បុញ្ញានិ ករោតិ)** សេចក្ដីថា មិនធ្វើបុណ្យ ដែលជាបច្ច័យ ដល់កពខាងមុខ ។

[២៧៤] បទថា **ធម្មាធម្មេន** ប្រែថា ដោយត្រូវតាមធម៌ និងដោយ មិនត្រូវតាមធម៌ ។

[២៧៦] បទថា **ហាន (ហានេហិ)** បានដល់ ដោយហេតុទាំងឡាយ ។

[២៨៦] បទថា **ធ្វើឲ្យច្បាស់ (សច្ឆិករោតិ)** សេចក្ដីថា អ្នកមានតបៈ កាលធ្វើខ្លួនឲ្យក្ដៅក្រហាយ នឹងធ្វើឲ្យច្បាស់នូវឧត្តរិមនុស្សធម៌បានយ៉ាងណា ។ ធម៌រាសី (គំនរធម៌) ៣ យ៉ាង ឈ្មោះថា ដែលបុគ្គលគប្បីឃើញដោយខ្លួន ឯង ដោយអំណាចសេចក្ដីព្យាយាមដែលប្រកបដោយអង្គ ៤ និងដោយ អំណាចធុតង្គ ។

[២៩០] ក្នុងបទថា **ធម៌ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង រកកាល ទ្រុឌទ្រោមមិនបាន (សន្ទិដ្ឋិកា និជ្ជរា)** នេះ លោកហៅ មគ្គយ៉ាងណាមួយ

ថា តិស្សោ និជ្ជរា ព្រោះកិលេសទាំងបី រកជរាទ្រុឌទ្រោមមិនបាន ។

ចប់អដ្ឋកថា រាសិយសូត្រទី ១២

# អ ដ្ឋ ក ថា

## បាដលិយសូត្រទី ១៣

ក្នុង បាដលិយសូត្រទី ១៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២៩២] បទថា អ្នកនាំដំណឹង (ទូតេយ្យានិ) ប្រែថា ការងារទូត ជាសំបុត្រក៏មាន ជាសាសន៍អំពីមាត់ក៏មាន ។

[២៩៣] ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារព្ធពាក្យនេះថា តថាគតដឹងច្បាស់អំពីបាណាតិបាត (បាណាតិបាតញ្ចាហំ) ដូច្នេះ ។ ទ្រង់ប្រារព្ធ ដើម្បីសម្ដែងដល់ព្រះសព្វញ្ញូថា តថាគតមិនបានដឹងមាយាតែម្យ៉ាង សូម្បីរឿង ដទៃៗ តថាគតក៏ដឹង យ៉ាងនេះៗ ។

[២៩៤] ទ្រង់ប្រារព្ធបទនេះថា គាមណី មានសមណព្រាហ្មណ៍ពួក មួយ (សន្តិ ហិ គាមណិ ឯកេ សមណព្រាហ្មណា) ដូច្នេះ ដើម្បីទ្រង់សម្ដែង លទ្ធិរបស់សមណព្រាហ្មណ៍ដ៏សេស ហើយឲ្យលះលទ្ធិនោះចេញ ។

[២៩៥] បទថា ប្រដាប់ដោយផ្កាឈើជាក្រវិល (មាលី កុណ្ឌលី) សេចក្ដីថា ប្រដាប់ផ្កាឈើដោយកម្រងផ្កាឈើ ដាក់ក្រវិលត្រចៀក ដោយ ក្រវិលទាំងឡាយ ។ បទថា ដោយសេចក្ដីប្រាថ្នាចំពោះស្ត្រី (ឥត្ថិកាមេហិ)

សេចក្តីថា សេចក្តីប្រាថ្នាក្នុងស្ត្រីទាំងឡាយ ឈ្មោះឥត្ថីកាម ។ (ឲ្យបម្រើខ្លួន) ដោយឥត្ថីកាមទាំងនោះ ។

[៣០២] បទថា **ផ្ទះស្នាក់** (អាវសថាគារំ) បានដល់ បន្ទប់ដេក ដែលធ្វើទុកក្នុងទីកន្លែងមួយនៃផ្ទះត្រកូល ដើម្បីនៅសប្បាយសម្រាប់មនុស្សម្នាក់ប៉ុណ្ណោះ ។ បទថា **ខ្ញុំព្រះអង្គ ក៏ចាត់ចែងសមគួរតាមស័ក្តិ តាមកម្លាំង** (តេនាហំ យថាសត្តិ យថាពលំ សំវិភជាមិ) សេចក្តីថា ខ្ញុំព្រះអង្គ នឹងចែកចាយបន្ទប់ដេកនោះ ដោយសមគួរដល់ស័ក្តិ និងដោយសមគួរដល់កម្លាំង ។

[៣០៦] បទថា **អលំ** ប្រែថា គួរ ។ បទថា **ក្នុងឋានៈដែលគួរសង្ស័យ** (កង្ខនិយេ ឋានេ)[១] បានដល់ ក្នុងហេតុដែលគួរសង្ស័យ ។

[៣០៧] ដោយបទថា **ចិត្តសមាធិ** (ចិត្តសមាធី) ទ្រង់សម្តែងថា បើអ្នកតាំងនៅក្នុងសមាធិធម៌នោះហើយ គប្បីត្រឡប់បានចិត្តសមាធិ ដោយអំណាចមគ្គ ៤ ព្រមទាំងវិបស្សនា ។

[៣០៨] បទថា **ព្រោះតថាគតជាអ្នកបដិបត្តិមិនខុស** (អបណ្ណកតាយ មយ្ហំ) សេចក្តីថា បដិបទានេះ រមែងប្រព្រឹត្តទៅយ៉ាងនេះ ព្រោះតថាគតជា

---

១ (បិដក កង្ខនិយេ ច បន ឋានេ) ។

អ្នកបដិបត្តិមិនខុស គឺ មិនមានកំហុស ។ បទថា កដគ្គាហោ ប្រែថា កាន់យកជ័យជំនះ ។

[៣០៩] បទថា ធម្មសមាធិ ក្នុងបទថា គាមណី នេះឯងជាធម្មសមាធិ បើអ្នកតាំងនៅក្នុងធមសមាធិនោះ គប្បីបានចិត្តសមាធិ (អយំខោ គាមណិ ធម្មសមាធិ តត្រ ចេ ត្វំ ចិត្តសមាធឹ បដិលភេយ្យាសិ) នេះ បានដល់ កុសលកម្មបថ ១០ ។ បទថា ចិត្តសមាធិ បានដល់ មគ្គ ៤ ព្រមដោយវិបស្សនា ។

[៣១០] មួយ៉ាងទៀត បទថា បាមោជ្ជៈរមែងកើតឡើង (បាមុជ្ជំ ជាយតិ) សេចក្តីថា ធម៌ ៥ ពោលគឺ បាមោជ្ជៈ បីតិ បស្សទ្ធិ សុខ និងសមាធិ ដែលលោកពោលយ៉ាងនេះថា កាលបាមោជ្ជៈមានហើយ រមែងឲ្យកើតបីតិ ដូច្នេះ ឈ្មោះ ធម្មសមាធិ ។ ចំណែកមគ្គ ៤ ព្រមដោយវិបស្សនា ឈ្មោះ ចិត្តសមាធិ ។ មួយ៉ាងទៀត កុសលកម្មបថ ១០ និងព្រហ្មវិហារ ៤ នេះ ឈ្មោះធម្មសមាធិ ភាពនៃចិត្តតម្កល់មាំដែលកើតឡើងដល់អ្នកបំពេញធម្ម-សមាធិនោះ ឈ្មោះចិត្តសមាធិ ។ បទថា បើដូច្នេះ អ្នកនឹងលះបង់សេចក្តីសង្ស័យបាន (ឯវំ ត្វំ ឥមំ កង្ខាធម្មំ បជហេយ្យាសិ) សេចក្តីថា បើដូច្នេះ បើអ្នកតាំងនៅក្នុងធម្មសមាធិមានប្រភេទដូចពោលហើយនេះ គប្បីត្រឡប់បាន

*ចិត្តសមាធិយ៉ាងនេះ គប្បីលះបង់សេចក្ដីសង្ស័យនេះបានដោយពិត ។ បទដ៏សេសក្នុងទីទាំងពួង មានន័យដូចពោលហើយនោះឯង ។*

ចប់អដ្ឋកថា ចាដលិយសូត្រទី ១៣

## ចប់គាមណិសំយុត្ត

### រួមក្នុងវគ្គនេះមាន ១១ អដ្ឋកថា

១-អដ្ឋកថា ចណ្ឌសូត្រ
២-អដ្ឋកថា តាលបុត្តសូត្រ
៣-អដ្ឋកថា យោធាជីវសូត្រ
៤-អដ្ឋកថា អសិពន្ធកបុត្តសូត្រ
៥-អដ្ឋកថា ទេសនាសូត្រ
៦-អដ្ឋកថា សង្ខធម្មសូត្រ
៧-អដ្ឋកថា កុលសូត្រ
៨-អដ្ឋកថា មណិចូឡកសូត្រ
៩-អដ្ឋកថា គន្ធភកសូត្រ
១០-អដ្ឋកថា រាសិយសូត្រ
១១-អដ្ឋកថា ចាដលិយសូត្រ

# អសង្ខតសំយុត្ត

## វគ្គទី ១[1]

## អ ដ្ឋ ក ថា

## វគ្គទី ១ និង ទី ២

[៣១៦] បទថា **អសង្ខតៈ (អសង្ខតំ)** បានដល់ ដែលបច្ច័យមិនធ្វើឲ្យកើត ។ បទថា **ហិតេសិនា** ប្រែថា អ្នកស្វែងរកប្រយោជន៍ដ៏ធំ ។ បទថា **អនុកម្បកេន** ប្រែថា អនុគ្រោះហើយ ។ បទថា **អាស្រ័យសេចក្ដីអនុគ្រោះ (អនុកម្បំ ឧបាទាយ)** សេចក្ដីថា កំណត់ដោយចិត្តគិតជួយ លោកអធិប្បាយថា អាស្រ័យ ដូច្នេះក៏មាន ។ បទថា **កិច្ចនោះដែលតថាគត...ធ្វើហើយដល់អ្នកទាំងឡាយ (កតំ វោ តំ មយា)** សេចក្ដីថា ព្រះសាស្ដា កាលសម្ដែងអសង្ខតៈ និងផ្លូវនៃអសង្ខតៈនេះ ឈ្មោះថា ធ្វើកិច្ចដល់លោកទាំងឡាយហើយ ព្រោះថា កិច្ច គឺ ការសម្ដែងធម៌មិនវិបរិតរបស់ព្រះសាស្ដាដែលអនុគ្រោះ ក៏ត្រឹមតែប៉ុណ្ណោះ ចំណែកការបដិបត្តិបន្តពីនេះ ជាកិច្ចរបស់សាវក

---

១-ព្រះអដ្ឋកថា កែសេចក្ដីក្នុងអសង្ខតសំយុត្តរួមគ្នាទាំងវគ្គទី ១-២ ។

ទាំងឡាយ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ម្នាលភិក្ខុ ទាំងឡាយ** ... **គល់ឈើ ។ល។ នេះជាអនុសាសនីរបស់តថាគត (ឯតានិ ភិក្ខវេ រុក្ខ-មូលានិ ។បេ។ អម្ហាកំ អនុសាសនី)** ដូច្នេះ ដោយបទនេះ ទ្រង់សម្តែង សេនាសនៈ គឺ គល់ឈើ ។ ដោយបទថា **ផ្ទះស្ងាត់ (សុញ្ញាគារានិ)** នេះ ទ្រង់សម្តែងស្ថានទីដែលស្ងាត់អំពីមនុស្ស និងដោយបទទាំងពីរ ទ្រង់ប្រាប់ សេនាសនៈដែលសមគួរដល់ការបំពេញព្យាយាមផ្លូវកាយ និងចិត្ត ឈ្មោះថា ទ្រង់ប្រគល់មត៌កឲ្យ ។ បទថា **ចូរសម្លឹង (ឈាយថ)** សេចក្តីថា ចូរចូល ទៅសម្លឹងអារម្មណ៍ ៣៨ ដោយអារម្មណូបនិជ្ឈាន និងសម្លឹងខន្ធ អាយតនៈ ជាដើម ដោយលក្ខណូបនិជ្ឈាន ដោយជាអនិច្ចលក្ខណៈជាដើម លោក អធិប្បាយថា ចូរចម្រើនទាំងសមថៈ និងវិបស្សនា ។ បទថា **មា បមាទត្ថ** ប្រែថា កុំប្រមាទ ។ បទថា **កុំជាអ្នកក្តៅក្រហាយក្នុងខាងក្រោយ (មា បច្ឆា វិប្បដិសារិនោ អហុវត្ថ)** សេចក្តីថា ជនពួកណាក្នុងកាលមុន វេលាជាកម្លោះ មិនមានរោគ សម្បូរណ៍ដោយសេចក្តីសប្បាយ ៧ យ៉ាងជាដើម ទាំងសាស្តា ក៏នៅចំពោះមុខ លះបង់យោនិសោមនសិការចេញ សោយសុខក្នុងការដេក ធ្វើខ្លួនជាអាហាររបស់សង្កើចទាំងយប់ទាំងថ្ងៃ ប្រមាទហើយ ជនពួកនោះ ខាងក្រោយ វេលាជរា មានរោគ ស្លាប់ វិបត្តិ ទាំងសាស្តាក៏បរិនិព្វានហើយ

ទឹកដល់ការនៅដោយសេចក្ដីប្រមាទមុនៗ នោះ និងពិចារណាឃើញសេចក្ដីស្លាប់ដែលមានបដិសន្ធិ ថាជាការៈធ្ងន់ រមែងក្ដៅក្រហាយ តែអ្នកទាំងឡាយកុំបានជាដូច្នោះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងដូច្នេះ ទើបត្រាស់ថា **មា បច្ឆា វិប្បដិសារិនោ អហុវត្ថ** ដូច្នេះ ។ បទថា **នេះជាអនុសាសនីរបស់តថាគត ដើម្បីអ្នកទាំងឡាយ (អយំ វោ អម្ហាកំ អនុសាសនី)** មានអធិប្បាយថា នេះជាអនុសាសនី គឺ ឱវាទរបស់តថាគតដើម្បីអ្នកទាំងឡាយថា **ឈាយថ មា បមាទត្ថ** (ចូរសម្លឹង កុំប្រមាទ) ដូច្នេះ ។

[៣៣៩] បទដែលគួរទឹងពោល ក្នុងបទថា **ពិចារណាឃើញកាយក្នុងកាយ (កាយេ កាយានុបស្សី)** ដូច្នេះ ជាដើមនោះ ខ្ញុំនឹងពោលខាងមុខ ។

[៣៦២] ក្នុងបទថា **ទីបំផុត (អន្តំ)**[១] ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា អន្តៈ ព្រោះមិនមានសេចក្ដីត្រេកអរដោយអំណាចតណ្ហា ។

[៣៦៣] បទថា **អនាសវំ** ព្រោះ មិនមានអាសវៈ ៤ ។

[៣៦៤] បទថា **សច្ចំ** ព្រោះជាបរមត្ថសច្ចៈ ។

[៣៦៥] បទថា **បារំ** ព្រោះអត្ថថា ជាចំណែកដទៃពីវដ្ដៈ ។

[៣៦៦] បទថា **និបុណំ** ព្រោះអត្ថថា ល្អិត ។

---

១ បាឡីបិដក ( អនត ) ។

[៣៦៧] បទថា សុទុទ្ទស ព្រោះជាធម៌ដែលឃើញបានសែនលំបាក ។

[៣៦៨] បទថា អជជ្ជរ ព្រោះមិនគ្រាំគ្រាដោយជរា ។

[៣៦៩] បទថា ធុវ ព្រោះអត្ថថាតម្កល់មាំ ។

[៣៧០] បទថា អបលោកិន ព្រោះជាធម៌មិនសេចក្តីវិនាស ។

[៣៧១] បទថា អនិទស្សន ព្រោះនរណាៗ មិនគប្បីឃើញបានដោយចក្ខុវិញ្ញាណ ។

[៣៧២] បទថា និប្បបញ្ច ព្រោះមិនមានកិលេសគ្រឿងយឺតយូរ គឺតណ្ហា មានះ និងទិដ្ឋិ ។

[៣៧៣] បទថា សន្ត ព្រោះអត្ថថា ស្ងប់ ។

[៣៧៤] បទថា អមត ព្រោះមិនមានសេចក្តីស្លាប់ ។

[៣៧៥] បទថា បណីត ព្រោះអត្ថថា ប្រសើរថ្លៃថ្លា ។

[៣៧៦] បទថា សិវ ព្រោះអត្ថថា មានសេចក្តីត្រជាក់ ។

[៣៧៧] បទថា ខេម ព្រោះប្រាសចាកអន្តរាយ ។

[៣៧៨] បទថា តណ្ហក្ខយ ព្រោះជាបច្ច័យឲ្យអស់តណ្ហា ។

[៣៧៩] បទថា អច្ឆរិយ ព្រោះគួរអស្ចារ្យ ព្រោះអត្ថថា តាំងមាំដោយសមាធិ ។ រឿងដែលមិនធ្លាប់ក៏មានន៉ុះឯង ។

[៣៨០] បទថា អច្ចុត គួរនឹងពោលថា មិនធ្លាប់មាន ។

[៣៨១] បទថា អនីតិក ព្រោះប្រាសចាកទុក្ខ ។

[៣៨២] បទថា អនីតិកធម្ម ព្រោះជាធម៌ប្រាសចាកទុក្ខជាសភាវៈ ។

[៣៨៣] បទថា និព្វាន ព្រោះមិនមានតណ្ហាគ្រឿងរួបរឹត ។

[៣៨៤] បទថា អព្យាបជ្ឈ ព្រោះមិនមានសេចក្ដីបៀតបៀន ។

[៣៨៥] បទថា វិរាគ ដោយជាបច្ច័យដល់ការសម្រេចធម៌ជាគ្រឿងប្រាសចាកតម្រេក ។

[៣៨៦] បទថា សុទ្ធិ ព្រោះជាធម៌បរិសុទ្ធិដោយបរមត្ថ ។

[៣៨៧] បទថា មុត្តិ ព្រោះជាធម៌ផុតចាកភព ៣ ។

[៣៨៨] បទថា អនាលយ ព្រោះមិនមានអាល័យ ។

[៣៨៩] បទថា ទីប ព្រោះអត្ថថាជាទីពឹង ។

[៣៩០] បទថា លេណ ព្រោះអត្ថថា គួរស្នាក់អាស្រ័យ ។

[៣៩១] បទថា តាណ ព្រោះអត្ថថា ជាទីការពារ ។

[៣៩២] បទថា សរណ ព្រោះអត្ថថា កម្ចាត់ភ័យ ។ អធិប្បាយថា ធ្វើភ័យឲ្យវិនាស ។

[៣៩៣] បទថា បរាយន ព្រោះជាទីដំណើរទៅ ជាទីទៅ ជាទីពឹង

អាស្រ័យខាងមុខ ។

បទដ៏សេសក្នុងទីនេះ មានន័យដូចពោលហើយនុ៎ះឯង ដូច្នេះឯង ។

ចប់អដ្ឋកថា អសង្ខតសំយុត្ត

## ចប់អសង្ខតសំយុត្ត

## វគ្គទី ១ និង ទី ២

# អព្យាកតសំយុត្ត

## អ ដ្ឋ ក ថា

## ខេមាថេរីសូត្រទី ១

*ក្នុង ខេមាថេរីសូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៩៣] *បទថា ខេមា បានដល់ ព្រះថេរី វេលានៅជាគ្រហស្ថ ជាមហេសីរបស់ព្រះបាទពិម្ពិសារ ជាឧបាសិកាមានសទ្ធា បួសហើយជាព្រះមហាថេរី ដែលព្រះមានព្រះភាគទ្រង់តាំងទុកក្នុងឯតទគ្គៈអ្នកមានបញ្ញាច្រើនដោយព្រះពុទ្ធវចនៈយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុនីជាសាវិការបស់តថាគតអ្នកមានបញ្ញាច្រើន ខេមាភិក្ខុនីជាកំពូល ។*

[៣៩៤] *បទថា ជាបណ្ឌិត (បណ្ឌិតា) បានដល់ ប្រកបដោយភាពជាបណ្ឌិត ។ បទថា ឈ្លាសវៃ (ព្យត្តា) បានដល់ ប្រកបដោយភាពជាអ្នកឈ្លាសវៃ ។ បទថា មានបញ្ញា (មេធាវិនី) បានដល់ ប្រកបដោយបញ្ញាជាគ្រឿងកម្ចាត់កិលេស ។ បទថា ជាពហុស្សូត (ពហុស្សុតា) បានដល់ ប្រកបដោយភាពជាពហុស្សូត ទាំងផ្លូវបរិយត្តិ ទាំងផ្លូវបដិវេធ ។*

[៣៩៨] បទថា **អ្នករាប់ចំនួន (គណកោ)** បានដល់ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីទព្វន្ត ។ បទថា **អ្នកប្រមាណ (មុទ្ទិកោ)** បានដល់ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយម្រាមដៃ ។ បទថា **អ្នកប្រមាណ (សង្ខាយកោ)** បានដល់ ជាអ្នកឈ្លាសវៃក្នុងការរាប់ដោយវិធីបូក ។ បទថា **ជ្រៅ (គម្ភីរោ)** បានដល់ ជ្រៅប្រាំបីម៉ឺនបួនពាន់យោជន៍ ។ បទថា **ប្រមាណមិនបាន (អប្បមេយ្យោ)** បានដល់ ប្រមាណដោយការរាប់ជាអាឡ្ហកៈមិនបាន ។ បទថា **ស្ទង់បានដោយលំបាក (ទុប្បរិយោគាហោ)** បានដល់ កាន់យកប្រមាណដោយការរាប់ជាអាឡ្ហកៈបានលំបាក ។ បទថា **គប្បីបញ្ញត្តិសត្វដោយរូបណា (យេន រូបេន តថាគតំ)** សេចក្ដីថា គប្បីបញ្ញត្តិតថាគត ពោលគឺសត្វថា ខ្ពស់ ទាប ខ្មៅ ស ដូច្នេះ ដោយរូបណា ។ បទថា **រូបនោះ ដែលតថាគតលះបង់បានហើយ (តំ រូបំ តថាគតស្ស បហីនំ)** សេចក្ដីថា រូប មានប្រការដូចពោលហើយ ព្រះតថាគតទ្រង់ជាសព្វញ្ញូលះបង់បានហើយ ដោយការលះតណ្ហា ។ បទថា **ផុតចាកការបញ្ញត្តិថាជារូប (រូបសង្ខាយ វិមុត្តោ)** សេចក្ដីថា ផុតពីការទទួលរ៉ាប់រងថាជារូបតទៅ ដោយចំណែកនៃរូប និងអរូបខ្លះ ចាកការបញ្ញត្តិថារូប ព្រោះរម្ងាប់សូម្បីវោហារថា នឹងមានសូម្បីបែបនេះ ដូច្នេះខ្លះ ។ បទថា **ជារបស់ជ្រៅ (គម្ភីរោ)** បានដល់ ជ្រៅ ព្រោះជ្រៅដោយអធ្យាស្រ័យ

ផង ព្រោះសេចក្តីជ្រៅដោយគុណធម៌ផង អធិប្បាយថា កាលព្រះតថាគត ទ្រង់ជ្រៅដោយគុណធម៌នោះ មានហើយយ៉ាងនេះ ។ ពាក្យថា ខាងមុខអំពីស្លាប់ហើយ តថាគត ពោលគឺ សត្វនេះរមែងកើត នេះ រមែងមិនសមគួរ សូម្បីពាក្យថា ខាងមុខអំពីស្លាប់ហើយ តថាគត រមែងមិនកើតទៀតជាដើម រមែងមិនសមគួរ រមែងមិនគួរ ដល់ព្រះតថាគតដែលជាសព្វញ្ញូ ដែលទ្រង់ឃើញការមិនមាននៃបញ្ញត្តិនោះ ព្រោះមិនមានប្រការដែលជាហេតុឲ្យមានបញ្ញត្តិថា តថាគត ពោលគឺ សត្វជាដើម ។

បទថា **រមែងប្រៀបគ្នាបាន (សំសន្ទិស្សតិ)** បានដល់ នឹងមានយ៉ាងនេះ ។ បទថា **ចូលគ្នាបាន (សមេស្សតិ)** បានដល់ នឹងមានជាប់គ ។ បទថា **មិនខុស (ន វិហាយិស្សតិ)** បានដល់ នឹងមិនមានសព្ទដែលឃ្លៀងឃ្លាត ។ ក៏ទេសនាថា **ក្នុងបទដែលសំខាន់ (អគ្គបទស្មឹ)** ក្នុងទីនេះ ទ្រង់បំណាងបទដែលសំខាន់ ។ តែបទនេះ ត្រាស់ដោយអធិការនៃអព្យាកតធម៌ ដែលពោលទុកពិស្តារហើយក្នុងខន្ធិយវគ្គទី ២ នុ៎ះឯង ។

ចប់អដ្ឋកថា ខេមាថេរីសូត្រទី ១

# អ ដ្ឋ ក ថា

## បឋមសារីបុត្តកោដ្ឋិតសូត្រទី ៣

ក្នុង បឋមសារីបុត្តកោដ្ឋិតសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[៤១៤] បទថា *នេះជាពាក្យសំដៅដល់រូប (រូបគតមេតំ)* បានដល់មានត្រឹមតែរូបប៉ុណ្ណោះ ។ ក្នុងបទនេះ ព្រះសារីបុត្រសម្តែងថា នរណាៗក្រៅអំពីរូប រមែងមិនបានទទួលនាមថា សត្វ ដូច្នោះ កាលមានរូប វត្ថុនោះរមែងមានត្រឹមតែនាមប៉ុណ្ណោះ ។ សូម្បីក្នុងបទថា *នេះជាពាក្យសំដៅដល់វេទនា (វេទនាគតមេតំ)* ជាដើម ក៏ន័យនេះឯង ។ បទថា *លោកដ៏មានអាយុ (អយំខោ អាវុសោ ហេតុ)* សេចក្តីថា នេះគឺ សភាវៈដែលមិនគួរបានទទួល (ឈ្មោះ) ព្រោះផុតពីរូបជាដើម ជាហេតុដែលព្រះមានព្រះភាគទ្រង់មិនព្យាករណ៍បញ្ហាប្រការនោះ ។

ចប់អដ្ឋកថា បឋមសារីបុត្តកោដ្ឋិតសូត្រទី ៣

# អ ដ្ឋ ក ថា

## កុតុហលសាលាសូត្រទី ៩

ក្នុង កុតុហលសាលាសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[៤៤១] បទថា *ជជែលប្របល់ក្នុងសាលា (កុតុហលាយំ)* សេចក្ដីថា ចំពោះសាលាខ្លួននេះ ឈ្មោះថា *កុតុហាលា* មិនមាន តែសមណព្រាហ្មណ៍ទាំងឡាយអ្នកកាន់លទ្ធិផ្សេងៗ គ្នា សន្ទនាគ្នាដល់រឿងផ្សេងៗ ត្រង់សាលាណា សាលានោះ គឺ សាលាខ្លួននេះ សម្រាប់សមណព្រាហ្មណ៍ជាច្រើនលោកពោលដូច្នេះ ។ សាលានេះ លោកហៅថា *កុតុហលសាលា* ព្រោះជាទីកើតការប្រឈូកប្របល់ថា និយាយអ្វីហ្ន៎? ។

[៤៤២] បទថា *រមែងទៅឆ្ងាយ (ទូរំបិ គច្ឆតិ)* សេចក្ដីថា រមែងទៅជរាបដល់ព្រហ្មលោកជាន់អាភស្សរៈ ។ បទថា *លះបង់កាយនេះផង (ឥមញ្ច កាយំ និក្ខិបតិ)* សេចក្ដីថា រមែងលះបង់ចោលដោយចុតិចិត្ត ។ បទថា *មិនចូលដល់ (អនុប្បន្នោ ហោតិ)* សេចក្ដីថា រមែងមិនចូលដល់ ព្រោះបដិសន្ធិចិត្តមិនកើតក្នុងចុតិខណៈនុ៎ះឯង ។

ចប់អដ្ឋកថា កុតុហលសាលាសូត្រទី៩

---

# អ ដ្ឋ ក ថា

## អានន្ទសូត្រទី ១០

*ក្នុងអានន្ទសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[៤៤៣] បទថា ពាក្យព្យាករណ៍នោះ ក៏នឹងទៅរួមគ្នាជាមួយលទ្ធិរបស់សមណព្រាហ្មណ៍ដែលជាសស្សតទិដ្ឋិ (តេសមេតំ សទ្ធិ អភវិស្ស) សេចក្តីថា ពាក្យព្យាករណ៍នោះតែមួយជាមួយលទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះ ។ បទថា នឹងអនុលោមដើម្បីការកើតឡើងនៃញាណថា ធម៌ទាំងពួងជាអនត្តា (អនុលោមំ អភវិស្ស ញាណស្ស ឧប្បាទាយ សព្វេ ធម្មា អនត្តា) សេចក្តីថា វិបស្សនាញាណថា សព្វេ ធម្មា អនត្តា នេះ រមែងកើតឡើង ពាក្យព្យាករណ៍របស់យើងនោះ នឹងអនុលោមខ្លះឬទេហ្ន៎? ។*

ចប់អដ្ឋកថា អានន្ទសូត្រទី ១០

# អ ដ្ឋ ក ថា

## សភិយសូត្រទី ១១

ក្នុងសភិយសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[៤៤៥] បទថា ការពោលដោះស្រាយ បានសូម្បីត្រឹមនេះ (ឯត្តកេន ឯត្តកមេវ) សេចក្តីថា លោកដ៏មានអាយុ ការព្យាករណ៍របស់អ្នកដែលបង្ហាញថា បើហេតុមាន រូបរមែងមានជាដើម គឺ ព្យាករណ៍ថា បើហេតុមិនមាន រូបរមែងមិនមាន ដោយកាលប៉ុណ្ណោះ មានប្រើនសូម្បីត្រឹមនេះ ។ បទថា កាលបើពោលដោះស្រាយពីរោះយ៉ាងនេះ ក៏មិនចាំបាច់ត្រូវសួរអ្វីទៀត (កោ បនវាទោ អភិក្កន្តេ) សេចក្តីថា ក៏មិនត្រូវពោលអ្វី ក្នុងការព្យាករណ៍ដ៏ពីរោះ ព្រោះល្អគួរជាទីពេញចិត្ត ដោយន័យនៃធម្មទេសនាទុំះឯង មិនចាំបាច់ពោលអ្វីទៀត នឹងនិយាយគ្នាបាន ។

ចប់អដ្ឋកថា សភិយសូត្រទី ១១

## ចប់អព្យាកតសំយុត្ត

### រួមក្នុងវគ្គនេះមាន ១១ អដ្ឋកថា

១-អដ្ឋកថា ខេមាថេរីសូត្រ ២-អដ្ឋកថា បឋមសារីបុត្ត...សូត្រ
៣-អដ្ឋកថា កុតូហលសាលាសូត្រ ៤-អដ្ឋកថា អានន្ទសូត្រ
៥-អដ្ឋកថា សភិយសូត្រ

# ចប់

# អដ្ឋកថាសំយុត្តនិកាយ

# សឡាយតនវគ្គ

# អដ្ឋមភាគ

# ភាគ ៣៦

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 1.000 US |
| ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ នៅរដ្ឋម៉ាសាជូសេត សហរដ្ឋអាមេរិក | $ 300 US |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | $ 70 US |
| -ឧបាសក វ៉ាន់ ស៊ីមវ៉ា ឧបាសិកា តាំង សានីតា ព្រមទាំងបុត្ត | $ 30 US |
| -កុមារី តាំង សុមាវតី | $ 10 US |